ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

Royaume du Cambodge

Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ

# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី “ឌុច”

# សាធារណៈ

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩**

**សវនាការលើកទី៣០**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍

*(Judge Silvia Carwright)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវ៉ែន៍

*(Judge Jean-Marc Lavegne)*

លោក ធូ មណី

លោក យូរ ឧត្តរា *(បម្រុង)*

លោកស្រី ក្លូឌា ហ្វេនស៍ *(បម្រុង)*

*(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោកស្រី សែ កុលវុឌ្ឍី

លោក លឹម ស៊ុយហុង

កញ្ញា ណាថាក់ វិចស៊ែល

*(Ms. Natacha Wexels-Riser)*

លោក ម៉ាត្តូ គ្រីស្ពារ *(Mr. Matteo Crippa)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក យ៉េត ចរិយា

លោក វីលៀម ស្មីត *(Mr. William Smith)*

លោក ពេជ្រ សម្បត្តិ

លោក ហ្សាឆិរី ឡាំប៉ែល

*(Mr. Zachery Lampell)*

លោក ប៉ាក ច័ន្ទលីណូ (ក្រឡាបញ្ជី)

**ជនជាប់ចោទ៖**

លោក កាំង ហ្គេក អ៊ាវ

**មេធាវីការពារជនជាប់ចោទ៖**

លោក ការ សាវុត្ថ

លោក ហ្វ្រង់ស្វ័រ រូ (*François Roux)*

លោកស្រី ម៉ារីប៉ូល កានីហ្សារ

*(Mrs.Marie-Paule Canizares)*

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms. Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក គង់ ពិសី

លោក គីម ម៉េងឃី

កញ្ញា ទី ស្រ៊ីនណា

លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្គី

*(Ms. Silke Studzinsky)*

លោក អាឡាំង វ៉ែនណឺ

*(Mr. Alain Werner)*

លោកស្រី អេលីហ្សាប៉ែត រ៉ាបេសាន់ដ្រាតាណា

*(Ms. Elizabeth RABESANDRATANA)*

កញ្ញា ចេស្ស៊ីកា ហ្វីណែល

(*Ms. Jessica Finelle)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក កូវ កែវរតនៈ

# ឧបសម្ព័ន្ធ

## សាក្សី

**សាក្សី ៖** ជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច

សួរដោយ ប្រធានអង្គជំនុំ ផ្តើមពី ..........ទំព័រ ៤
សួរដោយ ចៅក្រម ធូ មណី ផ្តើមពី ..........ទំព័រ ៦
សួរដោយ ចៅក្រម ស៊ីលយ៉ា ខាត់វ៉ាយថ៍ ផ្តើមពី ..........ទំព័រ ១៥
សួរដោយ ប្រធានអង្គជំនុំ ផ្តើមពី ..........ទំព័រ ២៣
សួរដោយ ចៅក្រម យ៉ា សុខន ផ្តើមពី ..........ទំព័រ ៣២
សួរដោយ ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី ..........ទំព័រ ៤៩
សួរដោយ ប្រធានអង្គជំនុំ ផ្តើមពី ..........ទំព័រ ៦៧

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ហ្វ្រង់ស្វ័រ រូ | បារាំង |
| លោកស្រី សែ កុលវុឌ្ឍី | ខ្មែរ |
| លោក វាលៀម ស្មីត | អង់គ្លេស |
| ជនជាប់ចោទ | ខ្មែរ |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| ចៅក្រម ធូ មណី | ខ្មែរ |
| ចៅក្រម យ៉ា សុខន | អង់គ្លេស |

# កិច្ចដំណើរការនីតិវិធី

[០៩:០៥:៣០]

*[ចៅក្រមចូលមកកាន់បន្ទប់សវនាការ]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាស បន្តកិច្ចដំណើរការនីតិវិធីសវនាការ ។ អញ្ជើញលោក តំណាងសហព្រះរាជអាជ្ញា ។

**លោក វីលៀម ស្មីត៖**

អរុណសួស្តីលោកប្រធាន លោក លោកស្រីចៅក្រម លោកមេធាវី! ខ្ញុំចង់ធ្វើការទាញចំណាប់អារម្មណ៍អង្គសវនាការ ព្រឹកមិញនេះគឺ យើងបានពិនិត្យមើលសៀវភៅមួយ ទាក់ទងទៅនឹងសេចក្តីសន្និដ្ឋាន អនុលោមតាម៩២ ។ ហើយដែលយើងគិតថា រូបភាពមួយចំនួនទាក់ទងទៅនឹងប្រតិបត្តិការនៅជើងឯក និងនៅស-២១ ហើយនិងរូបភាពផ្សេងៗ ទាក់ទងទៅនឹងផ្នូររួមនៅជើងឯក ។ ហើយយើងមានរូបភាព១៣៦ គឺយើងបានដាក់ជូននៅថ្ងៃ៥ ខែឧសភា ។ សៀវភៅរូបភាពនេះគឺបានបង្កើតឡើងនៅក្នុងសំណុំរឿង ហើយខ្ញុំស្នើសុំអង្គសវនាការ ថាតើខាងអយ្យការនៅពេលណាមួយបន្ទាប់ពីការតាំងសំណួរទៅកាន់ជនជាប់ចោទ អំពីជើងឯក ថាតើអយ្យការនឹងអាចដាក់សៀវភៅរូបភាពនេះនៅពេលណាដែលសមរម្យ នៅចំពោះមុខអង្គសវនាការអនុលោមតាមវិធាន ៨៧.២ និង៣ ។ ហើយអ្វីដែលយើងចង់ធ្វើនោះ ក៏យើងចង់ដាក់ឯកសារដែលយើងបានលើកឡើងនៅក្នុងសេចក្តីកត់សម្គាល់របស់សហព្រះរាជអាជ្ញា គឺលេខ E53 ដែលយើងដាក់កាលពីខែមុន ។ ហើយយើងបានផ្តល់សៀវភៅមួយជូនលោកចៅក្រមហើយ ។ ហើយរូបភាពមួយចំនួនយើងបានប្រើនៅថ្ងៃនេះ ។ ហើយរូបភាពទាំងអស់នោះគឺ ហាក់ដូចជាមិនមាននៅក្នុងកំណត់ហេតុសំណុំរឿងនោះទេ ។ ដូច្នេះ គឺខ្ញុំសូមសួរថាតើនៅពេលណាដែលសហព្រះរាជអាជ្ញាអាចដាក់ឯកសារនេះ ជូនអង្គសវនាការដើម្បីបង្ហាញសាធារណជនអំពីលក្ខណៈនៃរូបភាពទាំងអស់នោះ ។ ហើយអនុលោមតាមកិច្ចប្រជុំរៀបចំសវនាការ អង្គសវនាការបានរៀបរាប់និងលើកឡើងអំពីការធ្វើសេចក្តីសង្ខេបទៅលើឯកសារផ្សេងៗ ។ ហើយចំណុចទីបី គឺខ្ញុំចង់ធ្វើការដាក់ជូនអង្គសវនាការអំពីបញ្ជីអ្នកទោសដែលយើងបានកែតម្រូវ ហើយនិងឧបសម្ព័ន្ធដែលមានចំនួន៥១ វាទាក់ទងប្រភេទអ្នកទោសនៅស-២១ ហើយនិងពេលវេលាដែលបុគ្គលមានវត្តមាននៅស-២១។ ហើយ

ឯកសារមួយចំនួន លោកចៅក្រមបានលើកឡើងជាក់លាក់ហើយ ប៉ុន្តែ ឯកសារមួយចំនួនផ្សេងទៀតមិនទាន់បានលើកឡើងនៅឡើយទេ ។ ហើយយើងមិនមែនសុំដាក់ឧបសម្ព័ន្ធនីមួយៗនោះបង្ហាញជូនជនជាប់ចោទនោះទេ ។ ហើយយ៉ាងណាក៏ដោយខ្ញុំជឿថា ខាងមេធាវីការពារក្តីអាចលើកចំណុចសង្កេតរបស់ខ្លួន ។

ដូច្នេះ ខ្ញុំសុំស្នើថា ខ្ញុំសុំដាក់ឯកសារបីនោះប្រហែលជាយើងចំណាយពេលម្ភៃទៅសាមសិបនាទីទៅតាមសេចក្តីណែនាំរបស់អង្គសវនាការ ។ ហើយយើងអាចធ្វើការបង្ហាញជូនក្នុងរយៈពេលខ្លីជាងនេះ ។ ហើយដើម្បីជាផលប្រយោជន៍របស់សារធារណជននោះ គឺខ្ញុំគិតថាឯកសារទាំងអស់នោះ អាចបង្ហាញក្នុងរយៈពេលម្ភៃនាទីតែប៉ុណ្ណោះ ។ ហើយខ្ញុំសូមសួរថា តើពេលណាដែលសមស្របដើម្បីឲ្យខ្ញុំអាចបង្ហាញបាន ។ ហេតុអ្វីបានជាខ្ញុំលើកឡើងចំណុចនេះ? ដោយសារតែនៅពេលនោះគឺយើងកំពុងតែផ្តោតទៅលើអង្គហេតុពីស-២១ ទៅដល់ស-២៤ ហើយគឺខ្ញុំសួរនេះដើម្បីឲ្យមានការបញ្ជាក់ ច្បាស់ថាខ្ញុំអាចបង្ហាញឯកសារនៅពេលណា ដើម្បីយើងអាចកត់បញ្ចូលទៅក្នុងសំណុំរឿង ហើយនិងវាទាក់ទងទៅនឹងបញ្ជីភស្តុតាងផ្សេងៗទៀត ដែលខ្ញុំបានបញ្ជាក់អម្បាញ់មិញនេះ ។

[០៩:០៩:៣៥]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:១០:៥៧]

**ប្រធានអង្គជំនុំ៖**

អរគុណលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិដែលបានលើកឡើងអំពីបញ្ហានេះ ។ ហើយអង្គជំនុំជម្រះក៏បានទទួលនូវបណ្តុំនៃរូបភាពទាំងអស់នោះ ដែលលោកព្រះរាជអាជ្ញាប៉ុនប៉ងថានឹងដាក់បញ្ចាំងនៅក្នុងអំឡុងពេលដំណើរសវនាការនេះដែរ ។ ប៉ុន្តែ តើមានភាគីណាជំទាស់នឹងការប៉ុនប៉ងក្នុងការលើកនូវរូបភាពមួយចំនួនដើម្បីយកមកបញ្ចាំងជាសារធារណៈ នៅក្នុងសាលសវនាការនេះដែរឬទេ? បើសិនជាមិនមានទេ គឺអង្គជំនុំជម្រះបានពិចារណាហើយ ឃើញថា នឹងដាក់ ។

**លោក ហ្វេង់ស្វ័រ រូ៖**

លោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព! ខ្ញុំសូមធ្វើការទាញការចាប់អារម្មណ៍ពីអង្គសវនាការចំពោះករណីដែលថាសហព្រះរាជអាជ្ញា ការិយាល័យសហព្រះរាជអាជ្ញាមានការប្រញាប់ប្រញាល់ក្នុងការធ្វើឡើងដូច្នេះ ដែលគាត់មិនបានគិតអំពីវិធានមួយចំនួនដែលយើងមិនអនុញ្ញាតឲ្យធ្វើការ

លើកឡើងបង្ហាញឈ្មោះសាក្សី វាជាការហាមទៅលើបទប្បញ្ញត្តិនេះ។ ហើយនៅក្នុងសៀវភៅរូបភាពនោះ គឺវាមានឈ្មោះនិងរូបភាពលើអំពីសាក្សីមួយចំនួន ដែលមិនទាន់បានកោះហៅមកផ្ដល់សក្ខីកម្មនៅឡើយ ។ ដូច្នេះហើយ ខ្ញុំសុំឲ្យសហព្រះរាជអាជ្ញាធ្វើការកត់សម្គាល់ទៅលើបញ្ហានេះ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ដើម្បីធ្វើការបំភ្លឺខាងមេធាវីការពារក្ដីដែលបានលើកឡើងនោះ លោកបានបញ្ជាក់ប្រាប់យើងថា លោកមិនមានការជំទាស់ទៅលើគោលការណ៍វិធានច្បាប់របស់យើង ប៉ុន្តែ លោកធ្វើការកត់សម្គាល់ និងជំទាស់ទៅលើរយៈពេលនោះឬក៏យ៉ាងម៉េច?

**លោក ហ្វ្រង់ស្វ័រ រូ៖**

ខ្ញុំទើបតែឮលោកសហព្រះរាជអាជ្ញា កំពុងស្នើសុំឲ្យយើងផ្ដល់យោបល់ជាសារធារណៈនៅថ្ងៃនេះទៅលើឯកសារដែលមាននៅក្នុងសំណុំរឿង គឺនៅពេលនេះ យើងមិនអាចផ្ដល់ជាយោបល់ទៅលើឯកសារនោះទេ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកបានលើកឡើងថា យើងមិនអាចប្រើប្រាស់រូបភាពទាំងអស់នោះ ដែលសាក្សីទាំងអស់មានការការពារ ហើយយើងមិនអាចបង្ហាញឈ្មោះរបស់គេ ហើយចំពោះឯកសារផ្សេងៗទៀត តើយ៉ាងម៉េចដែរ លោកអត់មានជំទាស់ ឬក៏លោកមានការជំទាស់?

**លោក ហ្វ្រង់ស្វ័រ រូ៖**

ខ្ញុំអត់មានការជំទាស់ ទៅលើឯកសារផ្សេងទៀតនោះទេ ។

**លោក វីលៀម ស្មីត៖**

សូមអរគុណលោកចៅក្រម គឺខ្ញុំសុំលើកដោយសង្ខេប ។ ទាក់ទងទៅនឹងការស្នើរបស់ខ្ញុំនេះ គឺខ្ញុំនឹងសុំពេលវេលាមួយចំនួនធ្វើការពិនិត្យទៅលើសំណើរបស់ខ្ញុំ ។ ហើយយើងមានដាក់ឈ្មោះនៅក្នុងពាក្យសុំរបស់យើងព្រឹកមិញ ហើយយើងយល់អំពីជំហររបស់មេធាវីការពារក្ដី ។ ហើយទាក់ទងទៅនឹងការបង្ហាញសាក្សីនោះ គឺយើងនឹងគិតគូរអំពីបញ្ហានៃការបង្ហាញឈ្មោះ ហើយយើងអត់មានធ្វើការចង់បង្ហាញឈ្មោះទៅលើសាក្សីអស់ទាំងនោះទេ ។

**ប្រធានអង្គជំនុំ៖**

អរគុណបើដូច្នេះ យើងឃើញថាមិនមានការជំទាស់អីជាក់លាក់ទេ។ ហើយអង្គជំនុំជម្រះបានពិចារណាហើយសម្រេចថា បណ្តុំនូវរូបភាពដែលសហព្រះរាជអាជ្ញាប៉ុនប៉ងក្នុងការដាក់បង្ហាញជូនតាមកញ្ចក់ទូរទស្សន៍ជាសាធារណៈនោះឃើញថា អង្គជំនុំជម្រះសម្រេចថា នឹងអនុញ្ញាតនៅក្រោយពេលធ្វើការដេញដោលអំពីអង្គហេតុនៃប្រតិបត្តិការស-២១ និងជើងឯកចប់ ។ ហើយប្រសិនបើក្នុងអំឡុងពេលថ្ងៃនេះ បើពេលវេលាសមស្របដែលយើងអាចធ្វើទៅ ហើយចុងម៉ោងដូចជាល្ងាចនេះអីជាដើមបើសិនជាយើងមានពេល គឺយើងនឹងអនុញ្ញាតនៅពេលវេលាចុងម៉ោង ។ បើពុំមានក៏យើងលៃពេលណាមួយសមស្របនៅក្រោយពេលដែលចប់ការដេញដោលទៅលើអង្គហេតុប្រតិបត្តិការស-២១ និងជើងឯកនេះដែរ ។ សូមអញ្ជើញលោកហ្សង់ម៉ាក ។

[០៩:១៥:៥៤]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ដូច្នេះ ការព្យួរទុកសេចក្តីសម្រេចរបស់អង្គសវនាការគឺថា ឯកសារដែលមានលើកឡើងឈ្មោះឬក៏ព័ត៌មានទាក់ទងទៅនឹងសាក្សី ដែលត្រូវបានការពារនោះគឺ យើងមិនគួរធ្វើការបង្ហាញទេ លើកលែងតែយើងមានការអនុវត្តទៅលើវិធានការការពារផ្សេងៗ ។

**ប្រធានអង្គជំនុំ៖**

អនុរក្សមន្ទីរឃុំឃាំង នាំជនជាប់ចោទមកកាន់ឈើរាងវង់ក្រចកសេះនៅទីនោះ ។

នៅថ្ងៃនេះយើងនឹងធ្វើពិភាក្សាដេញដោលលើអង្គហេតុនៃការសម្លាប់នៅមន្ទីរស-២១ បច្ចុប្បន្នយើងហៅថា គុកទួលស្លែង និងតំបន់ជុំវិញគុកទួលស្លែង។ អំណាចនៃក្នុងការបញ្ជាសម្លាប់ហើយនិងសម្លាប់នៅវាលពិឃាតជើងឯក នេះជាអង្គហេតុដែលត្រូវពិភាក្សាដេញដោលនៅថ្ងៃនេះ ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោក កាំង ហ្កេកអ៊ាវ តើចំនួនជនរងគ្រោះយ៉ាងតិចបំផុតមានចំនួន ១២៣៨០នាក់ ត្រូវបានសម្លាប់នៅក្នុងដំណើរការនៃប្រតិបត្តិការស-២១ ចាប់តាំងពីពេលបង្កើតរហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ ១៩៧៩ ។ យើងនិយាយដូច្នេះជាការត្រឹមត្រូវទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន បើនិយាយពីចំនួនជនរងគ្រោះ ដែលទៅស្លាប់នៅទីនោះចំនួនប៉ុណ្ណេះវាជាចំនួនដែលខ្ញុំមិនដែលបានហ៊ាននិយាយថាចំទេ វាជាចំនួនតិចបំផុត លើសពីនុ៎ង នេះ

និយាយពីចំនួន ។ សុំបញ្ចប់ ។

[០៩:១៩:៣៦]

**ស៖** ទីកន្លែងនៃការដែលគណៈកម្មាធិការស-២១ ជ្រើសរើសដើម្បីធ្វើការសម្លាប់ទៅលើជនរងគ្រោះទាំងអស់នោះ តើប្រតិបត្តិការនោះនៅកន្លែងណា ទាំងការសម្លាប់ ទាំងការកប់សាកសព ប្រព្រឹត្តទៅនៅកន្លែងណាខ្លះទៅ?

[០៩:២០:០២]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! មានបីកន្លែងសំខាន់ ។ កន្លែងទីមួយ នៅពេទ្យឆ្កួតតាខ្មៅ កន្លែងនេះ យើងខ្ញុំបានគាស់អដ្ឋិធាតុយកមកដុតអស់ទៅហើយ អត់មាននៅសល់ស្លាកស្នាមទេ ភស្តុតាងទេ ។ កន្លែងទីពីរ គឺនៅជុំវិញស-២១មជ្ឈមណ្ឌលភ្នំពេញ ដែលយើងធ្លាប់ហៅដែរថា “គុកទួលស្លែង” ។ ហើយទីបី គឺនៅមជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក ។ ដូច្នេះ តាមខ្ញុំចាំគឺមានបីកន្លែងហ្នឹងឯង មិនហួសទៅឯណាទៀតទេ ។

**ស៖** នៅក្នុងដំណើរការប្រព្រឹត្តទៅនៃការសម្លាប់ យើងប្រើពាក្យពីមុនកម្ទេច ។ តើអ្នកណាជាអ្នកសម្រេចកម្ទេចលើអ្នកទោសដែលបានចាប់បញ្ជូនមកដល់ស-២១?

**ឆ៖** អ្នកសម្រេចកម្ទេចគឺអ្នកដែលមានសិទ្ធិសម្រេចកម្ទេច ដូចមានចែងនៅក្នុងឯកសារថ្ងៃ៣០ មីនា ១៩៧៦ ។ បើនិយាយឲ្យចំនៅស-២១ គឺលេខាសេនាធិការ ។ ដូច្នេះ មនុស្សដែលសេនាធិការគេសម្រេចកម្ទេចហើយ ជាការចប់ហើយស-២១ ត្រូវតែធ្វើតាមបង្គាប់គេកុំដោះលែង នេះជាការសម្រេចនឹងន។ ក៏ប៉ុន្តែ ដើម្បីកិច្ចដំណើរការស-២១ ឬក៏តាំងពីគុកកងពល៧០៣មក គឺអ្នកនៅខាងក្រោមគេអ្នកសម្រេច ដើម្បីឲ្យកិច្ចដំណើរការហ្នឹង កុំឲ្យកកស្ទះ អ្នកណាសួរហើយយកចេញ នេះជាកិច្ចដំណើរការប្រចាំ ។

ដោយឡែក តាំងពីខ្ញុំចូលទៅជាអនុប្រធាន ហើយនិងជាប្រធានស-២១ អ្នកដែលគិតគូរបញ្ហានេះកុំឲ្យកកស្ទះ ហើយនាំយកចេញទៅហ្នឹង ដំបូងមាន មិត្តហ៊ី គិតគូ ។ ដល់ក្រោយមកមានរឿងឧបសគ្គមួយ ដែលខ្ញុំតែងតែនិយាយញឹកញាប់ដែរគឺ មិត្តហ៊ី គាត់យកមនុស្សម្នាក់ដែលកំពុងសួរចម្លើយយកទៅកម្ទេចមុនពេលចប់ ។ តាំងពីពេលនោះមក មុននឹងយកទៅត្រូវតែសុំយោបល់ខ្ញុំសិន សួរចប់ហើយឬនៅ? បើសួរចប់ហើយ អាហ្នឹងគេចាត់ចែងហើយ ។ ដូច្នេះ កិច្ចដំណើរការវាមានលក្ខណៈពីរច្បាស់លាស់។ លក្ខណៈទីមួយ អ្នកសម្រេចបញ្ជូនមកគឺ សេនាធិការ តាងនាមឲ្យអចិន្ត្រៃយ៍មជ្ឈិមបក្ស។

ទីពីរ អ្នកដំណើរការដើម្បីកុំឲ្យការកកស្ទះគឺ គណៈកម្មាធិការស-២១ អ្នកដែលជិតដល់ក្នុងបញ្ហានេះជាក់ស្ដែងគឺ អនុលេខាស-២១ និយាយអ៊ីចេះ អត់ចៀសពីឧក្រិដ្ឋកម្មនេះទេ ក៏ប៉ុន្តែការងារនេះវាជាបន្ទុកដែលយើងខ្ញុំផ្ទេរទៅឲ្យគេ ។ ហើយការងារនេះ វារត់របត់តាំងពីនៅជាមន្ទីរនគរបាលកងពល៧០៣ម្លេះ ។ សូមបញ្ចប់ ។

**ស៖** នៅក្នុងមន្ទីរនៃមជ្ឈមណ្ឌលមន្ទីរស-២១ ក្រុងភ្នំពេញ នៅក្នុងមណ្ឌលហ្នឹង តើមានការសម្លាប់ហើយកប់សាកសពនៅទីនោះទេ? យើងមិននិយាយពីខាងក្រៅទេ និយាយពីក្នុងរង្វង់នៃមន្ទីរ ។

[09:00:00]

**ឆ៖** ក្នុងរង្វង់ បើតាមខ្ញុំគិតគឺ សំដៅបរិវេណវិទ្យាល័យពញាយ៉ាត តាមការដែលទៅតទល់គ្នាបង្ហាញភស្តុតាងនោះ ពួកនោះ ដូចនិយាយថា នៅក្បែរខាងក្នុងបរិវេណវិទ្យាល័យពញាយ៉ាត មានៗកប់សាកសពដែរ ជាពិសេសសាកសពកុមារ ឲ្យខ្ញុំជាក់ស្ដែង ខ្ញុំអត់ដឹងទេ ។ ប៉ុន្តែ បើនៅខាងក្រៅមាន ។ ខាងក្រៅមិនឆ្ងាយផុតពីផ្លូវលេខ អូយ! ភ្លេចផ្លូវលេខ លេខប៉ុន្មានទេ ៦១៣ អ៊ីចឹងមិនដឹង មិនៗផុត ពីផ្លូវវត្តមហាមន្ត្រីទេ នៅទៅខាងលិច ហើយខាងជើងមិនផុតពីផ្លូវលេខ៣១០ ហើយខាងត្បូងអាចផុតផ្លូវលេខ៣៦០ អ្ហ៎! ដូចមិនផុតទេ ។ នេះសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ យើងធ្វើការដេញដោលលើអង្គហេតុប្រតិបត្តិការនៃការសម្លាប់នៅក្នុងក្របខ័ណ្ឌនៃបរិវេណមន្ទីរស-២១ ហើយនិងបរិវេណជុំវិញមន្ទីរស-២១ ។ តើអស់លោក លោកស្រីចៅក្រមមានសំណួរអ្វីចង់ ថាត្រូវសួរដល់ជនជាប់ចោទរូបនេះទេ អំពីអង្គហេតុដែលខ្ញុំបានបញ្ជាក់អម្បាញ់មិញនេះ ។ បើមានសូមអញ្ជើញ។ សូមអញ្ជើញ លោកចៅក្រម ធូ មណី ។

**សួរដោយចៅក្រម ធូ មណី៖**

សូមអរគុណលោកប្រធាន ។

**ស៖** ជនជាប់ចោទ តើលោកបានអះអាងអំមិញហើយថា កន្លែងដែលសម្លាប់ ហើយកប់ជនរងគ្រោះ ឬក៏អ្នកទោសហ្នឹង មានបីកន្លែងសំខាន់គឺ ទីមួយ នៅគុកតាខ្មៅ ទីពីរ បរិវេណជុំវិញនៅនិងខាងក្នុងមន្ទីរស-២១ ហើយនិងទីបី នៅកន្លែងមជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក ។ តើលោកអាចពន្យល់ប្រាប់យើងបានទេ ថាតើអ្នកទោសប្រភេទណា ដែលត្រូវបានសម្លាប់នៅក្នុងមន្ទីរស-២១ ឬក៏បរិវេណជុំវិញមន្ទីរស-២១?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម ។ មនុស្សដែលសម្លាប់នៅក្នុងមន្ទីរស-២១ ហើយនិងបរិវេណស-២១ មានចំនួនច្រើន ។ ខ្ញុំអាចនិយាយជាសរុបជូនថា ក្រោយពីការសម្លាប់ហើយនិងកប់នៅពេទ្យឆ្កួតតាខ្មៅ អង្គភាពនេះសម្លាប់និងកប់សាកសពនៅខាងលិច ហើយនិងក្នុងបរិវេណវិទ្យាល័យពញាយ៉ាត ។ ខ្ញុំសូមជូនរឿងមួយ ដែលខ្ញុំបានជម្រាបលោកចៅក្រមដោយផ្ទាល់ពីមុន ខ្ញុំត្រូវគេបង្គំបញ្ជាឲ្យទៅពិនិត្យមើលការសម្លាប់បុគ្គលសំខាន់ពីររូបគឺ នង សួន និង សួស នៅ ហៅ ឈូក ។ ខ្ញុំបានរាយការណ៍ជូនលោកចៅក្រមហើយ ខ្ញុំសូមរាយការណ៍បញ្ជាក់ព្រឹត្តិការណ៍នេះថែមម្តងទៀត នៅពេលនោះអចិន្ត្រៃយ៍ឲ្យខ្ញុំទៅមើលម៉ោងប្រាំភ្លឺ នៅខាងលិចបរិវេណវិទ្យាល័យពញាយ៉ាតនេះ គេធ្វើឃាតសួស នៅ ហៅ ឈូក ហើយនិង នង សួន ពេលហ្នឹងគេប្រើកាំបិតចាក់សសៃបំពង់ក សសៃឈាមធំនៅគល់កហ្នឹង ។ ដូច្នេះ មនុស្សសំខាន់ក៏មាន មនុស្សធម្មតាក៏មាន ក៏ប៉ុន្តែ ចន្លោះពេលដែលតាខ្មៅមិនសូវបានប្រើជាញឹកញាប់ ហើយជើងឯកមិនទាន់បានជ្រើសរើស ។ ដូច្នេះ ខ្ញុំសូមសរុបប៉ុណ្ណឹង សូមអស់យោបល់ ។

[០៩:២៨:៣៦]

**ស៖** លោកអាចបញ្ជាក់បាទេថា នៅក្នុងអំឡុងពេលដែលមន្ទីរស-២១ត្រូវបានស្ថិតនៅក្នុងទីតាំងនៃអង្គភាពនគរបាលជាតិ ដែលហៅថា *ប៉េហ្ស៊ី(PJ)* នោះ តើការសម្លាប់អ្នកទោសត្រូវធ្វើនៅទីណា? ហើយសាកសពត្រូវយកទៅកប់នៅទីណា?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! រឿងនេះ ខ្ញុំមិនជាក់ស្តែងក៏ពិតមែន តែខ្ញុំសូមជូនជាសេចក្តីសន្និដ្ឋាន ដែលអាចពិតជាមូលដ្ឋាន គឺនៅ *ប៉េហ្ស៊ី* គេមិនសម្លាប់ ហើយនិងគេមិនកប់នៅទីនោះទេ ព្រោះដីនៅទីនោះ សុទ្ធតែថ្មភាគច្រើន បើតាមខ្ញុំសន្និដ្ឋាន គឺពេលនោះ គេសម្លាប់នៅតាខ្មៅ ។ ហើយ *ប៉េហ្ស៊ី* ហ្នឹងគ្រាន់តែជាកន្លែងស្តុកទុកសម្រាប់សួរចម្លើយប៉ុណ្ណឹង ។ នេះសូមសង្ខេបជូន វិភាគ និងសន្និដ្ឋានជូនប៉ុណ្ណោះ ។

**ស៖** ដូចលោកធ្លាប់បានអះអាងកន្លងមកហើយថា អ្នកដែលត្រូវបានចាប់ខ្លួនមកមន្ទីរស-២១ គឺសុទ្ធតែត្រូវបានសួរចម្លើយ ហើយបន្ទាប់ពីបានចម្លើយសារភាពហើយត្រូវយកទៅសម្លាប់ ។ ហើយលោកក៏បានអះអាងទៀតថា ការបញ្ជាជាទូទៅហ្នឹងគឺ ខាងលើថ្នាក់លើជាអ្នកបញ្ជាមក កាលណាអ្នកដែលចាប់ខ្លួនមកមន្ទីរ ស-២១ ហើយ គឺមិនអាចដោះលែងទៅវិញបានទេ ។ ប៉ុន្តែ ខ្ញុំចង់បញ្ជាក់ថាបន្ទាប់ពីបានសួរចម្លើយរួចរាល់ ហើយនិងបានចម្លើយសារភាពហើយ តើអ្នកណាឲ្យច្បាស់លាស់ជាអ្នក

បញ្ជាឲ្យយកអ្នក ដែលត្រូវបានសួរចម្លើយនោះទៅសម្លាប់ ឬក៏ម្ដេច?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! បញ្ហានេះត្រូវចែកជាពីររយៈកាលសំខាន់។ រយៈកាលទីមួយ គឺនៅពេលមុនដែលមានព្រឹត្តិការណ៍សម្លាប់ដាច់ចម្លើយទៅលើបុគ្គលឈ្មោះ សឹន សារី ហៅ ប្រេវ ។ រឿងនេះសម្រេចចាត់ចែងនៅលើ មិត្តហ៊ី គាត់អ្នកចាត់ចែង ក្នុងគោលបំណងម្ចាស់ការកុំឲ្យកកស្ទះកិច្ចដំណើរការ ទាំងកន្លែងឃុំឃាំង ទាំងចំនួនជនរងគ្រោះដែលឃុំឃាំងនៅទីនោះ តិចល្មមកុំឲ្យរត់រួចអី ។ ដល់ក្រោយមានព្រឹត្តិការណ៍ដែលគាត់សម្លាប់ឲ្យដាច់ចម្លើយ សឹន សារី ហៅ ប្រេវ មកមេព្រមានគាត់ម្ដង ។ ពេលនុំងហើយដែលចាប់ផ្ដើម អ្នកណាដែលសួរចម្លើយចប់ មិត្តហ៊ី យកមកសុំយោបល់ខ្ញុំ ថាអានេះចប់ហើយបង ខ្ញុំថា អើ បើចប់ហើយ អនុវត្តទៅ ។

[០៩:៣១:៤៨]

ខ្ញុំក៏ទទួលស្គាល់ថាអាហ្នឹងវាចប់ ។ ប៉ុនបណ្ដាំរបស់មេ គឺមុននឹងយកទៅឲ្យទាល់តែចម្លើយចប់នេះបណ្ដាំពិតប្រាកដ ។ ដូច្នេះ លក្ខខណ្ឌដែលមេដាក់ឲ្យគឺ សួរចម្លើយចប់បានយកទៅបាន ។ នេះគឺវាមានពីរដំណាក់សំខាន់អ៊ីចឹង ។ ប៉ុន្តែ ក្នុងដំណាក់ទីពីរនេះ វាមានលក្ខណៈពិសេសខ្លះ ឧទាហរណ៍ ដូចក្នុងបញ្ជី159/4.10 អ៊ីចឹង ខាងលើបញ្ជូនមកទាំងឈុត មនុស្សមួយរយនាក់ ។ មកដល់ថ្ងៃ២៣ បញ្ជាឲ្យ ស-២១ អនុវត្ត ពេលនោះមិត្តហ៊ី គាត់នៅ ខ្ញុំក៏នៅ ។ មិត្តហ៊ី គាត់ប្រើពាក្យមួយដែលគាត់ធ្លាប់មានដក់ក្នុងខួរក្បាល ខ្ញុំកែតម្រូវ ។ ដូច្នេះ លក្ខណៈនេះ វាបញ្ជាក់ថា កាលណាមកទាំងឈុតអ៊ីចឹង វាមានរឿងខ្លះដែលយើងមិនទាន់យល់ពាក្យពេចន៍គ្នាទៅវិញទៅមក ។ ក៏ប៉ុន្តែ យើងទាំងអស់គ្នាត្រូវតែអនុវត្តតាមកិច្ចបញ្ជាពីលើ នេះមួយរឿង ។

មួយរឿងទៀត ខ្ញុំនិយាយជាហូរហែហើយ ពេលដែល មិត្តហ៊ី មិននៅ ខាងលើហៅខ្ញុំយកបញ្ជីទៅ នេះមួយរឿង ។ ទៅដល់គាត់ចាត់ចែង នេះៗ អានេះគួរចេញ អានោះគួរចេញ អីៗទៅ បន្ទរៗ អាហ្នឹងមួយរឿង នៅសល់ជាឯកសារ ។ ហើយមួយលើកទៀត មិត្តហ៊ី មិននៅដែរ អាហ្នឹង ខ្ញុំឲ្យ ប៉េង ធ្វើ អាហ្នឹងក៏មានមួយបែបទៅទៀតវាមានគន្លឹកគន្លាក់អ៊ីចឹង ។ ដល់ចុងក្រោយពួកបូព៌ាអត់មានគន្លឹកគន្លាក់អីទេ គឺវាចូលមកដល់ គឺយកចេញ ប្រហែលជាបីរយនាក់ ។ សរុបមក ក្នុងដំណាក់កាលទីពីរនេះវាមានលក្ខណៈ ជាលក្ខណៈពិសេសខ្លះ ដូចដែលខ្ញុំបានរាយការណ៍ជូនអ៊ីចឹង ។ ក៏ប៉ុន្តែ សរុបមក នៅតែគណៈកម្មាធិការស-២១ វាសម្រេច អនុវត្តគោលនយោបាយរបស់បក្ស ខ្លាំងត្រូវតែកម្ទេច ។

សូមបញ្ចប់ ។

**ស៖** សូមអរគុណ ។ ហើយតើលោកអាចបញ្ជាក់បានទេ ថាតើក្រោយពីបានទទួលបញ្ជាឱ្យយកអ្នកទោសយកទៅសម្លាប់ ឬក៏អ្នកដែលបានឆ្លើយសារភាព ហើយយកទៅកម្ទេចហ្នឹង តើអង្គភាពណាមួយដែលជាអ្នកទទួលបន្ទុកក្នុងការអនុវត្តយកអ្នកទោសទៅសម្លាប់?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! អង្គភាពតែមួយទេគឺ កងពិសេស ឯចំណែកបីបួននាក់ដែលចាំនៅហ្នឹង ជើងឯកនោះ ជាផ្នែកមួយតូចរបស់កងពិសេស ។ សូមអស់យោបល់ ។

[០៩:៣៤:៥៨]

**ស៖** តើគេអនុវត្តការសម្លាប់ទៅលើអ្នកទោសយ៉ាងដូចម្តេច? និយាយឱ្យចំថា តើគេប្រើវិធីណាខ្លះទៅលើក្នុងការសម្លាប់អ្នកទោស?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! វិធីដែលប្រែមកពីចាក់ត្រង់គល់កនេះមកជាវ៉ៃ ខ្ញុំមិនដឹងថាប្រែពីអង្កាល់ទេ ។ ក៏ប៉ុន្តែ ជឿថាពិតជាមានប្រែ ព្រោះ មិត្តហ៊ុយ អង្កាល់ដែលទៅតទល់នៅជើងឯកនោះ គាត់និយាយអំពីរឿងវ៉ៃនៅកញ្ចឹងកហ្នឹង ។ ដូច្នេះ ប្រែ តែមិនដឹងប្រែពីអង្កាល់ទេ ។ សូមជម្រាបលោកចៅក្រមប៉ុណ្ណេះ សូមចប់ ។

**ស៖** វិធីណាផ្សេងទៀតដែរក្នុងការសម្លាប់អ្នកទោស?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ក្រៅពីវិធីចាក់កហើយនិងវិធីវ៉ៃ មានតែវិធីបូមឈាមហើយនិងយកមនុស្សម្នាក់ពីរយកទៅវះកាត់ដើម្បីរៀនកាយវិភាគ ។

**ស៖** តើលោកមានដែលបានបង្រៀន អំពីវិធីសាស្ត្រក្នុងសម្លាប់អ្នកទោសដល់បុគ្គលិកមន្ទីរស-២១ដែរ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ខ្ញុំអត់បង្រៀនទេ។ ដូចខ្មែរយើង ខ្ញុំជម្រាបបន្តិចទៅចុះ ខ្មែរយើងថា ខ្ញុំអត់ទៅបង្រៀនក្រពើឱ្យចេះហែលទឹកទេ ឱ្យហែលទេ ។ នេះគេចេះហែលហើយ ។

**ស៖** នៅក្នុងមន្ទីរស-២១ តើមានអ្នកទោសដែលបានស្លាប់នៅក្នុងអំឡុងពេលទទួលទារុណកម្មនូវការសួរយកចម្លើយដែរ?

**ឆ៖** ជម្រាបប្រសាសន៍! មាន ។

**ស៖** តើជាញឹកញាប់ទេ?

**ឆ៖** ជម្រាបប្រសាសន៍! ខ្ញុំក្តាប់មិនសូវបានទេក៏ប៉ុន្តែដំណឹងដែលមកដល់ខ្ញុំហើយខ្ញុំនៅចងចាំ ។ ហើយម្យ៉ាងទៀតរឿងហ្នឹងវាឃ្លាតឆ្ងាយហើយ ។ រឿងមួយគឺរឿងដែលខ្ញុំបាទបានជម្រាបអង្គជំនុំជម្រះ

យើងកាលពីម្សិលមិញហើយ ការដែលស្លាប់ដាច់ចម្លើយហើយ ខ្ញុំឱ្យសាមីខ្លួនគេសរសេរចម្លើយហ្នឹង ហើយខ្ញុំសុខចិត្តរាយការណ៍ទៅលើខាងពន្យល់ខាងលើ នេះទីមួយ ។

ទីពីរទៀត ឈ្មោះ ខឹម ភ ល្មើសក្នុងវិន័យធ្វើទារុណកម្ម យកអាស្បែកជើងប៉ូលិសអានេះ-- ទៅទាត់ឆ្អឹងជំនីជនរងគ្រោះដែលខ្លួនឯងត្រូវសួរ ស្លាប់ដាច់ចម្លើយ ។ ហ្នឹងមួយ ។ ហើយមួយទៀត ឃើញរូបថតដែលនៅសល់ម្នាក់នោះត្រូវគេច្រកស្បោងផ្លាស្ទិកស្លាប់ នៅដេកនុ៎ងមានស្បោងប្លាស្ទិកនៅក្បែរនោះ ។ ដូច្នេះឯកសារដែលនៅសល់ ខ្ញុំឃើញបីប៉ុននុ៎ង ។ ឯការដែលរាយការណ៍ដល់ខ្ញុំឃើញមានច្បាស់លាស់បំផុត គឺអារឿងដែលស្លាប់ឈ្មោះ ពឹង គឹមសៀ ហ្នឹងឯង ។ ព្រោះ ពឹង គឹមសៀ នោះសំខាន់គួរសមដែរ ។ នេះសូមសរុបជូនលោកចៅក្រមប៉ុណ្ណេះ ។

[០៩:៣៨:៥៩]

**ស៖** តើនៅក្នុងស-២១ មានវិធីដែលបង្អត់អាហារអ្នកទោសរហូតដល់អ្នកទោសស្លាប់បាត់បង់ជីវិតដែរ?

**ឆ៖** ខ្ញុំជម្រាបប្រសាសន៍លោកចៅក្រមដោយស្មោះត្រង់ ខ្ញុំអត់ក្តាប់បានបញ្ហានេះ ហើយមិនដែលឮអ្នកណារាយការណ៍បញ្ហានេះទេ ក៏ប៉ុន្តែអាចមានលទ្ធភាពដល់ហ្នឹង ។ ជឿ បើលទ្ធភាពហ្នឹងខ្ញុំជឿមាន ។

**ស៖** ក្រៅពីវិធីនេះ តាមការសិក្សាគឺថាមានចម្លើយសាក្សីខ្លះបានបញ្ជាក់ថាមាននូវបុគ្គលិកមន្ទីរស-២១ មានយកសត្វអសិរពិសយកទៅឱ្យខាំទៅលើអ្នកទោសរហូតដល់បាត់បង់ជីវិត ។ តើមានករណីអ៊ីចឹងកើតឡើងដែរ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ខ្ញុំសូមឆ្លើយថា គ្មាន ។

**ស៖** តើលោកធ្លាប់បានចូលរួមសម្លាប់អ្នកទោសដោយផ្ទាល់ដែរ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ខ្ញុំមិនដែលបានចូលរួមសម្លាប់អ្នកទោសដោយផ្ទាល់ដែទេ ។

**ស៖** ហើយតើលោកធ្លាប់បានឃើញការសម្លាប់អ្នកទោសដែរ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ខ្ញុំឃើញ ។ ឃើញមួយដងដែលច្បាស់បំផុតដូចខ្ញុំរាយការណ៍ជូនលោកចៅក្រមអ៊ីចឹងនៅពេលម៉ោងប្រាំភ្លឺដែលគេធ្វើឃាត ជ័យ សួន ហើយនិង សួស នៅ ហៅ ឈូក ។ លើកទីពីរ ខ្ញុំទៅជើងឯក ខ្ញុំគេចមុខដែរ មិនទៅឱ្យឃើញសកម្មភាពហ្នឹងច្បាស់នឹងភ្នែកទេ

ឃើញគេបណ្តើរមនុស្សមកស្ទុង ខ្ញុំបែរខ្នងដាក់ ។ នេះមានប៉ុណ្ណឹង មានពីរលើកហ្នឹង ។

[០៩:៤១:៤២]

**ស៖** តើលោកអាចបញ្ជាក់បានទេក្រោយពីការសម្លាប់ប្រព្រឹត្តទៅ បានផ្ទេរយកទៅធ្វើនៅជើងឯក ។ តើនៅមានការសម្លាប់អ្នកទោសនៅក្នុងមន្ទីរស-២១ ជាបន្តទៅទៀតដែរ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! មុនដំបូងខ្ញុំស្មានថាផុតហើយ ផ្ទេរទៅជើងឯកទៅផុតការសម្លាប់នៅបរិវេណវិទ្យាពញ្ញាយ៉ាតហើយនិងជុំវិញក្រៅបរិវេណនោះ ខ្ញុំស្មានថាផុតហើយ ប៉ុន្តែតាមការតទល់ដែលអ្នកគេអនុវត្តបញ្ជាក់ថា នៅៗមានបន្តទៀត ជាពិសេសកុមារ ។ គេកម្ទេចហើយ គេកប់ចោលនៅក្បែរៗនោះកុំឲ្យមាននៅសល់ឃើញក្អេងណាមានរត់ ។

**ស៖** ក្រៅពីកុមារដែលលោកអះអាង តើមានអ្នកណាខ្លះដែលនៅបន្តសម្លាប់នៅមន្ទីរស-២១?

**ឆ៖** ខ្ញុំមិនច្បាស់ទេលោកចៅក្រម ក៏ប៉ុន្តែអាច ។ អ្នកដែលឈឺស្លាប់ហើយនិងអ្នកដែលបូមឈាមប្រហែលជាពួកហ្នឹង ។

**ស៖** ចុះចំពោះអ្នកទោសដែលលោកអះអាងថា ជាអ្នកទោសសំខាន់ដែលលោកធ្លាប់បានលើកឡើងជាញឹកញាប់ដូចជា កុយ ធួន វន វ៉េត ឬក៏ ហ៊ូ នឹម ផ្សេងៗទៀត ។ តើការសម្លាប់អ្នកទាំងនោះសម្លាប់នៅទីណា? ហើយវិធីសម្លាប់យ៉ាងដូចម្តេច?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! មនុស្សសំខាន់ដែលខាងលើគេព្រួយបារម្ភក្រែងស-២១ ដោះលែង ក្រោយពីសម្លាប់ហើយគេឲ្យថតរូប ។ ដូច្នេះ ដើម្បីទុកជាស្លាកស្នាមឲ្យខាងលើឃើញច្រើនតែកាត់បំពង់កសិនបានថត ដូច្នេះប្លែកគឺត្រង់សម្លាប់ហើយថត ។ ដូច្នេះ ពួកនេះប្រហែលសម្លាប់ថ្ងៃហើយពេលស្ងាត់នៅក្នុងដុបមួយក្បែរផ្លូវម៉ៅសេទុងហើយនិងខាងជើងផ្លូវលេខ៦១៣ (សូមទោស) ខ្ញុំមិនចាំទេ មិនដឹងផ្លូវអីទេ គេហៅផ្លូវវត្តមហាមន្ត្រីពីមុនមក ។ នេះពួកសំខាន់ គឺមានថត ហើយដើម្បីថតឲ្យវាច្បាស់ជូនខាងលើទាល់តែមានកាត់បំពង់ក ។ នេះគឺសូមបញ្ជាក់ប៉ុណ្ណេះ ។

**ស៖** ក្រៅពីអ្នកសំខាន់ តើអ្នកទោសណាខ្លះទៀតដែលត្រូវសម្លាប់ហើយថតរូប?

**ឆ៖** ជម្រាបប្រសាសន៍លកចៅក្រម! ក្រៅពីអ្នកទោសសំខាន់មិនមានសម្លាប់អ្នកណាហើយថតរូបទេ ។ ការដែលថតនេះទាល់តែខាងលើបញ្ជា អើ! ថតផង ។ អាហ្នឹង ខ្ញុំក៏ឲ្យគេថត បញ្ជាឲ្យគេថតទៅហើយបញ្ជូនរូបថតទៅខាងលើ ។

**សៈ** ចុះតើក្នុងការដែលលោកអះអាងមិញថា បន្ទាប់ពីទីតាំងសម្លាប់ត្រូវបានផ្លាស់ប្តូរទៅជើងឯក តើមានការសម្លាប់នៅក្នុងមន្ទីរស-២១ ដែរ ប៉ុន្តែជាពិសេសទៅលើកុមារ? អ៊ីចឹង តើលោកអាចបញ្ជាក់បានទេថាវិធីសាស្ត្រក្នុងការសម្លាប់កុមារហ្នឹងគេប្រើវិធីសាស្ត្រណា?

[០៩:៤៥:៣៩]

**ឆៈ** ជម្រាបប្រសាសន៍លោកចៅក្រម! វិធីសាស្ត្រសម្លាប់កុមារ ខ្ញុំមិនច្បាស់ទេ ។ ក៏ប៉ុន្តែ មានរឿងមួយដែលខ្ញុំទទួលដោយស្មោះថា ពិតជាមាន ។ គឺរឿងដែលគេចាប់កុមារ ចាប់ជើងកុមារហើយបោកក្បាលសម្លាប់ទៅនឹងដើមឈើ ។ ដូច្នេះ កុមារអាចចាក់សម្លាប់ ឬក៏អាចវាយសម្លាប់ ឬអាចយ៉ាងម៉េច ជាទូទៅយ៉ាងហ្នឹងមែន ។ ឯចំណែកបោកក្បាល លទ្ធភាពបោកក្បាលនឹងគល់ឈើចៀសមិនរួចទេ ក៏ប៉ុន្តែលទ្ធភាពតែមួយដែលយើងខ្ញុំទទួលថាពិត គឺថារឿងបោះកុមារពីជាន់ទីបីនៃអគារ “A” ចុះមកក្រោម ខ្ញុំមិនជឿទេ មិនមាន ។ នេះលទ្ធភាពក្រុមក្នុងបញ្ហាសម្លាប់កុមារ ។

**សៈ** លោកបានអះអាងមិញដែរថា អ្នកទោសសំខាន់ដែលថ្នាក់លើតម្រូវឲ្យមានការថតរូប ហើយលោកអះអាងថាអាចជាការសម្លាប់ហើយ ហើយដើម្បីថតរូបថាត្រូវអារ-ក ។ ប៉ុន្តែ ក្រៅពីអ្នកទោសសំខាន់ដែលលោកអះអាងហ្នឹង តើមានតែវិធីសម្លាប់មនុស្សដោយ សម្លាប់អ្នកទោសផ្សេងទៀតដោយវិធីអារ-កដែរ?

**ឆៈ** ជម្រាបប្រសាសន៍លោកចៅក្រម! ខ្ញុំជឿថាអារ-កគឺដើម្បីថត ក្រៅពីនោះខ្ញុំមិនជឿថាមានអារ-ក ទេ ។

**សៈ** ដូចលោកធ្លាប់បាននិយាយជាច្រើនលើកច្រើនសាហើយថា អ្នកដែលត្រូវបានចាប់ខ្លួនយកមកមន្ទីរស-២១ នេះគឺជាទូទៅត្រូវបានសួរចម្លើយ ជាពិសេសគោលដៅដែលបង្កើតស-២១ហ្នឹង គឺដើម្បីបានចម្លើយសារភាព ។ តើអ៊ីចឹងលោកអាចបញ្ជាក់បានទេថា តើអ្នកដែលត្រូវចាប់ខ្លួនយកមកមន្ទីរស-២១ សុទ្ធតែបានសួរចម្លើយរួចទើបយកទៅសម្លាប់ ឬក៏មានលក្ខណៈផ្ទុយពីនេះ?

**ឆៈ** ជម្រាបប្រសាសន៍លោកចៅក្រម! មានលក្ខណៈផ្ទុយពីនេះ ។ ឧទាហរណ៍ ពួកបូព៌ាដែលមកចុងក្រោយនេះ រវាងខែធ្នូ ១៩៧៨ អត់មានបានសួរទេ បញ្ជាពី ពូនួន មកឲ្យយកចេញប្រហែលជាបីរយនាក់ ។ ហើយដូចខ្ញុំបានជម្រាបម្តងពីររួចមកហើយថា អង្គភាព៩២០ ដែលគេបញ្ជូនមកដល់ស-២១ នៅថ្ងៃ២៣ ខែវិច្ឆិកា ១៩៧៧ នេះខាងស-២១ អនុវត្តយកចេញភ្លាមតាមបញ្ជាអស់មុនថ្ងៃ២ ធ្នូ ១៩៧៧ ដូច្នេះអត់បានសួរទេ ។ ក្រៅពីនោះជាប្រចាំថ្ងៃអ្នកទោសមកច្រើនពេក ជនរងគ្រោះដែលចូល

មកជាប់នៅនុំងមកច្រើនពេក មានអ្នកខ្លះមិនមានសារសំខាន់អត់បានសួរទេយកចេញទៅហើយ ។ នេះមានករណីដែលផ្ទុយបីប្រភេទនេះ បីរឿងនេះ សូមជម្រាបតាមការចងចាំ ។ ហើយខ្ញុំសរុបបានដោយសង្ខេបប៉ុណ្ណេះ ។ សូមអស់ ។

[០៩:៤៩:៤៧]

**ស៖** តើលោកអាចបញ្ជាក់បានទេថា តើនៅក្នុង-- កន្លងមកអ្នកត្រូវចាប់ខ្លួនយកមកមន្ទីរស-២១ ហ្នឹងគឺមានករណីជាច្រើនអាចឆ្លងកាត់តាមចម្លើយសារភាពអ្នកដែលបានចាប់ខ្លួនមុន ។ ហើយអ្នកចាប់ខ្លួនបន្តបន្ទាប់មកហ្នឹង គឺត្រូវបានយកមកហើយធ្វើទារុណកម្ម ដើម្បីបានចម្លើយសារភាពជាបន្តៗ ហើយអ្នកទាំងនោះ គឺគ្រួសារជាពិសេសប្រពន្ធ ឬក៏កូនដែលអ្នកទាំងក៏ត្រូវបានចាប់ខ្លួនមកជាមួយដែរ ។ អ៊ីចឹងថាតើក្រៅពីជនដែលគេឆ្លើយដាក់នៅក្នុងចម្លើយសារភាព ក្រុមគ្រួសារ ដូចជាប្រពន្ធ ឬកូនហ្នឹង គឺត្រូវបានគេសួរយកចម្លើយដែរ?

**ឆ៖** មានអ្នកខ្លះសំខាន់ ជាស្រីមែនតែគាត់សំខាន់ដែរ ដែលខាងលើគេចាប់អារម្មណ៍ ដូចជាបង វិន ប្រពន្ធ វន វ៉េត អ៊ីចឹង ។ ខ្ញុំឱ្យគេសួរតាមដោយសេចក្តីណែនាំ បង ភាស់ ប្រពន្ធបង ចេង អន រកខ្ញុំឱ្យគេសួរតាមសេចក្តីណែនាំដែរ ។ ក៏ប៉ុន្តែ អ្នកខ្លះក្នុងឋានៈជាប្រពន្ធគេមែន ក៏ប៉ុន្តែ មិនមកជាមួយប្តីទេ គឺគេបំបែក ហើយយកទៅកម្ទេចនៅកន្លែងផ្សេង ដូចជាប្រពន្ធ កង ចាប ហៅ សែ បើតាមខ្ញុំចាំអត់ចូល ស-២១ ទេ ។ នេះគឺខ្ញុំសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

**ស៖** នេះជាការលើកឡើងប្រហែលជាច្រំដែលថា អ្នកដែលត្រូវបានចាប់ខ្លួនចូលមកមន្ទីរស-២១ ហើយត្រូវសួរយកចម្លើយរួចនោះ គឺត្រូវតែកម្ទេច ប៉ុន្តែ យើងបានសង្កេតឃើញថា មានអ្នករស់រានមានជីវិតមួយចំនួនមិនត្រូវបានកម្ទេចទេ ក្រោយពីបានសួរយកចម្លើយ តើលោកអាចពន្យល់បានទេ អំពីភាពផ្ទុយគ្នានេះ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! អ្នកដែលសួរចម្លើយរួចហើយអត់បានកម្ទេចមានពីរប្រភេទ ។ ប្រភេទទីមួយ ដែលខាងលើគេអនុញ្ញាតទុកជាទោសរួចជីវិត បានន័យថា ស-២១ អត់មានសិទ្ធិសម្លាប់ទេ បើគ្មានសេចក្តីណែនាំមកថ្មី ។ ពួកនេះមានប្រាំមួយនាក់ គឺពួកគូរឆ្លាក់នេះប្រាំនាក់ ហើយនិងទន្តពេទ្យ ឌី ផុន នេះម្នាក់ ទាំងអស់ប្រាំមួយ ។ ក្រៅពីនោះ យើងខ្ញុំមានទុកសម្រាប់ជួបការងារនៅហ្នឹងមន្ទីរស-២១ ច្រើនដែរ ។ សរុបមក បើតាមខ្ញុំ-- ឥឡូវភ្លេចតួលេខច្បាស់លាស់ហើយ ប្រហែលជាដប់ប្រាំនាក់ រួមទាំងពួកគូរឆ្លាក់នឹងផង ។ នេះទុកប្រើទេក្នុងឋានៈយើងខ្ញុំទទួលខុសត្រូវថ្ងៃណាខាងគេ

បញ្ជាថា កម្ទេច ត្រូវតែយកទៅកម្ទេច ។ នេះមានប្រហែលប្រាំបួននាក់ មើល១ប្រហែលជា-- មាន១ពួកនោះ ខ្ញុំអត់បានរាប់ចំនួនទេ សូមទោស១មិនជូនចំនួនពេលនេះបានទេ ។ ប៉ុន្តែ មិនលើសដល់ទៅដប់ប្រាំ -ម្ភៃអីទេ ប៉ុននុ៎ង ។ ដូច្នេះ ពួកអ្នកដែលនៅរស់រានមានជីវិត ហើយដែលយើងខ្ញុំយកមកប្រើជាបណ្ដោះអាសន្ននេះនៅហ្នឹង ក្នុងអង្គសវនាការយើងហ្នឹងមានមួយ គឺលោក ជុំ ម៉ី ។ នេះគឺប្រភេទហ្នឹងខ្ញុំសូមបញ្ចប់ប៉ុណ្ណេះ ។

[០៩:៥៣:៥៥]

**ស៖** តើលោកមានសិទ្ធិក្នុងការសម្រេចថា ត្រូវទុកអ្នកទោសណាដើម្បីប្រើប្រាស់នៅក្នុងស-២១ នេះដោយផ្ទាល់ខ្លួន ឬក៏យ៉ាងម៉េច?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! នៅស-២១ ហើយក៏ប្រហែលជាអាចនៅក្នុងមន្ទីរសន្តិសុខទូទាំងប្រទេស គណៈកម្មាធិការមន្ទីរវាមានសិទ្ធិសម្រេចទុកមនុស្សមួយចំនួនសម្រាប់ប្រើ យើងហៅពាក្យ ប្រើទៅចុះ សម្រាប់ជួយការងារ ។ ក៏ប៉ុន្តែ យើងទុកគេប្រើ យើងយកអាយុជីវិតយើងទៅជំនួសគេហើយបើថ្លោះធ្លោយរត់រួច ឬបាតុកម្មបាន អីបាន គឺគណៈកម្មាធិការស-២១ ទទួលខុសត្រូវចុះចំពោះមុខបក្ស ។ នេះមិននិយាយពីសិទ្ធិទេ យើងនិយាយថា សិទ្ធិក៏បានដែរ គឺក្នុងក្របខ័ណ្ឌបែបនេះ ។ សូមបញ្ជាក់ជូនដោយស្មោះ ។

**ស៖** អ៊ីចឹង បើខ្ញុំស្ដាប់មិនច្រឡំទេ អ្នកដែលនៅរស់រានមានជីវិតហ្នឹងមិនមែនបានន័យថា ត្រូវដោះលែងឲ្យរួចផុតពីការសម្លាប់ទេ គឺថាគ្រាន់តែទុកប្រើប្រាស់ជាប្រយោជន៍របស់មន្ទីរស-២១ ជាលក្ខណៈបណ្ដោះអាសន្ន ហើយនៅពេលណាមួយនឹងត្រូវបានយកទៅសម្លាប់ដូចអ្នកទោសដទៃទៀតដែរ អ៊ីចឹងមែនទេ?

[០៩:៥៥:២៧]

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ពិតជាអ៊ីចឹងមែន ។

**ស៖** លោកបញ្ជាក់ហើយថា នៅក្រោយថ្ងៃ ៧ មករា ឆ្នាំ១៩៧៩ ហើយក្រោយពេលដែលគេបានរកឃើញមន្ទីរស-២១ នោះ គឺក្នុងគេបានប្រទះឃើញសាកសពជនរងគ្រោះមួយចំនួន ដូចជាមាននៅក្នុងឯកសារនៅរហូតដល់សព្វថ្ងៃមានខ្លះ ត្រូវបានសម្លាប់ដោយជាប់ខ្នោះនៅលើគ្រែអីជាដើមហ្នឹង តើលោកអាចបញ្ជាក់បានទេ? តើសាកសពទាំងនោះត្រូវបានគេសម្លាប់នៅពេលណា? ហើយអ្នកណាជាអ្នកសម្លាប់? បញ្ជាឲ្យសម្លាប់?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! យើងខ្ញុំរត់ចេញទៅនៅម៉ោងពីររសៀល ថ្ងៃ៧ មករា ១៩៧៩ នៅពេលដែលយើងខ្ញុំរត់ចេញទៅ មានសាកសពពួកយុទ្ធជន យ-៨ បួននាក់នៅលើគ្រែ ដែលអ្នកសួរម្នាក់ឈ្មោះ មិត្តណាន គាត់អនុវត្តតាមបញ្ជាណែនាំពីមុនរបស់គណៈកម្មាធិការមន្ទីរស-២១ ថាបើមានការអីត្រូវកម្ទេច ។ ដូច្នេះ បួននាក់ សម្លាប់នៅលើគ្រែក្នុងមួយបន្ទប់ បើតាមខ្ញុំចាំមានគ្រែមួយដាច់ដោយឡែកពីគេ ដាច់ដោយឡែកពីគ្នា ។ នេះសូមបញ្ជាក់ជូនប៉ុណ្ណេះ ពិតជាមាន៧បួននាក់ អត់លើសទេ ។

[០៩:៥៧:២៣]

**ស៖** លោកអាចបញ្ជាក់បានទេ តើវិធីសាស្ត្រក្នុងការសម្លាប់អ្នកទោសនៅមន្ទីរស-២១ លោកមានបានបែងចែកវិធីសាស្ត្រផ្សេងគ្នាក្នុងការសម្លាប់អ្នកទោស ដែលជាជនបរទេស ឬក៏អាណិកជនដែរ?

**ឆ៖** អរគុណ ខ្ញុំមិនបែងចែកទេ ។ ក៏ប៉ុន្តែ បញ្ជាមកពីលើដាច់ណាត់បញ្ជានេះ ពួកបស្ចិមប្រទេសបួននាក់ សម្លាប់ហើយត្រូវតែដុតសាកសពឲ្យអស់កុំឲ្យសល់ ។ នេះជាបញ្ជាដាច់ណាត់ ។

**ចៅក្រម ធូ មណី៖**

សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ ។

**ប្រធានអង្គជំនុំ៖**

អស់លោក លោកស្រីចៅក្រម មានសំណួរអ្វីសួរដល់ជនជាប់ចោទរូបនេះទេ?

សូមអញ្ជើញលោកស្រីចៅក្រម ។

**សួរដោយចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

**ស៖** សូមអរគុណលោកប្រធាន កាំង ហ្គេកអ៊ាវ លោកបាននិយាយអំពីការផ្តល់អំណាចក្នុងការសម្លាប់ដែលជាសេចក្តីសម្រេចរបស់គណៈស-២១ តើលោកអាចប្រាប់បានទេនរណាខ្លះជាសមាជិកនៅក្នុងគណៈ ស-២១ នោះ?

**ឆ៖** ក្នុងគណៈកម្មាធិការស-២១ វាមានតែគ្នាបីនាក់ទេ ។ ទីមួយគឺ ខ្ញុំ ទីពីរ គឺមិត្តហ៊ី ឈ្មោះដើម ខឹម វ៉ាក ហើយទីបី គឺមិត្តហ៊ុយ ។ ក្នុងចំណោមបីនាក់នេះ មិត្តហ៊ុយ, នុន ហ៊ុយ ដាច់ដោយឡែកពីគេនៅទទួលភារៈខាងព្រៃសទេ ។ នេះខ្ញុំសូមបញ្ជាក់ជូនប៉ុណ្ណេះដោយខ្លី ។

**ស៖** ក្រៅពីបញ្ជាឲ្យសម្លាប់អ្នកទោស តើគណៈនេះមានភារកិច្ចដទៃទៀតដែរឬទេ?

**ឆ៖** គណៈនេះភារកិច្ចសំខាន់របស់វាមានដាច់ដោយឡែកតាមមជ្ឈមណ្ឌលប្រតិបត្តិការ ។ នៅ ស-២១ មជ្ឈមណ្ឌលភ្នំពេញ ដែលឥឡូវនេះគេធ្លាប់ស្គាល់ជាទូទៅថា គុកទួលស្លែងនោះ ការងាររបស់វាសំខាន់ គឺឃុំឃាំងមនុស្សដែលអចិន្ត្រៃយ៍គេបញ្ជូនមកមួយរយៈ ដើម្បីធ្វើទារុណកម្ម ហើយយកចម្លើយរួចហើយកទៅកម្ទេច ។ នេះជាភារកិច្ចស្នូល ។ ដើម្បីភារកិច្ចស្នូលនេះ ដំណើរការបាន វាមានភារកិច្ចផ្សេងទៀតដែរ ដូចជាកងពិសេស វាមានភារកិច្ចការពារពីក្រៅ ចាំទទួលមនុស្សដែលគេបញ្ជូនមក ហើយចាំនាំមនុស្សពីភ្នំពេញទៅជើងឯក ។ ហើយភារកិច្ចកងការពារ វាការពារកុំឱ្យជនរងគ្រោះដែលយើងដាក់ឃុំឃាំងនោះរត់រួច ឬតដៃបាន ឬឡូឡាកើត វាមានភារកិច្ចអ៊ីចឹង ។ នេះភារកិច្ចបុគ្គលិកស-២១ គណៈកម្មាធិការ ស-២១ នៃមជ្ឈមណ្ឌលភ្នំពេញដែលយើងធ្លាប់ស្គាល់ហៅថា គុកទួលស្លែង ។ នេះសូមបញ្ជាក់ជូនលោកជំទាវ ប៉ុណ្ណេះ ។

[១០:០១:៥៦]

**ស៖** តើគណៈ ស-២១ នេះជួបប្រជុំគ្នាជាញឹកញាប់ដែរ ឬទេ?

**ឆ៖** ជម្រាប់ប្រសាស៍លោកជំទាវ! គណៈកម្មាធិការស-២១ពីរនាក់នៅមជ្ឈមណ្ឌលជួបគ្នាមួយថ្ងៃជួនអីពីរបីដងក៏មានដែរ តាមសេចក្ដីត្រូវការនៃការងារដើម្បីពិគ្រោះគ្នា ។ ឯចំណែក ពីខាងព្រៃសបើកាលណាខ្ញុំមានការងារអីឆ្ងល់ចង់ដឹង ចង់យល់ ចង់ឱ្យគេរាយការណ៍ ឱ្យគេតេអូពីភ្នំពេញទៅហៅមិត្តហ៊ុយ មក ដូច្នេះញឹកញាប់ ។ ជម្រាបប្រសាសន៍ប៉ុណ្ណេះ ។

**ស៖** តើលោករក្សានៅកំណត់ហេតុក្នុងនាមលោកជាសមាជិករបស់គណៈស-២១ ដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ខ្ញុំសូមលោកជំទាវមេត្តាពន្យល់ពាក្យថា កំណត់ហេតុក្នុងនាមជាសមាជិកស-២១ ខ្ញុំមិនយល់ទេ ឆ្លើយមិនទាន់កើតទេ ។ សូមទោស ។

**ស៖** នៅពេលដែលគណៈស-២១ ចេញសេចក្ដីសម្រេចចិត្តអ្វីមួយ ឧទាហរណ៍ថា ការចេញសេចក្ដីសម្រេចសម្លាប់អ្នកទោសមួយក្រុមណានោះ ក្នុងនាមលោកជាប្រធានស-២១ តើលោកសរសេរនៅកំណត់ហេតុនូវសេចក្ដីសម្រេចរបស់គណៈស-២១ នេះដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! កំណត់ហេតុនេះអង្គប្រជុំគណៈកម្មាធិការស-២១ គ្មានទេ យើងខ្ញុំមិនដែលបានធ្វើទេ ។ សូមរាយការណ៍ជូនអំពីកិច្ចដំណើរការដែលយើងខ្ញុំធ្លាប់ធ្វើ ។ ក្នុងចំណោមគ្នាខ្ញុំបីនាក់នេះ សម្រេចកិច្ចការអីៗមិនដែលទាំងចារទុកផង ។ បើសិនជាខ្ញុំចង់បញ្ជាទៅខាងក្រោមក៏ដោយ ក៏ត្រូវបញ្ជាតាម មិត្តហ៊ា នេះនៅភ្នំពេញ ។ បើសិនជាខ្ញុំចង់បញ្ជាអីទៅខាងស្រែនោះ ខ្ញុំត្រូវបញ្ជា

តាមមិត្តហ៊ុយ ឬឲ្យ មិត្តហ៊ី បញ្ជាតាម មិត្តហ៊ុយ ទៅទៀត ។ នេះវាមាន។ ក៏ប៉ុន្តែ ឲ្យវាមានកំណត់ហេតុចារថា ថ្ងៃនេះខ្ញុំបានបញ្ជាយ៉ាងនេះ អត់មានទេ។ ដោយឡែកនៅពេលណាដែលខ្ញុំប្រើបង ម៉មណៃ ក្នុងឋានៈជាជំនួយការរបស់ខ្ញុំ ខ្ញុំមានចារបញ្ជាខ្ញុំនៅហ្នឹងៗ ក្រដាសស្នាមមួយច្បាស់លាស់ ព្រោះគាត់មិនមែនជាគណៈគាត់មិនអាចប្រើសម្ដីគាត់ទៅបញ្ជាគេបានទេ ។ នេះសូមជម្រាបការអនុវត្តពិតជាក់ស្ដែងយ៉ាងនេះ ។

ដូច្នេះ សរុបមកកំណត់ហេតុនៃអង្គប្រជុំគណៈកម្មាធិការស-២១ គ្មានទេ ។ មានសល់តែកិច្ចបញ្ជារបស់ខ្ញុំទៅលើជំនួយការ ឲ្យជំនួយការហ្នឹងនាំពាក្យខ្ញុំទៅចាត់ចែងឲ្យគេធ្វើ ។ សូមបញ្ចាក់ខ្លីប៉ុណ្ណេះ។

[១០:០៥:១០]

**សៈ** លោកបានរៀបរាប់ថា បន្ទាប់ពីមានព្រឹត្តិការណ៍មួយ ដែល ហ៊ី បានសម្លាប់អ្នកទោសម្នាក់មុនពេលដែលចម្លើយនោះត្រូវបានចប់ ។ ហើយតើការបញ្ជាឲ្យសម្លាប់ ដែល ហ៊ី បានធ្វើហ្នឹង ត្រូវតែត្រឡប់ ត្រូវទៅរាយការណ៍មកលោកសិន ដើម្បីឲ្យលោកបានដឹងថា ចម្លើយសារភាពនោះ ត្រូវបានបញ្ចប់ហើយហើយ ។ តើនេះជាការលើកឡើងត្រឹមត្រូវដែរឬទេ?

**ឆៈ** ជម្រាបប្រសាសន៍លោកជំទាវ! គឺត្រឹមត្រូវហើយ អ្នកណាដែលសួរចប់ ហ៊ី គេមកប្រាប់ខ្ញុំថា អានេះសួរចប់ហើយ ខ្ញុំថា “អឺ! បើចប់ហើយអនុវត្តទៅ” ។

**សៈ** ដូច្នេះតាមដំណើរការគឺលោកបានបញ្ជាការសម្លាប់មនុស្សជាងមួយម៉ឺនពីពាន់នាក់ តើត្រឹមត្រូវដែរឬទេ?

**ឆៈ** ជម្រាបប្រសាសន៍លោកជំទាវ! ខ្ញុំសូមនិយាយបកទៅក្រោយវិញចុះ ខ្ញុំមិនបដិសេធអំពីបញ្ជាសម្លាប់ទេ ។ ក៏ប៉ុន្តែ ជាគោលការណ៍ មាគ៌ាដែលគេសង្កត់ពីលើមក គេប្រគល់មកឲ្យស-២១ ហើយ ២១ ត្រូវតែសម្លាប់ ។ ដូច្នេះ ខ្ញុំសូមឆ្លើយថា ក្នុងកិច្ចអនុវត្តគោលនយោបាយរបស់បក្សទៅលើមនុស្សជាងមួយម៉ឺននាក់នេះ គឺពិតជាស្ថិតនៅក្រោមអំណាចរបស់ខ្ញុំ ។

**សៈ** គណៈស-២១ មានការទទួលខុសត្រូវដ៏ច្រើន ដូចដែលលោកទើបតែបានពិពណ៌នាអម្បាញ់មិញនេះ ។ ដូច្នេះ តើវាមានន័យថា លោកបានដឹងយ៉ាងច្បាស់នូវកិច្ចការប្រតិបត្តិការប្រចាំថ្ងៃ នូវអ្វីដែលបានកើតឡើងនៅស-២១ តើត្រឹមត្រូវដែរឬទេ?

**ឆៈ** ជម្រាបប្រសាសន៍លោកជំទាវ! ប្រាកដជាត្រឹមត្រូវហើយ ។

**ស៖** លោកបាននិយាយថា ដំបូង ហ៊ា ដើម្បីកុំឲ្យនៅសល់ការងារច្រើនពេក ទាក់ទងទៅនឹងការសម្លាប់នោះ តើលោកមានន័យថាម៉េចដែរ? វាអាចជាបញ្ហានៃការបកប្រែ ប៉ុន្តែ តើលោកអាចពន្យល់ពីចំណុចនេះបានដែរឬទេ?

[១០:០៨:០៥]

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ខ្ញុំសូមត្រឡប់ទៅរឿងដើមវិញ ដូចជាវាច្រំដែលពេក ក៏ប៉ុន្តែសូមត្រឡប់មួយម៉ាត់ទៀតទៅចុះ ។ មនុស្សដែលគេបញ្ជូនមកស-២១ ត្រូវតែចាត់ចែងឲ្យស្រួល ធ្វើម៉េចកម្មេចរបស់គេឲ្យបាន កុំឲ្យរត់រួច ។ ដូច្នេះ ដើម្បីកុំឲ្យគរមនុស្សសល់ច្រើនពេក បើកាលណាគរសល់ច្រើនពេក ម្យ៉ាងវាលទ្ធភាពក្នុងរឿងគេតដែក៏មាន ក្នុងរឿងគេស្រែកឡូឡាក៏មាន ហើយនិងក្នុងរឿងចិញ្ចឹមបីបាច់ថែរក្សាក៏វាចុះបាយអង្ករច្រើនដែរ ។ ដូច្នេះ ក្នុងឋានៈគេជាអ្នកគិតគូរកិច្ចការចាត់ចែងប្រចាំថ្ងៃ គេសម្រេចយកមនុស្សចេញទៅ ដើម្បីកុំឲ្យវាគរមនុស្សនោះច្រើនពេក ចំនួនមនុស្សសល់ច្រើនពេកនាំឲ្យមានការពិបាក ។ អំមិញនេះខ្ញុំនិយាយនេះសំដៅយ៉ាងនេះឯង ។ សូមបញ្ជាក់ជូនលោកជំទាវប៉ុណ្ណេះ ។

**ស៖** សូមអរគុណ ។ លោកក៏បាននិយាយអំពីកុមារមួយចំនួនដែលត្រូវបានកប់នៅខាងក្នុងមន្ទីរបរិវេណស-២១ ។ តើកុមារអស់ទាំងហ្នឹងជាកុមារដែលនៅក្មេងៗ ឬក៏ជាទារកដែលមានអាយុក្រោយប្រាំឆ្នាំដែលមកជាមួយម្ដាយរបស់ពួកគេនោះឬ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ខ្ញុំមិនបានឃើញពិតទេ ក៏ប៉ុន្តែ ខ្ញុំជឿថាលទ្ធភាពច្រើនណាស់ គឺពួកដែលមានអាយុក្រោមប្រាំឆ្នាំ ។ ឯចំណែក អ្នកដែលលើប្រាំឆ្នាំប្រហែលជាបញ្ជូនទៅជើងឯកងណោះទេ ។

**ស៖** លោកបានប្រកែកថា មានក្មេងម្នាក់ត្រូវបានគេបោះពីលើមកតាមជណ្ដើរ ហើយបានស្លាប់ទៅ ។ ហេតុអ្វីបានជាលោកធ្វើការប្រកែកចំពោះការលើកឡើងបែបនេះ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! មិនមែនបោះតាមជណ្ដើរទេ បោះពីល្វែងមក តាមអាកាសស្រឡះ ធ្លាក់មកងាប់ ។ បានជាខ្ញុំប្រកែក ពីព្រោះការធ្វើឃាតមនុស្សចៀសវាងកុំឲ្យអ្នកទោសផ្សេងទៀតដឹង ។ គោលការណ៍ធ្វើការងាររបស់មន្ទីរនគរបាលគ្រប់តែកន្លែងមិនឲ្យបែកការណ៍ទេ រឿងសម្លាប់ក៏មិនឲ្យបែកការណ៍ដែរ ។ ដូច្នេះ បើបោះមនុស្សពីលើដំបូលមក កម្ពស់បីជាន់ វាខុសនឹងគោលការណ៍ណែនាំទាំងស្រុង ។ ដូច្នេះ ការខុសនឹងគោលការណ៍ណែនាំទាំងស្រុងពិតជាដឹងដល់ខ្ញុំ ។ ហើយ

តែដឹងដល់ខ្ញុំហើយ ល្មើសបែបនេះខ្ញុំអត់ទុកទេ វាយការណ៍សុំមេដកហើយ ។ ដូច្នេះ ហើយបានជាខ្ញុំអះអាងថាគ្មាន ។ សូមបញ្ជាក់ជូនលោកជំទាវប៉ុណ្ណេះ ។

**ស៖** តើកុមារទាំងអស់ដែលមានអាយុក្មេងៗ ដែលបានមកជាមួយម្តាយរបស់ពួកគេហ្នឹងស្លាប់ដោយប្រភេទណា?

[១០:១១:៣៥]

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ខ្ញុំសូមសរុបមួយមាត់ ស្លាប់ដោយគេសម្លាប់ មិនមែនស្លាប់ដោយអត់បាយ ឬស្លាប់ដោយអីទេ គឺស្លាប់ដោយគេសម្លាប់ ។ ក៏ប៉ុន្តែ សម្លាប់នេះអាចដូចខ្ញុំបានជម្រាបលោកជំទាវអ៊ីចឹង ជួនអីគេបោកក្បាលទៅបើសិនជាយកទៅដល់ជើងឯក ។ រួចបើសិនជានៅភ្នំពេញនេះ សម្លាប់ស្ងាត់ៗ ជួនអីអាចគេវៃដូចមនុស្សធំដែរ ។ នេះគឺខ្ញុំសូមបញ្ជាក់ជូនប៉ុណ្ណេះ ឲ្យខ្ញុំឃើញជាក់ស្តែងច្បាស់លាស់នឹងភ្នែកអត់មានទេ ឬក៏មានណែនាំពីខ្ញុំទៅអត់មានទេ ។ ណែនាំពីខ្ញុំទៅគឺកុមារដែលមកជាមួយឪពុកម្តាយអត់សល់ទេ ត្រូវតែកម្ទេច ។ នេះជាគោលការណ៍ដែលកំណត់ពីលើមក ។ ហើយខ្ញុំណែនាំចុះទៅក្រោមទៀត ។

**ស៖** ហើយជាពិសេសទៀតនោះ ក្មេងដែលអាយុនៅក្មេងៗគឺត្រូវបានគេ គេត្រូវបានបំបែកពីម្តាយ ឬក៏ឪពុករបស់គេ នៅពេលដែលគេមកដល់ ស-២១ ភ្លាម តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ត្រឹមត្រូវហើយ អត់នៅបានយូរទេ យ៉ាងច្រើនតែមួយថ្ងៃ។

**ស៖** ហើយដោយសារលោកមិនមានបញ្ហា ឬក៏បារម្ភអំពីការស្លាប់របស់កុមារ ឬក៏ដែលកុមារនោះត្រូវបានសម្លាប់នោះ ដូច្នេះ គឺលោកមិនបានដឹងថា តើកុមារអាយុក្មេងៗអស់ទាំងហ្នឹង តើត្រូវបានស្លាប់អស់ប៉ុន្មាននាក់ទេ? តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ត្រឹមត្រូវៗប្រាកដជាខ្ញុំអត់បានដឹងមែន ។ ខុសនោះវាខុសហើយ ប៉ុន្តែឲ្យដឹងគឺមិនដឹងទេចំនួននោះ ។

**ស៖** លោកបានសង្កត់បញ្ជាក់ថា លោកមិនបានដឹងលម្អិតអំពីការធ្វើទារុណកម្ម និងព័ត៌មានលម្អិតអំពីការសម្លាប់ទេ តាមពិតគឺលោកបានចៀសវាងថាលោកបានចូលរួម ហើយគឺលោកមិនបានចូលរួមនៅក្នុងវគ្គ ឬក៏ការធ្វើទារុណកម្ម ឬក៏បានទៅទីកន្លែងដែលអ្នកទោសត្រូវបានគេសម្លាប់នោះទេ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ត្រឹមត្រូវហើយ ។

**ស៖** ដូច្នេះ វិធីដែលអ្នកទោសត្រូវបានគេសម្លាប់នោះ គឺលោកមិនបានដឹងច្បាស់ទេ តើមែនទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ ខ្ញុំមិនបានដឹងច្បាស់ទេ ក៏ប៉ុន្តែជារួមខ្ញុំ-- បញ្ហាវា១-- គោលការណ៍វានៅក្នុងខ្ញុំ ។ ក៏ប៉ុន្តែ ក្នុងការឲ្យច្បាស់មិនឃើញច្បាស់ទេ មិនឃើញច្បាស់ ។

[១០:១៤:៤០]

**ស៖** អ៊ីចឹងខ្ញុំឆ្ងល់ថា ហេតុអ្វីបានជាលោកនិយាយថា មិនមានប្រើសត្វដែលមានពិសឲ្យខាំអ្នកទោសនោះទេ ហេតុអ្វីបានលោកអាចប៊ានអះអាងបានដូច្នេះ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! នេះមិនមែនជាបទបញ្ជារបស់ខ្ញុំ ហើយក៏មិនមែនជាបទបញ្ជាពីលើមក អនុញ្ញាតឲ្យធ្វើទារុណកម្មបែបនេះ ។ ទារុណកម្មបែបនេះ គឺសម្លាប់បែបនេះ ខ្ញុំមិនដែលបានបញ្ជាទេ ។

**ស៖** តើលោកអាចប្រាប់យើងខ្ញុំបានទេ តើលោកមានបានដឹងថាមានស្ត្រីដែលមានផ្ទៃពោះច្រើនទេ ដែលត្រូវបានឃុំខ្លួននៅស-២១ នោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ខ្ញុំអត់បានដឹងព័ត៌មាននេះទេ ។ នេះជម្រាបដោយត្រង់ ។

**ស៖** តើលោកមានបានដឹងថា មានស្ត្រីជាអ្នកទោសធ្លាប់មានសម្រាលកូននៅមន្ទីរ ស-២១ ដែរឬទេ?

**ឆ៖** មិនដឹងទេ សូមទោសខ្ញុំនិយាយអំមិញ វាហួសបន្តិច ។ ក្មួយ នួន ជា ឈ្មោះ នាង ឡៃ តារាហៅថន នេះ ចូលមកដល់ ស-២១ មានទម្ងន់ ហើយទៅសម្រាកកូនដូចនៅពេលរត់ជាមួយនឹងខ្ញុំ ។ ហ្នឹងមានមួយ នេះខ្ញុំចាំ ។ ដូច្នេះ ការសម្រាលកូននៅក្នុងបរិវេណមន្ទីរស-២១ មជ្ឈមណ្ឌលភ្នំពេញដែលយើងក្រោយមកហៅថាគុកទួលស្លែងនេះ ខ្ញុំមិនចាំថាមាន ។ សូមអស់យោបល់ប៉ុណ្ណោះ ។

**ស៖** កាលពីម្សិលមិញលោកបាននិយាយថា ប្រហែលជាមានអ្នកទោសមួយរយនាក់ត្រូវបានស្លាប់ដោយសារតែការបូមឈាមចេញពីខ្លួនរបស់ពួកគេ តើលោកអាចប្រាប់យើងខ្ញុំបានទេ ថាតើនៅពេលណាដែលសេចក្ដីសម្រេចក្នុងការបូមឈាមអ្នកទោសនោះត្រូវបានធ្វើឡើង?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! រឿងនេះខ្ញុំបានជម្រាបម្សិលមិញហើយ វាជាកិច្ចអនុវត្តបន្តពី ណាត មក ។ ហើយម្សិលមិញក៏ខ្ញុំបានបញ្ជាក់ដែរ វាអាចចប់នៅពេលដែលខាងពេទ្យ៩៨ ក៏សម្រិតសម្រាំងមិត្ត តៃ ឈ្មោះដើម ម៉ឹង សំណាង ប្រធានគណៈកម្មាធិការពេទ្យ ៩៨ ។ ហើយខាង ស-២១ នោះ ក៏បានសម្រិតសម្រាំង មិត្តទ្រី ។ ដូច្នេះវាអាចចប់នៅពេលនោះ ។

**សៈ** តើលោកធ្លាប់ដែលត្រូវបានទទួលបញ្ជាពីថ្នាក់លើ ឲ្យចាប់ផ្តើមដំណើរការក្នុងការបូមឈាមពីអ្នកទោសដែរឬទេ? បើសិនជាមានមែននោះ តើលោកដែលធ្លាប់ចេញបញ្ជាឲ្យបញ្ឈប់ការអនុវត្តបែបនេះដែរឬទេ?

[១០:១៨:១១]

**ឆៈ** ជម្រាបប្រសាសន៍លោកជំទាវ! ការបញ្ជាឲ្យបូមឈាមនេះ ដូចខ្ញុំបានបញ្ជាក់អម្បាញ់មិញអ៊ីចឹង បញ្ជានេះវាមកពីលើ ហើយថិរវេលារបស់វាចាប់តាំងពីខ្ញុំចូលទៅកាន់កាប់ជាអនុប្រធានម្តេះ ហើយក៏បន្តមក ។ ដល់ក្រោយមកខ្ញុំមានការបញ្ជាទៅខាងក្រោម មិនត្រឹមតែបញ្ជាទេ គឺជួយជ្រើសរើសមនុស្សតាមសំណូមពរខាងលើ កុំឲ្យយកឈាមនេះទៅបញ្ចូលឲ្យយុទ្ធជនទៅវាមានជំងឺដល់យុទ្ធជនទៀត ។ នេះមានស៊ីញ៉េមានអីរបស់ខ្ញុំចារនៅក្នុងលិខិតបញ្ជា ។ ដូច្នេះ ទោះបីក្នុងរយៈកាលស៊ើបអង្កេតខ្ញុំមិនបានឃើញឯកសារនេះទាំងអស់ក៏ដោយ ក៏ខ្ញុំជឿថាចំនួនប្រហែលជាមួយរយ ។ ដូច្នេះ នៅពេលបញ្ឈប់អត់មានបញ្ជាពីខាងលើ ហើយអត់មានបញ្ជាពីខ្ញុំទេ ឈប់គឺចប់បណ្តោយ បើតាមខ្ញុំចាំគឺនៅពេលដែលខាងស-២១ សម្រិតសម្រាំង មិត្តទ្រី ។ នេះខ្ញុំសូមបញ្ចប់ប៉ុណ្ណេះ ។

**សៈ** សូមអរគុណ ។ លោកបានលើកឡើងថា អ្នកទោសបរទេសបួននាក់ លោកបានបញ្ជាឲ្យសម្លាប់អ្នកទាំងបួននាក់នោះដោយដុត ហើយគឺការបញ្ជានេះគឺមកពីថ្នាក់លើ ។ ពីរថ្ងៃមុននេះគឺយើងបានមើលបញ្ជីមួយដែលមានអ្នកទោសមកពីបស្ចិមប្រទេសយ៉ាងច្រើន ហើយប្រសិនបើអង្គជំនុំជម្រះសាលាដំបូងជឿនោះ គឺយើងឃើញថាមានអ្នកទោសបរទេសមកពីបស្ចិមប្រទេសហ្នឹង ច្រើនជាងបួនដែលឃុំនៅស-២១ ។ ហើយតើវាត្រឹមត្រូវដែរឬទេ ថាអ្នកទាំងអស់នោះត្រូវបានសម្លាប់ក្នុងវិធីដូចគ្នា?

**ឆៈ** ជម្រាបប្រសាសន៍លោកជំទាវ! នៅក្នុងពេលដែលខ្ញុំធ្វើជាប្រធាន ហើយតាំងពីអនុប្រធានម្តេះ ខ្ញុំមិនដែលឃើញជនបស្ចិមប្រទេសឲ្យលើសពីបួននេះទេ ។ អត់ដែលឃើញឲ្យលើសពីបួននាក់នេះទេ នេះសូមបញ្ជាក់មួយរឿង ។ មួយរឿងជនបស្ចិមប្រទេសទាំងបួននាក់នេះ ចូលមកដល់កម្ពុជាមួយលើកពីរនាក់ មួយលើកទៀតពីរនាក់ទៀត ។ ដូច្នេះ ការបញ្ជូនយកទៅកម្ទេចមួយលើកពីរ មួយលើកពីរដូចគ្នា ។ សូមបញ្ជាក់ឲ្យច្បាស់នៅពេលនេះថា ជនបស្ចិមប្រទេសទាំងបួននាក់នេះមិនមែនដុតទាំងរស់ទេ គឺពិតជាគេសម្លាប់ហើយ បានគេដុតសាកសព ប៉ុន្តែ ដុតឲ្យទាល់តែសុសឲ្យអស់ ។ នេះគឺសូមបញ្ជាក់ប៉ុណ្ណេះ ។

**សៈ** តើគេសម្លាប់អ្នកទាំងអស់នោះនៅឯណា អ្នកទាំងបួននុង?

**ឆ៖** អ្នកទាំងបួននេះ គេកម្ទេចនៅខាងកើតផ្លូវ-- ខ្ញុំហៅបណ្ដោះអាសន្នទៅចុះ ខុសសូមអនុញ្ញាតកែក្រោយ ខាងកើតផ្លូវ៦១៣ ហើយនិងខាងជើងផ្លូវម៉ៅសេទុង ។ កាលនោះវាជាបឹង ហើយនិងកូនព្រៃស្បាតទាបៗនៅកន្លែងនុំង ។

**ស៖** នៅក្នុងបញ្ជីអ្នកទោសបរទេស ដែលយើងបានពិនិត្យកាលពីប៉ុន្មានថ្ងៃមុន យើងឃើញមានចំនួនច្រើនណាស់អ្នកទោសបរទេសមកពីប្រទេសផ្សេងៗ ដូចជាមកពីប្រទេសថៃ ។ ថាតើអ្នកទោសបរទេសផ្សេងទៀតនោះ ត្រូវបានគេសម្លាប់តាមរបៀបណា?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! អ្នកបរទេសថៃ អ្នកបរទេសឡាវ អ្នកបរទេសមកពីវៀតណាម សម្លាប់ដូចតែខ្មែរធម្មតាទេ ។ អត់មានអីប្លែកទេ ដោយឡែកតែពួកបស្ចិមប្រទេស ដែល ប៉ុល ពត ហើយក៏ប្រហែលជា ប៉ុល ពត មិនមែនពូ នួន ទេ ផ្ទាល់ទេ ដែលបញ្ជាឲ្យដុតកុំឲ្យសល់ ។ គាត់និយាយ ពូនួន គាត់និយាយច្បាស់អ៊ីចឹង គាត់ថា យើងមិនមែនគុយបាទេ ទុកសាកសពពួកហ្នឹងដូរ *ប៊ូដូហ្សេរ* ម៉េច? អត់ទេ ដុតឲ្យអស់កុំឲ្យឃើញដាន ។ នេះប្លែកគេមានតែពួកបស្ចិមប្រទេសបួននាក់ហ្នឹង មានអង់គ្លេសម្នាក់ ហើយក្រុមគ្រួសារ*អាមីល* លោកម្នាក់ហ្នឹងឈ្មោះ *អាមីល* ត្រកូល *អាមីល* ក៏ត្រូវបានសម្លាប់ហើយដុតខ្ទេចអ៊ីចឹងដែរ ។ អ្ហេ! ក្រៅពីនេះខ្ញុំអត់ចាំឈ្មោះទេ ព្រោះ*អាមីល* ដែលខ្ញុំចាំឈ្មោះដោយសារមើលសំណុំរឿងដែលគាត់ប្ដឹង ក្នុងឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណី លោកតា *អាមីល* គាត់សរសេរមកប្ដឹង ។ ខ្ញុំដឹងរឿងនេះ ។

[១០:២៣:៣២]

**ស៖** ថាតើគេសម្រេចចិត្តឲ្យសម្លាប់អ្នកទោសនៅជើងឯកនៅពេលណា?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! រឿងនាំអ្នកទៅជើងឯក រឿងយើងខ្ញុំទេ ។ រឿងគេតែគេប្រគល់មកហើយ ត្រូវតែស្លាប់ឲ្យគេ ឯចំណែកយើងខ្ញុំដល់នេះទៅរើសយកជើងឯក នេះជារឿងខ្ញុំក្មេងៗពីរនាក់ទេ រវាងខ្ញុំ និងមិត្ត ហ៊ រ ទេ ។ ដូច្នេះ ប្រហែលជាក្នុងខែបួន ឆ្នាំ១៩៧៦ ។

**ស៖** ហើយខ្ញុំជឿថានេះ គឺជាការណែនាំដែលលោកបានស្នើឡើងទៅថ្នាក់លើ ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! យើងខ្ញុំរើសជើងឯកហើយ បានៗជម្រាបទៅគេក្រោយទេ អត់មានសុំសេចក្ដីសម្រេចពីគេមុនទេ ។ យើងខ្ញុំជ្រើសរើសជើងឯកហើយ បានៗយើងខ្ញុំរាយការណ៍ទៅលើក្រោយ ។

**ស៖** ហេតុអ្វី តើវាមានហេតុអ្វីបានជាលោកសម្រេចឱ្យមានការសម្លាប់នៅជើងឯកដូច្នោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកជំទាវ! ខ្ញុំខ្លាចមេរោគ ជំងឺឆ្លង ជម្រាបប្រសាសន៍ ខ្ញុំខ្លាចជំងឺឆ្លង។ ដូច្នេះហើយបើចេះតែសម្លាប់មនុស្សនៅជុំវិញ ស-២១ មជ្ឈមណ្ឌលទួលស្លែង ដែលឥឡូវនេះយើងហៅគុកមជ្ឈមណ្ឌលភ្នំពេញ ហើយយើងឥឡូវនេះយើងហៅថា មជ្ឈមណ្ឌលទួលស្លែង ។ បើចេះតែសម្លាប់មនុស្សនៅភ្នំពេញកាន់តែច្រើនទៅៗ យើងខ្ញុំខ្លាចជំងឺឆ្លង ។ ដូច្នេះហើយ បានៗយើងខ្ញុំឱ្យ មិត្តហ៊ី រើសកន្លែងថ្មី គេចង្អុលជើងឯក ខ្ញុំយល់ព្រម ។ ដល់ខ្ញុំយល់ព្រម យើងធ្វើទាំងពីរនាក់ហើយ បានៗខ្ញុំរាយ-ការណ៍ទៅលើ ។ ដូច្នេះ មូលហេតុសំខាន់គឺ ខ្លាចជំងឺឆ្លង ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

លោកប្រធានខ្ញុំអស់សំណួរទៀតហើយនៅពេលនេះ ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** តើមាននីតិវិធីជាក់លាក់ទេក្នុងការសម្រេចដកយកជនរងគ្រោះទៅសម្លាប់នោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! បើនិយាយតាមភាសាជំនាន់នុ៎ង គេហៅថា នេះជាមាគ៌ាសកម្មភាព ។ ដូច្នេះ សកម្មភាពរបស់គណៈកម្មាធិការស-២១ ត្រូវធ្វើយ៉ាងម៉េចឱ្យសំណូមពររបស់បក្សបានសម្រេច បានល្អ ។ ដូច្នេះ ការសម្រេចបែបណាៗ គណៈកម្មាធិការស-២១ ទទួលខុសត្រូវ ។ ឧទាហរណ៍ត្រូវសម្លាប់នៅជើងឯក ក៏សម្លាប់ដើម្បីឱ្យកិច្ចដំណើរការបានល្អ ។ ដកប៉ុន្មាននាក់ ក៏គណៈកម្មាធិការស-២១ ខំអនុវត្តសកម្មភាព ធ្វើម៉េចឱ្យគោលការណ៍របស់គេដំណើរការបានល្អ កុំឱ្យមានមនុស្សកកស្ទះ ។

[១០:២៧:២៣]

ដូច្នេះ មាគ៌ាសកម្មភាពវាកំណត់ដោយគណៈកម្មាធិការស-២១ ក្នុងក្របខ័ណ្ឌនៃគោលនយោបាយរួមច្បាស់លាស់របស់បក្សកុម្មុយនីស្តកម្ពុជា ។ ខ្ញុំសូមជម្រាបប្រសាសន៍ប៉ុណ្ណោះ ។

**ស៖** កាលដែលយើងសួរអំពីចំណុចជាក់លាក់នេះ ឧទាហរណ៍ថាត្រូវដកបុគ្គលណាម្នាក់ ឬក៏ច្រើននាក់ទៅសម្លាប់ ។ តើយើងត្រូវសម្រេចដោយសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ ឬក៏ផ្ទាល់មាត់? ឬក៏តម្រូវឱ្យមានខាងផ្នែកបញ្ជីស្នាមហ្នឹងគេរៀបចំបញ្ជីមក ទើបលោកសម្រេចជាចំណារថាយ៉ាងដូចម្តេចអ៊ីចឹង បើសិនជាអត់មានសេចក្តីសម្រេចជាក់លាក់តាមករណីនីមួយៗ វាអាចជាបញ្ជី ហើយអាចជាសម្រេចអ៊ីចឹង ។ ពីព្រោះវាអាចមានការច្រឡំ បើសិនគ្រាន់តែនិយាយមាត់ទទេៗ អាចច្រឡំ

ព្រោះមនុស្សច្រើន ។

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ដំណាក់កាលនៃការធ្វើបែបនេះ គឺមានពីរដំណាក់ ។ ខ្ញុំសូមជម្រាបសាឡើងវិញ ដំណាក់ទីមួយគឺមុនពេលដែល មុនពេលកម្មេច សឺន សារី ហៅ ប្រេវ ។ ក្រោយពេលនុ៎ង មិត្តហ៊ី គេយកក្រដាស់មកបង្ហាញខ្ញុំ នេះបងសួររួចហើយ ហ្នឹងប្រាកដថារួចហើយ ថាបាទ អ្ហឺ! សួររួចហើយសួរទៅ យកទៅចុះ ។ អត់មានស៊ីញ៉េនៅលើក្រដាសដែលគេយកមកទេ ប៉ុន្តែគេមានក្រដាស់មួយមានឈ្មោះរបស់គេយកមក នេះជាប្រចាំ ហូរហែ ។ ថ្ងៃណាគេត្រូវយកទៅ គេយកគេយកមកបង្ហាញអាហ្នឹង ។ ដូច្នេះ គេៗរៀបចំឯនោះហើយ អ្នកណាសួរហើយខ្លះ អ្នកណាមិនទាន់សួរគេរៀបចំកុំឲ្យច្រឡំទៀត គេត្រូវមាត់ទៀត ។ រួចរឿងតែត្រូវមាត់ពីរដងមិនល្អទេ ប្រហែលជាមានបញ្ហា ។ ដូច្នេះ ខ្ញុំសូមសង្ខេបជូនប៉ុណ្ណេះ ។

**ស៖** ចុះដល់ពេលលោកធ្វើជាប្រធាន តើក្រោយពីព្រឹត្តហេតុនៃការដែលមនុស្សម្នាក់អំមិញត្រូវបានយកទៅសម្លាប់ដោយបាត់ចម្លើយ ហើយមានកែប្រែ គឺក្រោយមកគឺសិទ្ធិទាំងមូលនៃការសម្រេចថាយកទៅសម្លាប់នេះ គឺសិទ្ធិលើលោក ។ តើនីតិវិធីក្នុងនាមលោកដែលទទួលខុសត្រូវផ្ទាល់ចាប់ពីពេលនោះមក តើប្រព្រឹត្តទៅដូចម្តេចទៅ?

[១០:៣០:០៦]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ក្រោយព្រឹត្តការណ៍នេះ គោលការណ៍ដែលណែនាំមកហើយកំណត់ច្បាស់លាស់ ធ្វើម៉េចកុំឲ្យដាច់ចម្លើយដូចមុនទៀត ។ ធ្វើម៉េចក៏ដោយកុំឲ្យដាច់ចម្លើយដូចមុនទៀត ឯចំណែកកាតព្វកិច្ចយើង ហៅថាកាតព្វកិច្ចចោះ កាតព្វកិច្ចដឹកនាំដក សម្រេច យកទៅកម្មេចយ៉ាងម៉េច គឺនៅដដែលទេ គឺនៅមិត្តហ៊ី គេអ្នកអនុវត្ត ។ ដូច្នេះ គេមានបុគ្គលិករបស់គេហើយ អ្នកសួរហើយ គេអាចចារអក្សរពណ៌អីទៅ ឧទាហរណ៍ពណ៌ក្រហម អ្នកណាសួរមិនហើយ គេចារអក្សរអី ។ ដូច្នេះ មួយអាទិត្យគេមើលម្តងអីរបស់គេទៅ ដល់តែអ្នកសួរហើយ គេកាន់ថាអានេះសួរហើយបង អ្ហឺ! ថាប្រាកដជាសួរហើយ គេថាបាទ អើបើសួរហើយនេះទៅ ខ្ញុំអត់ដែលបានស៊ីញ៉េទេ ។

ដូច្នេះ កិច្ចដំណើរការកុំឲ្យសំណូមពរពីខាងលើ បទបញ្ជាពីខាងលើធ្វើម៉េចកុំឲ្យដាច់ចម្លើយ ។ ដូច្នេះ យើងអនុវត្តអាកុំឲ្យដាច់ចម្លើយហ្នឹង តាមរបៀបនេះ ។ គេយកក្រដាស់មកហុចឲ្យខ្ញុំ ខ្ញុំមិនដែលបានស៊ីញ៉េទេ ជាទូទៅខ្ញុំមិនដែលបានស៊ីញ៉េទេ ឬអាចយូរៗស៊ីញ៉េម្តងប៉ុន្មនុ៎ង ។

**ស៖** យើងកត់សម្គាល់ឃើញឯកសារមួយចំនួនដែលមានចំណាររបស់លោកថាកម្ទេចទាំងអស់ ទុកប្អូនសួរអ៊ីចឹង ។ បានជាយើងហ្នឹង ឬក៏មានករណីផ្សេងដោយឡែក បានន័យថាមនុស្សបញ្ជូនមកដល់ គឺទុកតែប្អូនសួរទេ ហើយប៉ុន្មានទៀតគឺសម្រេចដោយមិនបាច់សួរ ឬក៏ជាការបញ្ចេញមនុស្សពេលដែលសួរហើយបញ្ចេញមនុស្សទៅកម្ទេច ដែលយើងសួរនេះវាការសម្រេចធ្វើបញ្ជី ហើយសម្រេចចារលើបញ្ជី ។ វាអាចមានលក្ខណៈដោយឡែកពីរយ៉ាង ។ ទីមួយគឺក្នុងករណីទ្រង់ទ្រាយធំដែលមនុស្សត្រូវបញ្ចេញច្រើននាក់ ហើយនិងករណីមួយទៀតគឺជាករណីដែលមនុស្សតិចនាក់ ម្នាក់ ឬក៏ពីរនាក់ ។ វាអាចបញ្ហាមានលក្ខណៈខុសគ្នា តាមយើងមើលឯកសារ ។ លោកអាចនិយាយបានទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ឯកសារនេះបើតាមខ្ញុំចាំគឺបញ្ជីពួកខាង ស-២៤ ខាងព្រៃស, ស-២៤ ។ មិត្ត ហ៊ុយ គាត់រាយការណ៍មកពីរឿងបាតុភាពរបស់ពួកនេះ របស់ពួក អ្ហឹ!គាត់សរសេរអាសុខ ។ សុខ នេះគឺមិត្ត សុខ លេខាក្រុងពីអង្កាល់ជំនាន់មុន៧៥ ហើយគាត់ឲ្យទៅនៅខាងព្រៃស គាត់បញ្ជាឲ្យទៅនៅខាងព្រៃ មេខ្ញុំគាត់បញ្ជាឲ្យយកពួកនេះទៅនៅខាងព្រៃស ។ ហើយមួយទៀតគឺ ម៉ៃ លន់, ម៉ៃ លន់ គឺឪពុកក្មេករបស់ សុខ ។ ពួកនេះក៏មេស្គាល់ មេយកចិត្តទុកដាក់ ដូច្នេះ មុននឹងសម្រេចធ្វើម៉េចៗ ពួកនេះ សូមយោបល់មេសិន ។ ដូច្នេះ ខ្ញុំបានសូមយោបល់មេ ហើយបានដល់សូមយោបល់មេហើយ បានៗ ខ្ញុំចារថាវាយចោលទាំងអស់ ទុកតែប្អូននាក់សួរ ។ ដូច្នេះ គឺពួកព្រៃសទេ មិនមែនពួកនៅភ្នំពេញទេ ។ ដូច្នេះ ករណីព្រៃស ជាទូទៅក្នុងក្របខ័ណ្ឌសម្រេចរបស់គណៈកម្មាធិការ ស-២១ ទេ ។ ក៏ប៉ុន្តែដល់អាពិសេសបែបនេះ ពួកមិត្ត សុខ ហើយនិងពួក ម៉ៃ លន់ នេះ មេថា មុននឹងធ្វើម៉េចៗត្រូវឲ្យគាត់ដឹង សូមសម្រេចគាត់ បានៗវាមានចំណារនេះនៅសល់ ។ នេះសូមជម្រាបលោកប្រធានប៉ុណ្ណេះ ។

[១០:៣៣:៥០]

**ស៖** នៅក្នុងសំណុំរឿងដូចជាមានចម្លើយមួយចំនួនបានផ្តល់ថា នៅពេលមានក្នុងកិច្ចប្រជុំមួយនោះ លោកបានណែនាំដល់អ្នកប្រតិបត្តិការក្នុងការសម្លាប់មនុស្សថា វាយត្រង់កញ្ចឹងកនឹងដែកមិនដាច់ទេ ទាល់តែអារ-កទៀតទើបដាច់ ។ តើលោកចងចាំទេ ថាតើលោកបានណែនាំនៅក្នុងអង្គប្រជុំដល់អ្នកដែលអនុវត្តក្នុងការសម្លាប់មនុស្ស នូវពាក្យដែលយើងបានអានអម្បាញ់មិញដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ខ្ញុំមិនចាំទេ ប៉ុន្តែ ឥឡូវខ្ញុំសូមអនុញ្ញាតលោកប្រធាន តើនៅក្នុងសៀវភៅក្រាស់របស់បង ម៉ម ណៃ ឬក្នុងសៀវភៅណា? បើនៅក្នុងសៀវក្រាស់ហ្នឹងពិតជាខ្ញុំបានបង្រៀនគេ ក៏ប៉ុន្តែ ខ្ញុំភ្លេច ។

សូមលោកប្រធានមានប្រសាសន៍ទំព័រ ERN មក ខ្ញុំអាចដឹងបាន បើនៅក្នុងសៀវភៅនុ៎ង ។

**ស៖** នេះជាអង្គហេតុមួយដែលបានបង្ហាញនៅក្នុងដីកាបញ្ជូនរឿងឲ្យជំនុំជម្រះ នៅក្នុងកថាខណ្ឌដែលមានបានលើកឡើងអំពីអង្គហេតុនេះ ។

នេះសម្ដីរបស់សាក្សីទេ ហើយយើងទុកលទ្ធភាពនេះក្នុងការដេញដោលជាមួយនឹងសាក្សីទៀត បើសិនជាលោកឆ្លើយ ព្រោះសាក្សីមួយចំនួនដែលពាក់ព័ន្ធនឹងនេះ ដោយសាររក្សាសិទ្ធិក្នុងការការពារអត្តសញ្ញាណ យើងនឹងធ្វើការសួរដេញដោលជាមួយនឹងសាក្សីទៀត ដែលមានការបានឆ្លើយដូច្នេះ ។ ហើយពេលនេះយើងមិនដេញដោលបញ្ហានេះទៀតទេ គ្រាន់តែសួរលោកថាតើលោកចងចាំដែរឬទេលើបញ្ហានេះ? បើលោកមិនចងចាំទេ យើងនឹងធ្វើការតទល់ជាមួយនឹងសាក្សីនៅពេលក្រោយ ។

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ខ្ញុំមិនចងចាំទេៗ ហើយក៏ខ្ញុំនៅតែរក្សាពាក្យខ្ញុំថា ខ្ញុំអត់បង្រៀនក្រពើឲ្យហែលទឹកទេ ។

**ស៖** នៅការនាំមនុស្សចេញពីគុកទួលស្លែងទៅសម្លាប់នៅក្នុងបរិវេណតំបន់ក្បែរៗទួលស្លែង ដែលយើងបាននិយាយអំមិញ គឺហៅថាជិត ឬក៏ក្បែរទួលស្លែងនេះ ។ តើប្រព្រឹត្តទៅនៅពេលវេលាថ្ងៃ ឬក៏នៅពេលយប់? ព្រោះអំមិញលោកបានលើកឡើងថា មនុស្សពីរនាក់ដែលសំខាន់នោះ គឺបានប្រព្រឹត្តការណ៍ក្នុងការសម្លាប់នៅវេលាម៉ោងប្រាំភ្លឺ ។ ចុះករណីផ្សេងទៀតហ្នឹង តើក្នុងការសម្លាប់ហ្នឹង យើងប្រព្រឹត្តទៅនៅក្នុងអំឡុងពេលណា? ពេលថ្ងៃ ឬក៏ពេលយប់?

[១០:៣៧:៤០]

**ឆ៖** ខ្ញុំអត់បានឃើញផ្ទាល់ភ្នែកក៏ពិតមែន ក៏ប៉ុន្តែ បើឲ្យយើងខ្ញុំសន្និដ្ឋាន ខ្ញុំសន្និដ្ឋានថាស្ទើរតែទាំងអស់គឺពេលយប់ ។

**ស៖** លោកបានដឹងទេអំពីស្ថានភាពនៃរណ្ដៅកប់សពទាំងរណ្ដៅកប់សពរួម ទាំងរណ្ដៅកប់សពដោយឡែក ។ តើមានការរៀបចំជាមុនដែរទេ មុនដឹងនាំមនុស្សចេញយកទៅសម្លាប់នោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! គឺមានការរៀបចំជាមុន នៅខាងភ្នំពេញមិនដងយ៉ាងម៉េចទេ ប៉ុន្តែខ្ញុំជឿថាមានរៀបចំ ជីកជាមុន បានៗនាំមនុស្សយកចេញទៅ ។ ដោយឡែកនៅខាងជើងឯកមានមួយក្រុមនៅចាំនៅនុ៎ង មនុស្សដែលខ្ញុំស្គាល់ច្បាស់ថានៅចាំនៅនុ៎ង ខ្ញុំបានជួបនៅពេលទៅធ្វើការបង្ហាញឡើងវិញនោះ ជួប មិត្តតេង, តើយ តេង ។ ពួកមួយក្រុមហ្នឹងនៅ មិនមែនមួយក្រុមទេ ប្រហែលមួយពួក ប្រហែលគ្នាបួននាក់នៅចាំនៅនុ៎ង ប្រចាំជីករណ្ដៅ លប់រណ្ដៅឲ្យគេតែប៉ុននុ៎ង គ្នាអត់ធ្វើអីទេ។

ឯចំណែក កម្មោច ពួកកងពិសេសទៅពីភ្នំពេញទេ ។

ដូច្នេះ សូមសរុបមកវិញ រណ្ដៅទោះបីនៅភ្នំពេញក៏ដោយ ទោះបីនៅមជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯកក៏ដោយ ក៏មានការរៀបចំទុកជាមុន ។

**សៈ** ហើយយើងមានបានធ្វើការបែងចែកទេថាអ្នកដែលទទួលបន្ទុកជីករណ្ដៅសម្រាប់កប់សព ហើយនិងក្រុមអ្នកដែលទទួលបន្ទុកខាងសម្លាប់ ឬក៏អ្នកដែលទទួលបន្ទុកខាងសម្លាប់ហ្នឹងឯង ដែលជាអ្នកជីករណ្ដៅនោះ?

**ឆៈ** បើតាមខ្ញុំចាំ ហើយខ្ញុំបានដេញដោលសួរ មិត្តហ៊ អ្នកជីករណ្ដៅ គ្នាចេះតែជីករណ្ដៅ នេះទីមួយ ។ ទីពីរលប់រណ្ដៅវិញ ពីបីការពារមិនឲ្យអ្នកចូលទៅដល់ក្នុងបរិវេណនេះឃើញរណ្ដៅ ។ នេះភារកិច្ចរបស់អ្នកដែលនៅប្រចាំការនៅនឹងជើងឯកនេះ នៅប្រចាំការហ្នឹង ជាប់នឹងខ្មោចទាំងយប់ទាំងថ្ងៃហ្នឹង គ្នាហ្នឹង ។

[១០:៤០:០៤]

**សៈ** យើងសួរនេះ យើងសួរក្នុងកម្រិតនៅជុំវិញស-២១ យើងមិនទាន់ មិនចង់ពន្លាតឲ្យមានច្របូលច្របល់ពីព្រោះយើងធ្វើការអង្គហេតុពីរដាច់ពីគ្នា ពាក់ព័ន្ធគ្នាតិចតួច ។

ប៉ុន្តែ គោលបំណងអំមិញនេះ គឺសួរនៅក្នុងអង្គហេតុជុំវិញ នៃមន្ទីរស-២១ ដែលជាមជ្ឈមណ្ឌលនៅក្នុងក្រុងភ្នំពេញ ។

**ឆៈ** ជម្រាបប្រសាសន៍លោកប្រធាន! ការសម្លាប់មនុស្សនៅភ្នំពេញ ជីករណ្ដៅតូច យ៉ាងច្រើនសម្រាប់តែបីនាក់ប៉ុនន៎ុង ។ ដូច្នេះ ពួកកងពិសេសជាអ្នកជីកៗមុន បានៗនាំមនុស្សទៅក្រោយ ។ សូមបញ្ជាក់ជូនប៉ុណ្ណេះ ។

**សៈ** ប៉ុន្តែតាមកំណត់ជាច្រើនអំពីការកកាយរកសាកសព ឃើញថាមានរណ្ដៅសាកសពរួមខ្លះរហូតដល់ម្ភៃប្រាំបីនាក់ឯណោះ មានចំនួនរហូតដល់ម្ភៃប្រាំបីនាក់ ។ មានចំនួនដប់ជាង ដប់ពីរ ដប់បី ដប់ប្រាំបី ប៉ុន្តែ អាចំនួនច្រើនយើងឃើញបញ្ជីគឺមានរហូតដល់ចំនួនមួយរណ្ដៅមានចំនួនម្ភៃប្រាំបី នាក់ឯណោះ ។ នេះជាការដែលស្រាវជ្រាវរុករកក្រោយពេលក្រោយឆ្នាំ៧៩ ដោយគាស់សាកសពមក ដែលយើងមិនឃើញឆ្អឹងអដ្ឋិធាតុរហូតមកដល់សព្វថ្ងៃនេះ គឺដោយសារការគាស់របៀបនេះ ប៉ុន្តែមានកំណត់ហេតុដែលបង្ហាញថាមួយរណ្ដៅមានមនុស្សច្រើន មិនមែនបីដូចលោកទេ ។ តើលោកជឿថាអ៊ីចឹងទេ ឬក៏លោកប្រកាន់យកថាមួយរណ្ដៅអាចមានយ៉ាងច្រើនបីនាក់នោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ខ្ញុំចុះចាញ់ភស្តុតាងហើយ នេះជាភស្តុតាងដែលអត់ប្រកែកទេ ខ្ញុំអត់បានប្រកែកទេ ។

**ស៖** មួយសំណួរទៀតចុងក្រោយ មួយសំណួរទៀតនៅមានសំណួរច្រើនដែរ ប៉ុន្តែសម្រាក ។ តើមានករណីតម្រូវ ឬក៏នាក់ឃាដករ ឬក៏អ្នកសម្លាប់ហ្នឹង តម្រូវ ឬបញ្ជាឲ្យអ្នកដែលត្រូវគេហ្នឹងសម្លាប់នោះជីករណ្តៅសម្រាប់កប់ខ្លួនជាមុនៗនឹងសម្លាប់ដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ខ្ញុំមិនដឹងរឿងនេះទេ ក៏ប៉ុន្តែ ខ្ញុំមិនជឿៗ ឬក៏និយាយថាជឿតិចណាស់ ប្រាំភាគរយមិនដល់ផង ។

**ប្រធានអង្គជំនុំ៖**

មកឥឡូវនេះដល់ម៉ោងត្រូវសម្រាកហើយ អង្គជំនុំជម្រះប្រកាសឈប់សម្រាកចំនួនម្ភៃនាទីរហូតដល់ម៉ោងដប់មួយ ចាប់នឹងបន្តដំណើរការសវនាការដេញដោលតទៅតទៀត ។

*[សវនាការសម្រាកពីម៉ោង ១០:៤៣ នាទីដល់ម៉ោង ១១:០៥នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តដំណើរការនីតិវិធីសវនាការដេញដោលតទៅទៀត ។

**ស៖** លោកអាចប្រាប់ដល់អង្គសវនាការបានទេថា មនុស្សដែលត្រូវបាននាំទៅសម្លាប់ ហើយកប់នៅក្នុងរណ្តៅសាកសពរួម ដូចដែលយើបានលើកឡើងអម្បាញ់មិញមុននឹងសម្រាកបន្តិចនេះ ថាតើវិធីនាំមនុស្សទៅសម្លាប់ដូច្នេះ តើប្រព្រឹត្តតាមមធ្យោបាយអ្វីទៅ? វាអាចខុសពីទៅខាងជើងឯក វាអាចខុសគ្នា នេះគឺជាកន្លែងជិតៗ ហើយវាផ្លូវមានការកន្ទុកកន្ទៀត ឬក៏ផ្លូវឡើងហែមតូចៗផង តើដឹងជញ្ជូនមនុស្សទឹងទៅចេញពីកន្លែងគុកទួលស្លែងនឹងទៅដល់កន្លែងហ្នឹង ប្រព្រឹត្តទៅយ៉ាងដូចម្តេច? លោកដឹងរឿងហ្នឹងទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ខ្ញុំមិនដឹងច្បាស់ទេ ។ ក៏ប៉ុន្តែ ខ្ញុំសូមសន្និដ្ឋានជូន ដោយសារការងារនេះវាជាការងារឧក្រិដ្ឋដែលយើងខ្ញុំប្រព្រឹត្តជាហូរហែទៅហើយ វាអាចសន្និដ្ឋានបាន បើមិនចំពេក ក៏វាច្បាស់ជាមូលដ្ឋានដែរ ។ គឺគេមិនយកចេញទៅច្រើនម្តងទេ យកចេញទៅយ៉ាងច្រើនបីនាក់

ម្តង ដោយចងមុខ ។ ទៅដល់នុំងកម្មេចហើយមួយសាអ៊ីចឹងទៅ បានគេមកយកមួយសាទៀតយកទៅកម្ទេចទៀត ។ ដូច្នេះ មួយយប់ ឧទាហរណ៍ គេអាចធ្វើបាន ម្ភៃប្រាំបីនាក់ប៉ុននុំង ។ ដូច្នេះ ខ្ញុំគិតថា វាដំណើរការទៅបែបនេះ ចៀសវាងការរត់រួច ចៀសវាងការបែកការណ៍ ចៀសវាងអីៗនុំង គេយកទៅតិចៗអ៊ីចឹងទេ ។ សូមជម្រាបប្រសាសន៍ប៉ុណ្ណេះ ។

**ស៖** ពាក់ព័ន្ធនឹងការសម្លាប់ពួកបស្ចិមប្រទេសប្អូននាក់ ។ អំមិញចៅក្រម ធូ មណី ហើយចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ លោកស្រីបានសួរដេញដោលលោកហើយ គឺយើងចង់បញ្ជាក់បញ្ហានេះពីព្រោះយើងឃើញមានការអះអាងផ្ទុយគ្នា ។ អ៊ីចឹង យើងគ្រាន់តែសួរបញ្ជាក់បន្ថែមមួយចំនួនដូចខាងក្រោមនេះ៖

ព្រោះលោកថាមិនជឿទេថា នៃពួកបស្ចិមប្រទេសនោះត្រូវគេដុតទាំងរស់ ។ សួរថា តើក្នុងករណីនោះ លោកបញ្ជាទៅអ្នកក្រោមបង្គាប់ឲ្យសម្លាប់ជនបរទេសនុំង លោកបញ្ជាថាម៉េច?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ខ្ញុំនៅចាំពាក្យដែល ពួនួន គាត់បញ្ជាមកខ្ញុំ ។ គាត់ថា "ពួកអាច្រមុះវែងកម្ទេចទៅ ហើយថតរូបឲ្យផង ។ មិត្តត្រូវចាំយើងមិនទុកឆ្អឹងសម្រាប់ដូរយក *ប៊ូដូហ្វែរ* ដូចគុយបាទេ ។ គុយបា គេទុកឆ្អឹងសម្រាប់ដូរយក *ប៊ូដូហ្វែរ* អានេះគាត់និយាយបានវែងប៉ុណ្ណឹង ។ ហើយមកដល់ខ្ញុំមកដល់ផ្ទះហៅ មិត្តហ៊ី មកប្រាប់ថា ពួកបារាំង ខ្ញុំមិននិយាយហៅ អាច្រមុះវែងដូចគាត់ទេ ខ្ញុំហៅថាពួកបារាំងដកចេញទៅ ។ អង្គការសម្រេចឲ្យដកហើយ ហើយអង្គការឲ្យថត-- សុំទោស អង្គការឲ្យដុតឲ្យអស់សាកសពនោះ ខ្មោចនោះ ខ្ញុំនិយាយខ្មោច ដុតខ្មោចនុំង ឲ្យអស់ ឲ្យសុះកុំឲ្យនៅសល់ ។ ហ្នឹងខ្ញុំបញ្ជាក់ច្បាស់អ៊ីចឹងរបស់ខ្ញុំ សូមបញ្ជាក់ថា បទបញ្ជាពីលើមក ខ្ញុំបញ្ជាទៅរបៀបនេះ គឺកម្ទេចទៅដកទៅ ដុតខ្មោចឲ្យសោះឲ្យអស់ ។ នេះសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

[១១:១០:៤៦]

**ស៖** តើលោកបានទទួលរបាយការណ៍ ឬក៏ត្រួតពិនិត្យពីលើប្រតិបត្តិការនៃការសម្លាប់នោះដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ខ្ញុំអត់បានត្រួតពិនិត្យទេ គឺមិត្តហ៊ី គេដឹកនាំកិច្ចការនេះដោយផ្ទាល់ ។ លក្ខណៈពិសេសអ៊ីចឹង គឺមិត្តហ៊ី ទៅត្រួតពិនិត្យបញ្ហានេះ ដោយផ្ទាល់នៅនឹងកន្លែង ។

**ស៖** លោកបានទទួលស្គាល់រួចហើយអំពីការសម្លាប់ប្រភេទនោះ ដោយវិធីបូមឈាម យកឈាមយ៉ាងច្រើនរហូតដល់សោះពីខ្លួន ហើយស្លាប់ គឺយើងមិនចង់បញ្ជាក់បញ្ហាហ្នឹងទេ។ ប៉ុន្តែ យើង

ចង់បញ្ជាក់អំពី តួលេខនៃមនុស្សដែលត្រូវស្លាប់តាមមធ្យោបាយនេះ ដោយនៅក្នុងអង្គហេតុព្រមព្រៀង គឺមានបញ្ជាក់អំពីបញ្ហានេះដែរ ។ នៅក្នុងកថាខណ្ឌ២៥៩ គឺសរុបយ៉ាងហោចណាស់មានមនុស្សមួយពាន់នាក់ ដែលត្រូវសម្លាប់ដោយវិធីនេះ ដោយគេបូមឈាមអ្នកទាំងនោះ ពីម្ភៃទៅសាមសិបនាក់ជារៀងរាល់ថ្ងៃ ។ អ៊ីចឹង វាអាចភាពផ្ទុយគ្នា តែលេខទេ បានន័យថា ការអះអាងនៅក្នុងឯកសារយ៉ាងតិចមួយពាន់នាក់ ប៉ុន្តែលោកបាននិយាយពីថ្ងៃម្សិលមិញ ហើយព្រឹកមិញលោកបានបញ្ជាក់ទៀត យ៉ាងច្រើនបំផុតតែមួយរយនាក់ទេ ឃើញថាវាមានលម្អៀងគ្នាច្រើនមែនទែនលេខនេះ ។ សួរថាតើលោកប្រកាន់ជំហរយ៉ាងម៉េចដែរលើបញ្ហាចំនួនមនុស្សដែលត្រូវសម្លាប់ដោយវិធីបូមឈាមនេះ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ខ្ញុំសូមលើកជូនជាការសង្កេតសក្ខីកម្មដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ ខ្ញុំបាទបានបដិសេធ ពីព្រោះវាជារបៀបគិតលេខធម្មតា ។ គេថា មួយអាទិត្យពីម្ភៃនាក់ទៅសាមសិបនាក់ ។ ដូច្នេះ គេគុណមួយឆ្នាំទៅ គេគុណលេខអ៊ីចឹងទេ ។ ឯចំណែក ខ្ញុំបាទវិញខ្ញុំជឿថា ចំនួនដែលខ្ញុំនិយាយនេះ អាចមានខ្វះ ឬក៏អាចមានលើសខ្លះមួយរយហ្នឹង ។ ខ្ញុំជឿថា ឯកសារពិតជាមាននៅសល់ សម្រាប់បញ្ជាក់ជូនជាភស្តុតាង ។ នេះខ្ញុំសូមបញ្ជាក់ជូនប៉ុណ្ណោះ ថាខ្ញុំមិនទទួលស្គាល់ថា រហូតដល់មួយពាន់ ហើយមួយអាទិត្យផ្ទៀងផ្ទាត់ម្ភៃនាក់នោះទេ ។ ហើយក៏មិនទទួលស្គាល់ថា ទៅពេទ្យឯណាក្រៅអំពី៩៨ដែរ គឺទៅតែពេទ្យ៩៨ ទេ ។ សូមបញ្ជាក់ប៉ុណ្ណោះ សូមអរគុណ ។

[១១:១៤:០៣]

**ស៖** នៅក្នុងកថាខណ្ឌដដែលហ្នឹង គឺចំណុច “គ” នៅថ្ងៃមួយនៅមន្ទីរស-២១ គេបានប្រទះឃើញមានឈាមពីសាមសិប ទៅសែសិបប្លោក នេះជាអង្គហេតុមួយដែរ ។ លោកអាចបញ្ជាក់បញ្ហានេះបានទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ឈាមដែលបូមៗភ្លាម យកចេញទៅភ្លាម នេះបើតាមខ្ញុំចាំ ហើយខ្ញុំនៅក្តាប់បាន ខ្ញុំនឹកឃើញមិនដែលមានទុកឈាមណាឲ្យខូចដល់ទៅសាមសិប, សែសិបប្លោកទេ ។ មូលហេតុឈាមខូច តើដោយសារអី? អត់មានមូលហេតុច្បាស់លាស់បញ្ជាក់ទេ ហើយយើងខ្ញុំដឹងថា មុននឹងបូមឈាម គេគ្រាន់តែបានជួសមើលក្រុមឈាម ក្រុមA, ក្រុមB, ក្រុមO, ក្រុមAB គេបានគិតប៉ុននុ៎ង គេអត់គិតដល់ *វីសាស់រ៉ាស្ទ័រ* អីទៀតទេ ។ ដូច្នេះ រឿងឈាមអត់មានទុកឲ្យនៅសល់រហូតខូចដល់ទៅសាមសិប, សែសិបប្លោកទេ ។ នេះខ្ញុំសូមបញ្ជាក់ជូនដោយស្មោះប៉ុណ្ណោះ ។

**ស៖** កថាខណ្ឌអំមិញដែរត្រង់ចំណុច “ឆ” មាន នៅមានកន្លែងចិញ្ចឹមឈាមមួយកន្លែងផងដែរ ហៅថា ស្រះស្រង់ ដែលស្ថិតនៅខាងកើតគុកទួលស្លែង ។ តើមានដូច្នេះដែរឬទេ?

**ឆ៖** សូមជម្រាបប្រសាសន៍លោកប្រធាន! ឈ្មោះស្រះស្រង់នេះ គ្មានអ្នកណាប៉ានប្រើសម្រាប់ដាក់នៅក្នុងស្ថានទីណាមួយនៃអង្គការណាមួយរបស់ ប៉ុល ពត ទេ ។ ដូច្នេះ គ្រាន់តែឈ្មោះហ្នឹង វាច្បាស់ណាស់ទៅហើយ ថាមិនមែនជាទីតាំងមួយទេ ។ រួចបើនិយាយអំពីកន្លែងចិញ្ចឹមឈាម ដែលបារាំងគេហៅថា *បង់ដុយស្សង់*ៗ នោះកាន់តែច្បាស់ណាស់ទៅទៀតថា មិនមែន ។ ព្រោះមិនអាចមាននរណាធ្វើដោយគ្មានខ្ញុំទៅសុំពីខាងលើ ទាល់តែខ្ញុំសរសេរទៅសុំពីខាងលើ បានៗធ្វើបាន ព្រោះវាត្រូវការបច្ចេកទេស វាត្រូវការសម្ភារៈទំនើប ។ ដូច្នេះ ត្រូវហាត់រៀនអ្នកបច្ចេកទេសរក្សាឈាមនោះទៅទៀត ។ ដូច្នេះ គ្មានទេ ខ្ញុំសូមបដិសេធថា មិនមាន *បង់ដុយស្សង់* នៅស-២១ ទេ ។

**ស៖** ឥឡូវអរគុណ ។ ឥឡូវនេះ យើងចូលដល់ទៅពាក់ព័ន្ធជាមួយអង្គហេតុនៅជើងឯក ។ មុន

នឹងចូលពាក់ព័ន្ធជើងឯកហ្នឹង មានសំណួរមួយទៀត សួរថា តើមាននៅក្នុងពេលដែលនាំមនុស្សទៅចេញពីកន្លែងឃុំឃាំងហ្នឹង ទៅសម្លាប់ហ្នឹង នៅបរិវេណជុំវិញមន្ទីរស-២១ ហ្នឹង តើការនាំអ្នកទោសទៅសម្លាប់ហ្នឹង ហើយអ្នកដែលនាំទៅហ្នឹង គេប្រើពាក្យភូតកុហកយ៉ាងម៉េចដើម្បីឲ្យអ្នកទោសហ្នឹងមានការប្រឆាំងតបត ឬក៏រត់គេចខ្លួន ឬក៏ដឹងខ្លួនមុនជាដើម?

[១១:១៧:៣១]

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! នៅក្នុងសម័យខ្មែរក្រហម ការយកទៅសម្លាប់ ការចាប់ចង យកទៅចាប់ សុទ្ធតែប្រើពាក្យភូតទាំងអស់ ។ ដូច្នេះ ភូតថាទៅផ្ទះថ្មី វាជាពាក្យភូតដែលមានលក្ខណៈហូរហែមកហើយ ។ ក៏ប៉ុន្តែ វាជាគ្រាន់តែជំនួយស្មារតីប៉ុនន៎ុង គេចងដៃគ្នាជាប់ គេចងភ្នែកគ្នាជាប់ទៅហើយ ហើយគេនៅចាំពីក្រោយទៅទៀត ហើយធ្វើម៉េចគ្នារត់ទៅរួចទៅ គ្រាន់តែការពារមិនឲ្យស្រែកប៉ុនន៎ុង ។ ដូច្នេះ គេចេះតែលួងលោមហើយ ទន់ភ្លន់ហើយ ។ រឿងលួងលោមវាពិត ដូច្នេះ ខ្ញុំសូមទទួលស្គាល់ថា ពាក្យលួងលោម ភូតភរ ប្រាកដជាមានតាមបែបណាមួយមិនខាន ។ ហើយជាទូទៅពាក្យថាផ្លាស់កន្លែងថ្មី ។ សូមជម្រាបប្រសាសន៍លោកប្រធានប៉ុណ្ណេះ ។

**ស៖** ពាក់ព័ន្ធជាមួយនឹងការជ្រើសរើសយកបឹងជើងឯកធ្វើជាពិឃាដ អំមិញលោកស្រីថៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ លោកបានសួរលោករួចហើយ អំពីហេតុទាំងឡាយនៃការជ្រើសរើស ឬក៏អ្នកណាជាសម្រេចជ្រើសរើសទីនោះ ដើម្បីយកទៅធ្វើជាកន្លែងសម្រាប់ជាវាលពិឃាដ និងកប់សាកសពរួម

នោះ ។ យើងសួរថា ក្រោយពេលសម្រេចជ្រើសរើសយកទីនោះហើយ ថាមុននឹងប្រតិបត្តិការ តើលោក និងកងកម្លាំងរបស់មន្ទីរសន្តិសុខស-២១ របស់លោកហ្នឹង ទៅចាត់ចែងរៀបចំនៅទីនោះ ធ្វើយ៉ាងម៉េច ខ្លះទៅមុននឹងប្រតិបត្តិការ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ខ្ញុំជម្រាបដោយត្រង់ កិច្ចការអស់នេះ ប្រគល់ឱ្យគេគិតគូ ឱ្យគេធ្វើ ។ ក្រោយពីអនុម័តសម្រេចថា យកជើងឯកហើយ ខ្ញុំមានភារកិច្ចរាយការណ៍ទៅ ខ្ញុំត្រូវ រាយការណ៍ជូនមេៗ"អ៊ី" ដល់ទៅខាង មិត្តហ៊ី គេធ្វើៗតាមគោលការណ៍រក្សាសម្ងាត់ ហើយនិងរៀបចំ ការកម្ទេចនេះ ឱ្យបានស្រួលកុំឱ្យបែកការណ៍ ។

ដូច្នេះ គេមានបាំងជញ្ជាំងស័ង្កសី គេមានរុះផ្ទះពីភ្នំពេញយកទៅសង់ផ្ទះឈើមួយនៅនុ៎ង នៅខាង លើសម្រាប់អ្នកដែលនៅចាំផ្លូវ ចាំសាកសពនោះដេក ហើយនៅខាងក្រោមជាកន្លែងសម្រាប់ដាក់ជនរង គ្រោះ ដែលគេដឹកថ្ងៃនុ៎ងយកទៅកម្ទេចដាក់ខ្នោះនៅខាងក្រោម ។ យើងខ្ញុំទៅៗឃើញផ្ទះនុ៎ងច្បាស់ ។ ដូច្នេះ កិច្ចដំណើរការវាទៅអ៊ីចឹង ឱ្យប្រចាំមនុស្សបួននាក់នៅមួយក្រុមហ្នឹង សម្រាប់ជីករណ្តៅ សម្រាប់ កប់ សម្រាប់ការពារកុំឱ្យគេចូលទៅមើល ។ នេះ សូមបញ្ជាក់ជូនប៉ុណ្ណោះ ។

**ស៖** ក្រៅពីនេះ យើងមានធ្វើរបងអីទេ ឬក៏មានធ្វើជាប៉ុស្តិ៍យាមអីដែរទេ? ដូចជារបងខណ្ឌថា តំបន់នេះ គឺជាតំបន់កាន់កាប់ដោយមន្ទីរស-២១ អីអ៊ីចឹង ដែលជាបញ្ជាក់សម្រាប់នឹងបែងចែកអង្គភាព ផ្សេងទៀតកុំឱ្យមានការចូល ឬក៏ទៅគ្រប់គ្រងច្របូកច្របល់គ្នានៅទីនោះ ព្រោះជាកន្លែងសម្ងាត់ផង?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ដីនេះ គឺជាដី ប្រហែលជាដីកងពល៥០២ ប្រហែលជាដី របស់កងពល៥០២ ។ នៅពេលដែលសម្រេចចិត្តយកដីនេះហើយ ទាល់តែទៅសុំគេ ដូច មិត្តហ៊ី ទៅសុំ ។ ហើយបាំងស័ង្កសីជុំវិញៗ ហើយបានធ្វើកូនផ្ទះមួយនៅនុ៎ង ។ ដូចខ្ញុំបានជម្រាបលោកប្រធាន អ៊ីចឹង នេះប៉ុណ្ណឹង បើតាមខ្ញុំដឹង ។

**ប្រធានអង្គជំនុំ៖**

អរគុណ ។ តើលោក លោកស្រីចៅក្រម មានសំណួរអ្វីសួរដល់ជនជាប់ចោទទេ ទាក់ទងជាមួយ នឹងអង្គហេតុនៃប្រតិបត្តិការវាលពិឃាតជើងឯកនេះ?

សូមអញ្ជើញលោកចៅក្រម យ៉ាសុខន ។

**សួរដោយចៅក្រម យ៉ា សុខន៖**

**ស៖** សូមអរគុណលោកប្រធាន ។ តើលោកនៅចាំទេថា អ្នកទោសដែលយកទៅសម្លាប់នៅជើង

នោះ មានចំនួនប៉ុន្មាននាក់? ប្រហែលចំនួនប៉ុន្មាននាក់?

[១១:២៣:២៣]

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ខ្ញុំមិនចាំទេ គ្រាន់តែដឹងថា ក្នុងចំណោមមួយម៉ឺនពីរពាន់បីរយប្លាយនាក់ បួនរយនាក់ប្លាយនេះ បន្ថែមប៉ុន្មានមួយរយហុកសិបប្លាយលើកក្រោយនេះ ភាគច្រើនគឺកម្ទេចនៅជើងឯក បន្ទាប់មក គឺកម្ទេចនៅខាងតាខ្មៅ ហើយនៅភ្នំពេញជាភាគតិចជាងគេ ។ នេះគឺសូមបញ្ជាក់ជូនប៉ុណ្ណេះ ។ សូមបញ្ចប់ ។

**ស៖** មិនមានកំណត់ណាមួយដែលថាបែងចែកអ្នកទោសនេះត្រូវសម្លាប់នៅជើងឯក អ្នកទោសនោះត្រូវសម្លាប់នៅស-២១ មានទេ មានការបែងចែកអ្នកទោសបែបដូច្នេះទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! បើនិយាយពីបែងចែក គឺបែងចែកទៅតាមកាលបរិច្ឆេទមុនក្រោយ ។ មុនដំបូងខាងស-២១ ក៏ដូចជាអតីតមន្ទីរកងពល៧០៣ គឺសម្លាប់នៅក្នុងគុកពេទ្យឆ្កួតតាខ្មៅ ។ ដល់ក្រោយមកសម្លាប់ពីសពាសនៅជុំវិញ ជាពិសេសបរិវេណវិទ្យាល័យពញាយ៉ាត ។ ដល់ក្រោយមកបានទៅជើងឯក ។ នេះគឺបែងចែកតាមកាលបរិច្ឆេទរបៀបនេះ ។ ក៏ប៉ុន្តែ មនុស្សសំខាន់ដែលត្រូវថត កុមារតូចពេកក្រោមអាយុប្រាំឆ្នាំ ហើយនិងមនុស្សដែលស្លាប់ដោយសារការបូមឈាម ឬស្លាប់ដោយសារជំងឺ ប្រាកដជាបានកប់នៅនឹងភ្នំពេញ ។ នេះគឺបែងចែករបៀបនេះទៅវិញទេ ។ សូមបញ្ជាក់ជូនតាមការចងចាំប៉ុណ្ណេះ ។

**ស៖** លោកបានជ្រើសរើសជើងឯកជាកន្លែងសម្លាប់អ្នកទោសដែលនៅឆ្ងាយពីទីក្រុង តើលោកមានបានណែនាំវិធីក្នុងការដឹកនាំអ្នកទោសយកទៅជើងឯកនេះតាមវិធីណាទៅ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ខ្ញុំអត់បានណែនាំអំពីរបៀបដឹកជញ្ជូនទេ ដោយខ្ញុំជឿជាក់ថា អានេះវាជារបស់ដែលគេធ្លាប់ធ្វើ របៀបរបបដែលគេធ្លាប់ធ្វើ ឧក្រិដ្ឋកម្មដែលគេធ្លាប់ធ្វើ ។ និយាយអ៊ីចឹងមិនមែនថា ខ្ញុំចោលឧក្រិដ្ឋកម្មនេះទម្លាក់ទៅលើគេទ ខ្ញុំទទួលខុសត្រូវពីលើក៏ពិតមែន ក៏ប៉ុន្តែដល់ចូលជាវិធីល្អិតក្នុងការអនុវត្តឧក្រិដ្ឋកម្មនេះ ខ្ញុំអត់មានបានណែនាំទេ ទុកឲ្យគេដំណើរការតាមការចេះដឹងរបស់គេស្រាប់ ។ នេះសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

**ស៖** នៅពេលដែលកំណត់ថាយកអ្នកទោសយកទៅជើងឯក តើលោកមានឲ្យដំណឹងជាមុនទៅអ្នកប្រចាំការនៅជើងឯកនោះបានដឹងជាមុនទេ?

[១១:២៦:០២]

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! អ្នកប្រចាំការនៅជើងឯកអាចដឹងមុនក៏ថាបាន មិនដឹងមុនក៏ថាបាន ព្រោះនៅក្នុងអង្គភាពពួកកងពិសេសដូចគ្នា ។ ពួកនោះចាំតែឃើញខាងណោះគេទៅដល់បើកទ្វារឲ្យចូល ។ ដូច្នេះ អាចប្រហែលជាមិនបានឲ្យព័ត៌មានមុនទេ ព្រោះៗពួកនុ៎ងនៅចាំតែការពារវណ្ដៅការពារសាកសព ជីករណ្ដៅ លុបរណ្ដៅ ហើយការពារមិនឲ្យគេចូល ។ ដូច្នេះ ឃើញឡានពីស-២១ ទៅជាឡានរបស់គេ គេបើកទ្វារហើយ ។ ដូច្នេះ អត់មានឲ្យដំណឹងមុនទេ ។ សូមជម្រាបបញ្ជាក់ប៉ុណ្ណេះ ។

**ស៖** តើមានឬទេ កងពិសេសដឹកជញ្ជូនអ្នកទោសយកទៅជើងឯកតាមរថយន្ត ហើយបានមុននឹងបញ្ចូលទៅក្នុងរថយន្តបានបញ្ឆុះបញ្ចូលអ្នកទោសប្រើថា ប្ដូរផ្ទះថ្មី មានយ៉ាងដូច្នេះទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! កិច្ចដំណើរការបែបនេះ ភូតភរបែបនេះ ក្នុងរឿងឧក្រិដ្ឋកម្មទូទៅទាំងប្រទេស ជាពិសេស យើងកំពុងនិយាយនេះរឿងស-២១ គឺពិតជាមាន គឺពិតជាភរអ៊ីចឹង ។

**ស៖** រថយន្តដឹកអ្នកទោសទៅនោះ តើមានអ្នកការពារតាមរថយន្តមានចំនួនប៉ុន្មាននាក់ដែរ មានដឹងទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ប្រហែលជាអាចបួននាក់ ។ អ្នកបើកម្នាក់, អ្នកបញ្ជាក្បួននោះម្នាក់, ហើយពីខាងក្រោយយាមពីរនាក់ ។

**ស៖** អ្នកទោសដែលត្រូវគេចាប់បញ្ជូនទៅឡើងលើរថយន្ត តើមានគេចងមុខ ឬក៏ដាក់ខ្នោះជើង ឬដាក់ខ្នោះដៃឬទេ មុននឹងបញ្ជូនទៅ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! រឿងដាក់ខ្នោះដៃ ឬក៏ចងស្ពាបសេកទៅក្រោយ ត្រូវតែធ្វើចងមុខត្រូវតែធ្វើ ។ ឯចំណែក ការដាក់ខ្នោះជើងថែមទៀត ខ្ញុំជម្រាបថាមិនច្បាស់, ខ្ញុំជម្រាបថាអត់ច្បាស់ទេ ។ នេះសូមជម្រាបបញ្ជាក់ប៉ុណ្ណេះ ។

**ស៖** តើមានឬទេ នៅពេលដែលរថយន្តទៅដល់ជើងឯក ហើយអ្នកទោសត្រូវបានគេដាក់ចូលទៅក្នុងផ្ទះឈើមួយ?

**ឆ៖** រឿងនេះវាត្រូវតែធ្វើអ៊ីចឹង ត្រូវតែដាក់ចូលទៅក្នុងផ្ទះឈើមួយ ដាក់ខ្នោះជើងសិន ហើយប្រហែលជាមិនទាន់បើកមុខទេ ។ ដៃដែលចងស្ពាបសេក ឬដាក់ខ្នោះទៅក្រោយនេះក៏អត់ទាន់ស្រាយដែរ ។ ដល់គ្រប់ចំនួនអស់ហើយបានគេបញ្ចេញមួយម្ដងៗ ។ នេះសូមជម្រាបបញ្ជាក់ជូនប៉ុណ្ណេះ ។

[១១:២៩:៣៨]

**សៈ** គេយកអ្នកទោសទៅជើងឯកនោះច្រើននៅពេលយប់ ឬពេលថ្ងៃ?

**សៈ** ជម្រាបប្រសាសន៍លោកចៅក្រម បើតាមការសន្និដ្ឋានរបស់ខ្ញុំគឺ សុទ្ធសាច់គឺពេលយប់ ។

**សៈ** នៅពេលអ្នកទោសដាក់ចូលទៅក្នុងផ្ទះឈើនោះហើយ តើមានបញ្ឆេះម៉ាស៊ីនភ្លើងទេ?

**ផៈ** ជម្រាបប្រសាសន៍លោកចៅក្រម! ត្រង់បញ្ហានេះខ្ញុំសូមឆ្លើយថា ខ្ញុំទៅម្តង ខ្ញុំគ្មានឃើញម៉ាស៊ីនភ្លើងបញ្ឆេះទេ ខ្ញុំឃើញពិលព្រោងព្រាតនៅៗកន្លែងដែលឃុំអ្នកទោសនោះ ។ ហ្នឹងខ្ញុំសូមឆ្លើយប៉ុណ្ណេះ ។ ដូច្នេះ សរុបមក ខ្ញុំមិនជឿថាមានម៉ាស៊ីភ្លើងនៅជើងឯក ។

**សៈ** នៅពេលគេយកអ្នកទោសនោះចេញពីផ្ទះឈើនោះ តើមានគេប្រើពាក្យសម្តីថាទៅផ្ទះផ្សេងមួយទៀតទេ?

**ផៈ** ខ្ញុំជឿថាគេប្រើៗ ចៀសមិនរួចពីភរទេ ។

**សៈ** នៅពេលដែលចេញពីផ្ទះនោះតើមានអ្នកចាំកត់ឈ្មោះអ្នកនោះ មុននឹងយកទៅដល់រណ្តៅ?

**ផៈ** ជម្រាបប្រសាសន៍លោកចៅក្រម! ខ្ញុំជឿថាមានៗ ។ ថ្វីត្បិតតែខ្ញុំមិនល្អិតមិនបានតាមដានរឿងនេះ ខ្ញុំជឿថាមាន ។

**សៈ** តើមានគេឲ្យជនជាប់ចោទអង្គុយលុតជង្គង់ ដៃជាប់ខ្នោះ ភ្នែកនៅចង ហើយគេវាយអ្នកទោសពីក្រោយកញ្ជឹងក ដួលចូលទៅក្នុងរណ្តៅ បន្ទាប់មកបានត្រូវដោះខ្នោះ តើមានអ៊ីចឹងទេ?

**ផៈ** ជម្រាបប្រសាសន៍លោកប្រធាន រឿងហ្នឹងពិតៗ ។ ហើយតាមការដែល មិត្តហ៊ុយ គាត់និយាយនៅក្នុងការថតកុនជាមួយ ឫទ្ធី ប៉ាន់ ហ្នឹង ពេលខ្លះគ្នាស្លាប់ហើយ វានៅលើមាត់រណ្តៅគាត់ធាក់ទម្លាក់បញ្ចូលទៅនេះទៀត បានៗដោះ ធាក់ទម្លាក់ទៅក្នុងនុ៎ងទៀត ។ នេះជម្រាបដោយត្រង់អ៊ីចឹងគឺរឿងហ្នឹងពិតទាំងអស់ ។

**ផៈ** លោកចាំបានទេថា ចាប់ពីលោកចាប់យកជើងឯកជាកន្លែងសម្លាប់អ្នកទោស ក្នុងមួយខែៗ តើនាំអ្នកទោសទៅជើងឯកហ្នឹងប៉ុន្មានដង ហើយប្រហែលប៉ុន្មាននាក់? លោកមានចាំទេ?

**ផៈ** ជម្រាបប្រសាសន៍លោកប្រធាន! ខ្ញុំអត់ចាំទេ ។

[១១:៣៣:៥៣]

**សៈ** លោកមិនទាន់បានបញ្ជាក់អម្បាញ់មិញថា នៅពេលដែលគេវៃទៅលើអ្នកទោសនោះ តើគេវៃនឹងស្អី?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! រឿងនេះខ្ញុំមិនជាក់ស្តែងទេ ។ ក៏ប៉ុន្តែ នៅអមលាំង គេវ៉ៃនឹងគល់ឃ្លៃ ឬស្សីឃ្លៃ នេះខ្ញុំដឹងច្បាស់ ។ ហើយចូលមកដល់នៅស-២១ នេះ ដូចខ្ញុំបានរាយការណ៍ជម្រាបអង្គសវនាការយើងហើយ ដំបូង ណាត គាត់អួតពីវិធីចាក់សរសៃឈាមត្រង់នេះៗ ចាក់នឹងកាំបិតស្នៀតនៅនឹងសរសៃឈាមគល់កនេះ ។ ដល់ក្រោយមកឮ មិត្តហ៊ុយ និយាយ គឺគេវ៉ៃនឹងដែកភ្លៅរទេះ ។

**ស៖** តើឧបករណ៍វ៉ៃនោះ ទៅយកពីស-២១ទៅ ឬក៏អ្នកប្រចាំការនោះគេរក្សាឧបករណ៍នេះសម្រាប់ធ្វើដូច្នេះជារួចជាស្រេចហើយ?

[១១:៣៥:០៥]

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! រឿងនេះខ្ញុំចូលក្នុងសន្និដ្ឋានទៀតហើយ គឺឧបករណ៍នោះអាចនៅរក្សាទុកនៅជើងឯកឯណោះឯង ។

**ស៖** លោកនៅចាំបានទេថា សុន សេន, នួន ជា បានបញ្ជាឲ្យលោកអនុវត្តការសម្លាប់អ្នកទោសតាមលក្ខណៈទ្រង់ទ្រាយធំមានប៉ុន្មានលើក?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ពីលើកមុនខ្ញុំគិតថាមានបីលើក នេះតាមខ្ញុំចាំ ហើយខ្ញុំបានរាយការណ៍ជូនចៅក្រមជំនុំជម្រះ អ៊ូ!នែ៎ ចៅក្រមស៊ើបអង្កេត ។ ឥឡូវវាថែមមួយលើកដែលមាននៅក្នុង បញ្ជី D159/4.10 នេះទៀត ទាំងអស់បួនលើកទៅហើយ ពីលើកមុនបី អាលើកនេះមួយទៀតវាបួន ។

**ស៖** តើលោកមានបានចាំទេ តើលើកទីមួយនៅថ្ងៃណា ខែណា ឆ្នាំណាដែរ? ហើយលើកទីពីរលើកទីបី លើកទីបួន?

**ឆ៖** លើកទីមួយ នៅដើមឆ្នាំ១៩៧៧ នៅពេលដែលចាប់ កុយ ធួន មកហើយ កុយ ធួន ឆ្លើយដាក់ ។ ហើយអចិន្ត្រៃយ៍ប្រមូលកម្មាភិបាលរបស់ភូមិភាគឧត្តរចាស់នេះ ប្រមូលកម្មាភិបាលនៅភ្នំពេញហើយទៅប្រមូលកម្មាភិបាលមកពីខាងឧត្តរ មកពីខាងភូមិភាគកណ្តាលទៀត ។ ដូច្នេះ មួយលើក ហ្នឹងធំច្រើន ។ ដើម្បីបញ្ចូលមនុស្សថ្មីមកច្រើនយ៉ាងដូច្នេះ ត្រូវតែបញ្ចេញមនុស្សចាស់ នៅក្នុងនេះឲ្យអស់ចេញ ។ នេះលើកទីមួយ ។ ដូច្នេះគឺនៅក្រោយថ្ងៃដែល កុយ ធួន ឆ្លើយ ដូច្នេះក្រោយថ្ងៃ កុយ ធួន ឆ្លើយប្រហែលជាថ្ងៃ៣១ ខែ០១ ឬក៏៣១ ខែ១២ ឆ្នាំ១៩៧៥ អេ៎ (សុំទោស) ប្រហែលជាអាចថ្ងៃ៣១ ខែ១២ ឆ្នាំ១៩៧៦ ប៉ុននុ៎ង។ ដូច្នេះ នៅចុង១៩៧៦ ដើម១៩៧៧ បញ្ចូលមកហើយ បញ្ចូលច្រើន ។ ដូច្នេះ

ដើម១៩៧៧ នេះបញ្ចេញច្រើនដែរ នេះលើកទីមួយ ។

[១១:៣៨:១០]

លើកទីពីរប្រហែលជាពួក៩២០ នេះ នេះជាលើកទីពីរ ចូលមកមួយរយនាក់ ។ ចូលមកមួយរយនាក់ ចូលមកនៅហ្នឹងបានតែដប់ថ្ងៃទេ ។ សូមបញ្ជាក់ជូនលោកចៅក្រមថា កងពល៩២០ នេះក៏ជាកងពលកំណើតមកពីខាងភូមិភាគឧត្តរចាស់ដែរ ។ ដោយសាររឿងចម្លើយ ដោយសាររឿងអី ដោយ-សារស្អីផ្សេងទៀតហ្នឹង ដែលបានចាប់គ្នាមកមួយរយនាក់ទាំងប្រុស ហើយឲ្យស-២១ បញ្ចេញទៅទាំងឈុតភ្លាម នេះលើកទីពីរ ។ អ៊ូ! ប្រាំលើក ។

លើកទីបី នៅពេលដែល នៅក្នុងឆ្នាំ១៩៧៧ ប្រហែលជាក្នុងខែ៤ មុននឹងចាប់កម្មាភិបាលពួកបស្ចិម ប្រហែលជាក្នុងខែ៤ ហើយបញ្ចេញទៅមួយលើកទៀត ។ អ្ហឺ! ខ្ញុំច្រឡំលើកអស់ហើយ មើលលើកទីមួយពីកាលដើមឆ្នាំ១៩៧៧ ។ លើកទីពីរ កម្មាភិបាលពួក៩២០, មួយរយនាក់នេះ ។ លើកទីបីរវាង ខែ៤ ឆ្នាំ១៩៧៨ នៅពេល មុនពេលចាប់ ជូ ជេត ហៅស៊ី ។ លើកទីបួន មុនពេលចាប់កម្មាភិបាលភូមិភាគពាយ័ព្យ ។ លើកទីប្រាំ ចុងក្រោយគេ គឺពួកបូព៌ាដែលមកមិនបាច់សួរនោះ ។ ដូច្នេះ ប្រាំលើកដែលបញ្ចេញទាំងឈុតៗនេះ ប្រាំលើក ។

[១១:៤០:១០]

**ស៖** តើលោកមានចាំទេ លើកទីមួយនោះ អ្នកទោសប្រហែលមានចំនួនប៉ុន្មាននាក់? ហើយប្រភេទអ្នកទោសនោះមានជារដ្ឋការ មន្ត្រីរបស់ លន់ នល់ ដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! មកដល់ក្នុងខែ១ ឆ្នាំ១៩៧៧ រដ្ឋការ លន់ នល់ មានតិចណាស់ ។ ដូច្នេះ បើមានបញ្ចេញនៅពេលនោះ ទៅជាមួយនឹងគេក្នុងឈុតនោះក៏តិច នេះលើកទីមួយ ។ សូមបញ្ជាក់ជូនលោកចៅក្រមប៉ុណ្ណេះ ។

**ស៖** មានចាំចំនួនប្រហាក់ប្រហែលទេ លើកទីមួយហ្នឹង ប្រហែលជាប៉ុន្មាននាក់ដែរ?

**ឆ៖** មិនចាំទេ ប៉ុនគ្រាន់តែសុំសន្និដ្ឋានប្រហែលទៅចុះ យ៉ាងតិចក៏មួយរយដែរ ។

**ស៖** ចុះនៅលើកទីពីរ?

**ឆ៖** លើកទីពីរគឺមួយរយនាក់ត្រឹម ដូចឃើញនៅក្នុងឯកសារ 159/4.10ហើយ មួយរយនាក់។

**ស៖** លើកទីបីនៅថ្ងៃទី ខែ១២ ឆ្នាំ១៩៧៨?

**ឆ៖** នេះលើកទីប្រាំហើយលោកចៅក្រម ។ ខែ១២ ឆ្នាំ១៩៧៨ លើកទីប្រាំហើយ ។ លើកទីពីរ ប្រហែលជានៅក្នុងខែ២ ឆ្នាំ១៩៧៧ មួយរយនាក់ជាងដែរ ។

**ស៖** លើកទីបី?

**ឆ៖** លើកទីបី លើកទីមួយ នៅខែ១ ឆ្នាំ១៩៧៧ ។ លើកទីពីរ ខែ១១ ឆ្នាំ១៩៧៧ ចប់ត្រឹមថ្ងៃ២ ខែ១២ ឆ្នាំ១៩៧៧ ។ លើកទីបី ប្រហែលជានៅក្នុងខែ២ អ្ហឺ! ច្របូកច្របល់ហើយ មិនដឹងអាណាទីបី អាណាទីពីរ ទេ អាលើកទីបី ឬក៏ទីពីរមិនដឹងមួយរយប្លាយនាក់ មួយរយសែសិបប្លាយ មួយរយហាសិប នៅក្នុងខែ២ ឬខែ១ ឆ្នាំ១៩៧៨ ហ្នឹងលើកទីបី ។ លើកទីបួនរវាងខែ៤ ឆ្នាំ១៩៧៨ មួយសាទៀត ហើយបានចុងបញ្ចប់លើក ក្រោយនេះគឺ ខែ១២ ឆ្នាំ១៩៧៨ ។ នេះសូមជូនប៉ុណ្ណេះ ថ្ងៃខែច្របូកច្របល់ហើយ សុំទោស ។ ប៉ុន្តែ ការបញ្ចេញទៅទាំងឈុត គឺប្រាំលើកនេះឯង មិនខ្វះទេ មានតែលើសមួយលើកទៀត ផងមិនដឹង ខ្ញុំអត់បាន សរុបគិតគូរអីហ្នូរហែមកទេពីមុនមក ។

**ស៖** ខែ៣ ប្រហែលជាចំនួនមនុស្ស បីរយនាក់ ដែលយកពីបូព៌ាមកហ្នឹងមែនទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម មនុស្សយកពីបូព៌ាមកបីរយជាង។ ដូច្នេះ ខែ១១ មិនដឹង ខែណាទេ ប្រហែលជាខែ១០ ឬខែ១១ ឆ្នាំ១៩៧៨ ។

[១១:៤៥:២៣]

**ស៖** ចុះនៅថ្ងៃទី២ ឬទី៣ ខែ១ ឆ្នាំ១៩៧៩នោះ? អ្នកទោសត្រូវបានកម្ទេចប៉ុន្មាននាក់ដែរ?

**ឆ៖** អស់ហើយថ្ងៃ ខែ២ ខែ៣ ហ្នឹងអ្នកទោសនៅសល់ប៉ុន្មានឲ្យកម្ទេចទាំងអស់អត់មានឲ្យ សល់ទេ។ ដូច្នេះ សល់ប៉ុន្មាននាក់ដែលខ្ញុំទុកហ្នឹង សល់៤នាក់សម្រាប់សួរចម្លើយ ហើយសល់ដប់ប្រាំ នាក់សម្រាប់ជួយការងារ ។ ដូច្នេះ ដប់ប្រាំបួននាក់ ។

**ស៖** ក្នុងយុទ្ធនាការទ្រង់ទ្រាយធំនេះ ឃើញថាអ្នកទោសបានយកទៅសម្លាប់ហ្នឹងមានចំនួនច្រើន លោកបានបញ្ជាក់អម្បាញ់មិញថា អ្នកប្រចាំការនៅទីនោះមិនបានដំណឹងជាមុន តើរណ្តៅវាគ្រប់គ្រាន់ នឹងចំនួនមនុស្សដែលច្រើនលើសលប់នេះទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! រណ្តៅអាចក្នុងពេលយុទ្ធនាការច្រើនរបៀប ដូចនេះ យកចេញពី ភ្នំពេញទៅបណ្តើរ ហើយជីករណ្តៅថែមបណ្តើរ ។ ដូច្នេះ មិនមែនធ្វើមួយថ្ងៃឲ្យអស់ទាំង អស់ទេ ប៉ុន្តែជា គោលការណ៍ត្រូវតែធ្វើឲ្យអស់ ។ ដូច្នេះ វាសកម្មភាពវាអាចបត់បែន ក៏ប៉ុន្តែ ទិសដៅ កម្ទេចត្រូវតែឲ្យអស់ ។ នេះសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

**ស៖** យុទ្ធនាការធំម្តងៗ តើប្រើពេលប៉ុន្មានថ្ងៃដើម្បីចប់បេសកកម្មនេះ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ខ្ញុំមិននិយាយបានជាទូទៅទេ ក៏ប៉ុន្តែ ឯកសារច្បាស់នៅហ្នឹងដែលយើងរាល់ថ្ងៃនេះ គឺឯកសារលេខ159/4.10 បញ្ជាច្បាស់លាស់គឺថ្ងៃ២៦ ខែ១០ ឆ្នាំ១៩៧៧ ។ គ្នាមួយរយនាក់នេះ គេធ្វើរហូតដល់ថ្ងៃ២ ខែ១២ ឆ្នាំ១៩៧៧ ចប់ ។ ដូច្នេះពីថ្ងៃ ២៦,២៧,២៨,២៩,៣០,០១,០២ ប្រាំមួយថ្ងៃសម្រាប់គ្នាមួយរយនាក់នេះបានចប់ ។

**ស៖** បើថ្ងៃជាប់គ្នាដូច្នេះ តើគេមានដឹកអ្នកទោសនៅពេលថ្ងៃទេពេលនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! បើដឹកក៏ដឹកតិចដែរ ខ្ញុំមិនសូវជឿរឿងដឹកថ្ងៃទេ ។ យថាហេតុបែកការណ៍មិនប្រាកដថា មិនបែកដឹកថ្ងៃ ។ នេះសូមជម្រាបបញ្ជាក់ប៉ុណ្ណោះ ។

[១១:៤៨:៣៥]

**ស៖** តើមានគេបន្ថែមកម្លាំង សម្រាប់កម្ទេចអ្នកទោសនោះថែមទៀតទេក្នុងយុទ្ធនាការធំៗអ៊ីចឹង?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! អាចបន្ថែមយកពីកងការពារជ្រើសរើសយកមកបន្ថែមឲ្យពួកកងពិសេស ។ កងការពារ និងកងពិសេសបន្ថែមគ្នាទៅវិញទៅមកបាន។

**ស៖** សូមលោកបញ្ជាក់មកមើល ថាតើលោកបានចុះទៅផ្ទាល់ នៅជើងឯកហ្នឹងប៉ុន្មានលើក? នៅពេលណា? ជាមួយអ្នកណា? ហើយជាពេលដែលកំពុងមានសកម្មភាពវាយមនុស្សចោលទេ នៅពេលនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ខ្ញុំទៅជើងឯកនេះទៅម្តងដែលមេណែនាំទៅ។ មូលហេតុរឿងនេះ ខ្ញុំមិនៗ ក្រាញបន្តិចដែរ ក្រាញមិនទៅ គាត់តឿនលើកទីបី បានខ្ញុំសុខចិត្តទៅ ។ ខ្ញុំទៅហ្នឹងគ្រាន់តែបង្គ្រប់កិច្ចទេ ។ ដូច្នេះ ក្នុងប្រតិបត្តិការស-២១ ទាំងមូលនេះ ខ្ញុំទៅមើលនៅជើងឯកបានម្តង ហើយមើលនៅភ្នំពេញ អាហ្នឹងឃើញច្បាស់នឹងភ្នែកតែហ្នង បានម្តង ។ ឯចំណែក ទៅជើងឯក ខំគេចឲ្យខ្ទងទៅតែម្តងហ្នឹងឯងទេ ។ នេះសូមបញ្ជាក់ជូនថា ទៅតែម្តង នៅជើងឯក ។

**ស៖** ក្នុងន័យថា មេលោក បញ្ជាឲ្យលោកទៅជើងឯកហ្នឹង ក្នុងគោលបំណងគាត់ចង់ដឹងពីអីនៅជើងឯកនោះ?

**ឆ៖** ខ្ញុំសូមរាយការណ៍រឿងនេះឲ្យវែងបន្តិចចុះ ដើម្បីឲ្យអស់បញ្ហា ។ រឿងនេះ វាជាគេហៅថាល្បែងអផ្សុករបស់ ប៉ុល ពត ក៏ថាបានដែរ ថាគេវាប្រយ័ត្នរបស់គេក៏ថាបាន ។ មិននៅៗ គាត់ឲ្យលោកគ្រូ សុន សេន មកត្រួតពិនិត្យស-២១ គាត់ឲ្យខ្ញុំត្រៀមរៀបចំមុន ពេលដែលចុះមកដល់ហ្នឹង គាត់អត់

មានទៅមើលស្អីទេ គាត់ចុះតែពីឡានមក យកក្រមាដាក់ពីលើកាស្កិតគាត់ទៅទៀត គាត់ឈរនៅមុខផ្លូវចូលរបស់ស-២១ហ្នឹង ផ្លូវចូលរបស់វិទ្យាល័យពញាយ៉ាតហ្នឹង ។ គាត់ចុះពីឡានមក មិត្តហ៊ា ហើយនិងខ្ញុំ នៅហ្នឹងដីហ្នឹង ចាំទទួលគាត់ ទាំងអស់គ្នាក្រញ្ញេបក្រញ្ញោបទាំងពីរនាក់ហ្នឹង ទៅដល់គាត់ចុះពីឡានមកគាត់មើលនាយ មើលមួយសន្ទុះ គាត់ថា អ្អឺ! បង ប៉ុល ចង់មកខ្លួនឯង ។ ប៉ុន្តែ ខ្ញុំធានាថាមក ខ្ញុំមកនេះសម្តីរបស់លោកគ្រូ សុន សេន ប៉ុណ្ណឹង ។ និយាយបានតែពីរបីម៉ាតប៉ុណ្ណឹង គាត់ថា អ៊ឺះ! ទៅហើយណ៎ា លាហើយ គាត់ក៏មកបាត់មក ។ នេះខ្ញុំឃើញគំរូនេះមួយ ។

[១១:៥១:៥៧]

ដល់មួយទៀត គាត់តឿនឲ្យខ្ញុំទៅមើលគេពិឃាតមនុស្សនៅហ្នឹង ស-២១ ហ្នឹង ពិឃាតឈ្មោះ សួស នៅ ហៅ ឈូក ហើយនិងពិឃាតឈ្មោះ ជ័យ សួន នេះ ហ្នឹងព្រឹត្តិការណ៍ទីពីរ ។ ហើយដល់ព្រឹត្តិការណ៍ទីបី គាត់ឲ្យគេថត គាត់ឲ្យគាស់សព លី ផែល យកមកថត គ្នាស្លាប់ទៅហើយ បីថ្ងៃហើយ ឲ្យគាស់គ្នាយកមកថត ។ ខ្ញុំសរុបទាំងអស់មក ឃើញថា អ្អឺ! ប៉ុល ពត ឬក៏ សុន សេន មិនទុកចិត្តណាត ហើយក៏មិនទុកចិត្តស-២១ អ៉ំ!នែ កងពល៧០៣ សុទ្ធតែម្តង បានជាបញ្ជាឲ្យធ្វើអ៊ីចឹង ។ ដូច្នេះអារឿងបញ្ហានេះ យើងថា ល្បែងអផ្សុករបស់គេ ក៏ថាបាន យើងនិយាយថា គេវាប្រុងប្រយ័ត្ន គេមិនទុកចិត្ត សមាសភាព៧០៣ ដែលនៅជាមួយនឹងខ្ញុំ ក៏ថាបានដែរ បានជាគេចេះតែឲ្យខ្ញុំទៅត្រួតពិនិត្យដិតដល់ ត្រួតពិនិត្យដិតដល់ហួរហែហ្នឹង ។

នេះខ្ញុំសូមរាយការណ៍តាមវិភាគ និងតាមសន្និដ្ឋានប៉ុណ្ណេះ ។

[១១:៥៣:០០]

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវី មានអីហ្នឹង? អញ្ជើញលោក ហ្វ្រង់ស្វ័រ រូ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណ លោកប្រធាន ។ ខ្ញុំចង់និយាយបន្តិច ទាក់ទងទៅនឹងការបកប្រែជាភាសាបារាំង ។ ខ្ញុំគិតថា យើងបានបាត់ឃ្លាខ្លះ នៅក្នុងការបកប្រែជាភាសាបារាំង គឺមិននិយាយថា ប៉ុល ពត បានមកពិនិត្យមើលស-២១ ប៉ុន្តែ ខ្ញុំមិនគិតថា នេះជាអ្វីដែលជនជាប់ចោទ បាននិយាយទេ ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី ។ ដូច្នេះ សូមរំឭកអ្នកបកប្រែ សុំប្រឹងប្រែងក្នុងការបកប្រែឲ្យបានល្អ

ប្រសើរ ហើយចៀសវាងការបាត់ ។ អំមិញ បើថា ដូច្នោះមែន គឺអាចច្រឡំហើយ ព្រោះជាការប៉ុនប៉ង ប៉ុន្តែមិនមែនទេនែ ។ ហើយទីពីរ ប្រសិនបើមានសំណួរលឿន ឬក៏ដែលអាចមិនអាចបកប្រែទាន់ សូមផ្តល់មកផ្តល់ដំណឹងមកខ្ញុំ ដើម្បីខ្ញុំរំឮកដល់អ្នកដែលមាននិយាយហ្នឹងឯង ដើម្បីឲ្យគាត់បន្ថយនូវល្បឿនក្នុងការនិយាយ ដែលមានដោយ ឲ្យមានលទ្ធភាពអាចស្តាប់បាន ហើយនិងអាចបកប្រែបានត្រឹមត្រូវ ។

អញ្ជើញ លោកចៅក្រមតទៀត ។

**សួរដោយចៅក្រម យ៉ា សុខន៖**

**ស៖** នៅពេលលោកចុះទៅជើងឯកនោះ លោកមានបានចូលទៅមើលរណ្តៅសាកសពទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! រឿងខ្ញុំបាទ ទៅជើងឯក ខ្ញុំទៅតែមួយភ្លែតទេ បង្គ្រប់កិច្ច របៀបដូច សុន សេន គាត់មកមុខទូលស្តែងអ៊ីចឹង ដើម្បីបង្គ្រប់កិច្ច ។ សូមបញ្ជាក់ម្តងទៀត ខ្ញុំទៅជើងឯកទៅតែម្តងគត់ អត់បានទៅអង្គុយមើល ឬក៏អើតមើលរណ្តៅទេ គឺទៅតែមួយភ្លែត តាមរបៀបដែល សុន សេន គាត់មកទូលស្តែងអ៊ីចឹង ខ្ញុំទៅតែមួយភ្លែត គាត់មកមួយភ្លែត ខ្ញុំក៏ទៅជើងឯកតែមួយភ្លែតដែរ ។

**ស៖** សុន សេន បានបញ្ជាឲ្យលោកចុះទៅជើងឯក ក្នុងន័យទៅត្រួតពិនិត្យមើល ហើយលោកបានបញ្ជាក់អម្បាញ់មិញថា លោកទៅតែមួយភ្លែត តើលោកបកស្រាយយ៉ាងម៉េចដែរចំពោះបញ្ជារបស់ថ្នាក់លើ?

[១១:៥៧:០២]

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! រឿងទៅជើងឯកនេះ ខ្ញុំទៅខ្លីមែន ខ្ញុំអត់បានមើលរណ្តៅ ខ្ញុំអត់បានអើតចូលទៅក្នុងផ្ទះ ដែលគេឃុំឃាំងជនរងគ្រោះជាបណ្តោះអាសន្នមុននឹងយកទៅប្រហារជីវិតទេ ព្រោះគោលបំណងធ្វើម៉េច កុំឲ្យតែខាងពួក៧០៣ ដោះលែងមនុស្សបាន ។ ដូច្នេះ ខ្ញុំគិតថា មួយឆ្នាំវាមាន៣៦៥ថ្ងៃ ខ្ញុំទៅមួយឆ្នាំបានដប់ដង ក្នុងមួយដងមួយថ្ងៃ ក៏មិនអាចទប់គេបានដែរ ។ បើសិនជាគេចង់ដោះលែង បើសិនជាគេចង់ដោះលែង យើងទៅមួយឆ្នាំដប់ថ្ងៃ ក៏យើងទប់គេមិនជាប់ ។ ប៉ុន្តែ ខ្ញុំជឿថា គេធ្វើការគេចង់រស់ដែរ គេខ្លាចងាប់ ដូច្នេះ គេមិនហ៊ានដោះលែងទេ ដូច្នេះវាមិនត្រូវការអីចាំបាច់ខ្ញុំទៅមើលគេទេ ។ ដូច្នេះ បានជាខ្ញុំទៅតែមួយភ្លែតបង្គ្រប់កិច្ច ភាសាខ្មែរយើងហៅបង្គ្រប់កិច្ច ។ ហើយមកដល់បើតាមខ្ញុំចាំ ពេលនោះមេមិនទាំងសួរផង ហើយបើសិនជាមេសួរវិញ ខ្ញុំបានត្រៀមហើយ ខ្នោះដែលគេដាក់ខាងក្រោមហ្នឹងយ៉ាងម៉េច? របងដែលគេធ្វើជុំវិញហ្នឹងយ៉ាងម៉េច? ដូច្នេះ ចំណុចពីរ

ហ្នឹង ដែលខ្ញុំបានគិតថា បើសិនជាមេសួរ ឆ្លើយអាហ្នឹង ។ របងខ្ញុំបានដឹងដំណឹងជាហូរហែហើយ ដល់ពេលចុះពីឡានទៅ ខ្ញុំអើតមើលទៅឃើញរបងជុំវិញអ៊ីចឹងមែន ។ ហើយខ្មោះអីៗ កងអី ដែលគេដាក់មនុស្សនោះ ខ្ញុំអត់បានទៅអើតមែន។ ក៏ប៉ុន្តែ ខ្ញុំដឹង ដោយមិត្តហ៊ី ខ្ញុំដេញដោលសួរមិត្តហ៊ី ពីមុនមកយូរហើយ ។ រួចបើគាត់សួរខ្ញុំទៀតថា មិត្តឯង មានទៅចាំមើលគេទេ ខ្ញុំថា ខ្ញុំឃើញគេបណ្តើរពីក្រោយខ្នងខ្ញុំហ្នឹង ម្នាក់ ហើយខ្ញុំចេញមកបាត់មក ។ ហើយជាគោលការណ៍ ខ្ញុំដឹងទៀតថា នៅកន្លែងនោះ គេយកបញ្ចេញម្តងម្នាក់ យកទៅកម្ទេច យកទៅសម្លាប់ហើយ ដល់សម្លាប់ហើយ បានទៅយកម្នាក់មកទៀត ។ នេះខ្ញុំគិតហើយស្រេច ប៉ុន្តែមេគាត់មិនសួរ ក៏ហីទៅ នេះជម្រាបដោយត្រង់អ៊ីចឹង ។

**ស៖** តើលោកបានដឹងពីចំនួនរណ្តៅកប់សពនៅជើងឯកនោះទេ ចំនួនប៉ុន្មានទេ?

**ឆ៖** ខ្ញុំអត់បានដឹងទេ ជម្រាបប្រសាសន៍លោកចៅក្រម ។

**ស៖** អ្នកប្រចាំការមិនបានរាយការណ៍ប្រាប់លោកទេ?

**ឆ៖** រឿងនេះ បើនិយាយអំពីសិទ្ធិអំណាចរបស់ខ្ញុំ អាចត្រួតត្រា អាចដឹង អាចដេញដោលសួរអីទាំងអស់ ។ ក៏ប៉ុន្តែ ខ្ញុំមិនបានដេញដោលសួរគេ គឺអត់ទៅសួរអ្នកប្រចាំការទេ គឺត្រូវសួរមិត្តហ៊ី នេះគឺខ្ញុំអត់បានសួរ ។

**ចៅក្រម យ៉ា សុខន៖**

ខ្ញុំសូមអស់សំណួរលោកប្រធាន ។

[១២:០៣:៣៨]

**ប្រធានអង្គជំនុំ៖**

ដល់ពេលម៉ោង ត្រូវពិសារអាហារថ្ងៃត្រង់ហើយ តើមានអ្វីត្រូវសួរអ្វីទៀតទេលោកស្រីចៅក្រម? លោក ហ្សង់ម៉ាក? សូមអញ្ជើញ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោកប្រធាន ខ្ញុំជឿថា យើងអាចឈប់សម្រាកពេលអាហារថ្ងៃត្រង់ ប៉ុន្តែខ្ញុំអាចសុំឲ្យធ្វើការបំភ្លឺចំពោះសំណើរបស់សហព្រះរាជអាជ្ញា ដែលបានលើកឡើងព្រឹកមិញនេះ ។ លោកសហព្រះរាជអាជ្ញាបានដាក់សៀវភៅរូបភាព ហើយលោកមានបំណងចង់ឲ្យបង្ហាញរូបភាពទាំងអស់នេះ នៅក្នុងសវនាការរបស់យើង ។ ហើយលោកអាចនឹងមានបំណងចង់ប្រើប្រាស់រូបភាពមួយចំនួនក្នុងពេលដេញដោលជនជាប់ចោទ ឬក៏លោកចង់ប្រើក្នុងការបង្ហាញភស្តុតាង នៅមុខអង្គសាលាដំបូងក្នុងលក្ខណៈទូទៅ គឺលោក

លើកឡើង អំពីរយៈពេល២៥ ចំពោះបទបង្ហាញរបស់លោក ។ តើខ្ញុំយល់ត្រឹមត្រូវដែរឬទេ?

**លោក វីលៀម ស្មីត៖**

សូមអរគុណ លោក លោកស្រីចៅក្រម ។ ខ្ញុំទុកឲ្យលោក លោកស្រីចៅក្រម សម្រេចទៅលើរយៈពេលកំណត់នោះ ។ សហព្រះរាជអាជ្ញាចង់បញ្ជាក់ឲ្យច្បាស់ថា ឯកសារបីដែលយើងចង់ដាក់នោះគឺទាក់ទងទៅនឹង ទីមួយ សៀវភៅរូបភាព ។ សៀវភៅរូបភាពនោះ មាននៅក្នុងសំណុំរឿងយើងហើយ សៀវភៅរូបភាពនោះ គឺទាក់ទងទៅនឹងទីតាំង កន្លែងឃុំខ្លួន ហើយវាមានលេខឯកសារ E51.1 ដល់ E51.2 ។ ហើយចំពោះសៀវភៅរូបភាពនោះ ធ្វើយ៉ាងណាយើងខ្ញុំចង់ដាក់ជូនមុខអង្គសវនាការ ឲ្យបានត្រឹមត្រូវទៅតាមសេចក្ដីណែនាំ ដែលបានសម្រេចកាលពីថ្ងៃពុធ អាទិត្យមុន ។ ទីពីរ សៀវភៅរូបភាពទាក់ទងទៅនឹងជើងឯក ហើយរូបភាពដែលមាននៅក្នុងនោះវាទាក់ទងទៅនឹងប្រតិបត្តិការស-២១ហើយវាបានបង្ហាញអំពីឧបករណ៍ធ្វើទារុណកម្ម សម្លៀកបំពាក់ និងភស្តុតាងផ្សេងៗទៀត ដែលវាទាក់ទងទៅនឹងឧក្រិដ្ឋកម្ម ។ ហើយយើងចង់ធ្វើយ៉ាងណា ចង់បង្ហាញទៅលើសៀវភៅរូបភាពនោះ ឲ្យបានត្រឹមត្រូវនៅចំពោះមុខអង្គសវនាការ យោងតាមវិធាន៨៧.២និង៣ ។ ហើយឯកសារ E63.1 និង E 63.18 សហព្រះរាជអាជ្ញាក៏ចង់បញ្ជាក់ថា វាជាបញ្ជីអ្នកទោសដែលបានកែប្រែ ហើយវាមានឧបសម្ព័ន្ធ៥១ភ្ជាប់មកជាមួយ ហើយវារាប់អំពីចំនួនអ្នកទោសផ្សេងៗ និងប្រភេទអ្នកទោស ហើយក៏បានរៀបរាប់រយៈពេលនៃការចាប់ខ្លួន ឃុំខ្លួន និងការសម្លាប់ ហើយយើងខ្ញុំចង់ដាក់ឯកសារនេះនៅមុខអង្គសវនាការ។ ឯកសារនោះគឺ E68.1 ដល់ 5 ហើយសហព្រះរាជាអាជ្ញា យើងដឹងថា ឧបសម្ព័ន្ធមួយចំនួននោះ គឺបានបង្ហាញនៅក្នុងសវនាការហើយ។ ហើយឧបសម្ព័ន្ធមួយចំនួនទៀត មិនបានបង្ហាញនោះទេ។ ហើយឧបសម្ព័ន្ធទាំងអស់នេះវាស្រដៀងទៅនឹងរូបភាព ដែលលោក លោកស្រីចៅក្រមបានបង្ហាញហើយ ប៉ុន្តែរូបភាពនិងឯកសារមួយចំនួនមិនទាន់បានបង្ហាញ ។ ហើយយើងក៏ចង់បង្ហាញជាមួយនឹងសាក្សី នៅពេលដែលពួកគាត់ចង់មកផ្ដល់សក្ខីកម្ម និងជាមួយជនជាប់ចោទផងដែរ ។

រូបភាពទាំងអស់នោះ គឺបានបង្ហាញភស្តុតាង អំពីឧក្រិដ្ឋកម្ម ដែលបានដេញដោលនៅក្នុងសវនាការរបស់យើង ជាពិសេសទាក់ទងទៅនឹងការ ដឹងរបស់ជនជាប់ចោទ ទាក់ទងទៅនឹងបញ្ហាជនរងគ្រោះ ហើយវាទាក់ទងទៅនឹងការ ដែលយើងចង់ដាក់រូបភាពមួយចំនួន និងឧបសម្ព័ន្ធមួយចំនួននៅចំពោះមុខសាក្សី ។ ហើយយើងចង់ឲ្យអង្គសវនាការពិចារណាទៅលើបញ្ហានេះ ។ នេះគឺជាសំណើរបស់សហព្រះរាជអាជ្ញា ។ នៅពេលដែលសាធារណជន បានឃើញអំពីឧបសម្ព័ន្ធ និងរូបភាពទាំងអស់នោះ

គឺយើងអាចធ្វើនៅពេលនេះក៏បាន ឬក៏យើងអាចធ្វើតាមដំណើរការដេញដោលភស្តុតាងរបស់យើង ។ ដូច្នេះ គឺខ្ញុំទុកឲ្យ លោក លោកស្រីចៅក្រម ធ្វើការសម្រេចទៅលើបញ្ហានេះ ។ សូមអរគុណ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ប្រសិនបើខ្ញុំយល់ឲ្យបានត្រឹមត្រូវនោះ គឺជនជាប់ចោទ គាត់ចង់ដឹងអំពីឯកសារដែលលើកឡើងអម្បាញ់មិញនេះ ទាក់ទងទៅនឹងឧបសម្ព័ន្ធ និងឯកសារផ្សេងៗ ថាធ្វើយ៉ាងណាសង្ខេបឲ្យបានត្រឹមត្រូវ ហើយដាក់ជូនដេញដោលនៅចំពោះមុខអង្គសវនាការ ដើម្បីទទួលយកដោយអង្គសវនាការអនុលោមតាមវិធានផ្ទៃក្នុងរបស់យើង ។

**លោក វីលៀម ស្មីត៖**

គឺត្រឹមត្រូវហើយ តាមសេចក្តីណែនាំ ដែលលោកស្រីចៅក្រម ខាតវ៉ាយថ៍ បានលើកឡើងនៅថ្ងៃពុធអាទិត្យមុន ។ ឯកសារនេះ គឺវាបានបង្ហាញយ៉ាងត្រឹមត្រូវ ។ យើងអាចបង្ហាញឯកសារ ដោយមិនចាំបាច់ធ្វើការអាន នៅក្នុងសវនាការទេ យើងអាចធ្វើការសង្ខេប ។ ហើយដូច្នេះ ហើយទើបខ្ញុំបង្ហាញអំពីលេខឯកសារ និងលេខ ERN និងចំណងជើង ។ ចំណុចសំខាន់ ការបង្ហាញដេញដោលភស្តុតាងរបស់យើងនោះ គឺវាកម្រិតទៅលើសេចក្តីណែនាំទាំងអស់នោះ ដើម្បីឲ្យសាធារណជនធ្វើការស្វែងយល់ទៅលើភស្តុតាង និងភាគីផ្សេងៗឲ្យគាត់បានយល់ផងដែរ ។ ឯកសារទាំងអស់នេះ គឺវាទាក់ទងទៅនឹងរូបភាព ហើយវាមិនមានការរៀបរាប់ផ្សេងៗនោះទេ ។ វាគឺជាការបង្ហាញភស្តុតាងសង្ខេប ដើម្បីធ្វើយ៉ាងណាឲ្យយើងដាក់ នៅចំពោះមុខអង្គសវនាការ អនុលោមតាមវិធាន៨៧.២ និង ៣ ។

[១២:១០:០៨]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ដូច្នេះ ការជំទាស់ដែលបានលើកឡើងមេធាវីការពារក្តី គឺវាអត់ទាក់ទងទៅនឹងការកំណត់ប្រភេទឯកសារទេ គឺឯកសារមួយចំនួននោះ គឺវាអាចមានភាពដែលវាមិនបានលើកឡើង អំពីអត្តសញ្ញាណរបស់សាក្សីនោះទេ ។ ដូច្នេះហើយ គឺខ្ញុំយល់ថា មេធាវីការពារក្តីហាក់ដូចជាមិនមានបញ្ហាទាក់ទងទៅនឹងឯកសារដែលសហព្រះរាជអាជ្ញាចង់ដាក់ជូននោះទេ ។

**លោក ហ្រ្វង់ស្វ័រ រូ៖**

ឆ្លើយតបទៅនឹងសំណួររបស់លោកចៅក្រម គឺវាមិនមានការពិបាកទេ ប្រសិនបើអង្គសវនាការផ្តល់ពេលវេលាឲ្យយើងឲ្យគ្រប់គ្រាន់ នៅពេលអាហារថ្ងៃត្រង់ ដើម្បីធ្វើការពិនិត្យទៅលើឯកសារទាំង

អស់នោះ ។ ចំណុចនេះ គឺវាអាចធ្វើឲ្យខ្ញុំមានភាពសមស្រប និងមានការរៀបចំគ្រប់គ្រាន់ ។

សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អរគុណ ។ ឥឡូវនេះ យើងដល់ពេលត្រូវពិសារអាហារថ្ងៃត្រង់ហើយ ។ អ៊ីចឹង អង្គជំនុំជម្រះប្រកាសសម្រាក ដើម្បីពិសារថ្ងៃត្រង់ រហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញវិញ បន្តដំណើរការនីតិវិធីសវនាការរបស់យើង ។

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទ ទៅកាន់កន្លែងបន្ទប់រង់ចាំ ហើយឲ្យនាំគាត់មកកាន់ទីនេះនៅវេលាម៉ោងមួយសាមសិបនាទី ។

*[សវនាការសម្រាកពីម៉ោង ១២:១១ នាទី ដល់ម៉ោង ១៣:៣៤នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការដេញដោលតទៅទៀត ។ មុននឹងចូលទៅការសួរដេញដោល ខ្ញុំសូមសួរទៅលោកមេធាវីការពារក្តីពាក់ព័ន្ធនឹងឯកសាររូបថតបញ្ជីឈ្មោះជនរងគ្រោះដែលមានការបំពេញបន្ថែម ដែលស្នើឡើងដោយសហព្រះរាជអាជ្ញាពីព្រឹកមិញនេះ តើលោកមេធាវីមានការកត់សម្គាល់យ៉ាងម៉េចដែរទេ?

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន យើងខ្ញុំបានពិនិត្យមើលលើឯកសារអស់ទាំងនេះ ហើយខាងមេធាវីការពារក្តីសូមឲ្យធ្វើការបញ្ជាក់ឲ្យបានច្បាស់លាស់ថា ឯកសារអស់ទាំងនេះ គឺគ្រាន់តែជាសេចក្តីដកស្រង់ដែលបានជ្រើសរើសឡើងដោយការិយាល័យសហព្រះរាជអាជ្ញា ។ ម្យ៉ាងវិញទៀត ឯកសារមួយចំនួនក្នុងឯកសារអស់ទាំងនេះ គឺជាការបញ្ចេញមតិយោបល់របស់សហព្រះរាជអាជ្ញា ជាពិសេសគឺឧបសម្ព័ន្ធទៅលើបញ្ជីឈ្មោះអ្នកទោសដែលត្រូវបានគេកែប្រែឡើងវិញ ដែលនៅក្នុងឧបសម្ព័ន្ធនោះសហព្រះរាជអាជ្ញាបានផ្តល់នូវការវិភាគមួយដែលសមស្របសម្រាប់ពួកគេ ។

ដូច្នេះបច្ចុប្បន្ននេះឯកសារនេះ គឺមិនមាននៅក្នុងដៃរបស់ខាងសហចៅក្រមស៊ើបអង្កេតនៅឡើយទេ ។ ដូច្នេះហើយ ខ្ញុំចង់ឲ្យធ្វើការបញ្ជាក់គ្រប់ពេលទាំងអស់នៅពេលដែលយើងធ្វើការពិភាក្សាឯកសារ

ណាមួយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ហើយនិង បើសិនជាឯកសារហ្នឹងគឺជាការវិភាគរបស់ខាងសហព្រះរាជអាជ្ញា គឺវាសមស្របសម្រាប់តែពួកគេតែប៉ុណ្ណោះ ពីព្រោះអីឯកសារហ្នឹងគឺមិនទាន់ត្រូវបានពិភាក្សាដេញដោលគ្នានៅឡើយទេ ។

នេះគ្រាន់តែជាសេចក្ដីអង្កេតចំនួនពីររបស់ខ្ញុំ ដែលខ្ញុំចង់ដាក់ជូនអង្គសវនាការ ។ ហើយនៅពេលនេះដែរ ក៏ខ្ញុំសូមការឆ្លើយតបផងដែរ ដោយសូមដាក់នៅចំពោះមុខអង្គសវនាការ សូមឲ្យអង្គសវនាការធ្វើការពិចារណាថា ឧបសម្ព័ន្ធ D45.1 នៅក្នុងសំណុំរឿងឯកសារស៊ើបអង្កេតត្រូវបានបញ្ជូននៅក្នុងដំណើរការនីតិវិធី នោះគឺជារបាយការណ៍របស់អ្នកជំនាញ ដែលជាអ្នកថតរូប ដែលបានបង្កើតឡើងទៅតាមសំណើរបស់សហព្រះរាជអាជ្ញា ហើយរបាយការណ៍របស់អ្នកជំនាញនេះ ខាងសហព្រះរាជអាជ្ញាបានដកស្រង់រូបថតតែមួយចំនួនតែប៉ុណ្ណោះ ។ ដូច្នេះ ខាងមេធាវីការពារក្ដីសូមស្នើឡើងថាឯកសាររបាយការណ៍ទាំងមូលរួម*អាល់ប៊ុម* រូបថតនោះ គឺឲ្យដាក់បញ្ចូលនៅក្នុងនីតិវិធីសវនាការនេះ ។ នេះគឺដើម្បីរក្សាឲ្យបាននូវភាពពេញលេញនៃឯកសារ ខាងមេធាវីការពារក្ដីមិនយល់ថា ជាការចាំបាច់ដើម្បីធ្វើការថតចម្លងឡើងវិញនូវ *អាល់ប៊ុម* នោះទេ ។ ពីព្រោះ *អាល់ប៊ុម* នោះគឺមានដាក់បញ្ចូលនៅក្នុងសំណុំរឿងទៅហើយ ដូច្នេះយើងមិនចាំបាច់ធ្វើការចម្លងឡើងវិញទេ ។ ហើយយើងខ្ញុំសូមស្នើទៅអង្គសវនាការឲ្យដាក់បញ្ចូលឯកសារនេះនៅក្នុងដំណើរការនីតិវិធីរបស់យើង ។ ដូចគ្នានេះផងដែរ គឺរបាយ-ការណ៍នៃការឲ្យធ្វើឡើងវិញ ដែលត្រូវបានធ្វើឡើងនៅជើងឯក និងនៅទួលស្លែងដែលជាឧបសម្ព័ន្ធ D48.1 ព្រមទាំងនៅឧបសម្ព័ន្ធទាំងអស់នៃរបាយការណ៍នេះ នៃឯកសារនេះ ។

[១៣:៤០:២២]

ហើយជាថ្មីម្ដងទៀត ឯកសារនេះគឺខាងសហព្រះរាជអាជ្ញាដកស្រង់រូបថតតែពីរបីប៉ុណ្ណោះពីរបាយការណ៍ឯកសារនៃការធ្វើឡើងវិញនោះ ។ ដូច្នេះ ខាងមេធាវីការពារក្ដីសូមស្នើឲ្យដាក់ឯកសារទាំងស្រុងនេះនៅក្នុងដំណើរការនីតិវិធី ព្រមទាំងឧបសម្ព័ន្ធរបស់ឯកសារនោះទាំងអស់ ។ ដូច្នេះហើយខ្ញុំនិយាយអំពីឯកសារ D48.1 និងឧបសម្ព័ន្ធរបស់ឯកសារនោះ ដែលនេះគឺជារបាយការណ៍នៃការធ្វើឡើងវិញនៅជើងឯក ហើយនិងឯកសារ D48.2 ដែលជារបាយការណ៍នៃការធ្វើឡើងវិញនៅទួលស្លែង ។ ហើយចុងបញ្ចប់ខាងមេធាវីការពារក្ដីសូមឲ្យដាក់បញ្ចូលនៅក្នុងសំណុំរឿងផងដែរ នូវវីដេអូ ដែលថតក្នុងអំឡុងពេលនៃការធ្វើឡើងវិញនៅជើងឯកនិងនៅទួលស្លែង ។ ហើយការថតវីដេអូនេះ គឺត្រូវបានធ្វើឡើងទៅតាមសំណើរបស់សហចៅក្រមស៊ើបអង្កេត ហើយមានដាក់បញ្ចូលនៅក្នុងសំណុំរឿង ។

ដូច្នេះ ខាងមេធាវីការពារក្តីសូមធ្វើការបង្ហាញថា នៅពេលដែលយើងសួរសំណួរដល់ជនជាប់ចោទ គឺនឹងធ្វើការបង្ហាញនូវវីដេអូចំនួនបីនាទីដល់អង្គសវនាការ ។ ហើយនៅក្នុងវីដេអូដែលខាងសហព្រះរាជអាជ្ញា-- ដែលខាងមេធាវីការពារក្តីនឹងធ្វើការបង្ហាញហ្នឹង មិនមានបង្ហាញពីសាក្សីណាម្នាក់ទេ គឺមានតែជនជាប់ចោទតែប៉ុណ្ណោះ ។ នេះគឺជាសេចក្តីអង្កេតរបស់ខ្ញុំ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

តំណាងសហព្រះរាជអាជ្ញាអញ្ជើញ ។

**លោក វីលៀម ស្មីត៖**

សហព្រះរាជអាជ្ញាសូមអរគុណលោកប្រធាន ។ ជាការឆ្លើយតបទៅនឹងសេចក្តីអង្កេតរបស់ខាងមេធាវីការពារក្តីគឺជាការត្រឹមត្រូវហើយ បញ្ជីឈ្មោះអ្នកទោសហើយនិងសេចក្តី-- ហើយនិងឧបសម្ព័ន្ធគឺជាសេចក្តីដកស្រង់ពីបញ្ជីឈ្មោះរួមដែលត្រូវបានកែពិនិត្យឡើងវិញ គឺD48.1 ។

[១៣:៤៣:០១]

បញ្ជីឈ្មោះអ្នកទោសដែលត្រូវបានកែពិនិត្យឡើងវិញនោះ គឺអាស្រ័យទៅលើបញ្ជីឈ្មោះអ្នកទោសដែលមាននៅក្នុងសំណុំរឿងរបស់សហចៅក្រមស៊ើបអង្កេត ដែលមានរយៈពេលមួយឆ្នាំមកហើយ។ ហេតុផលដែលធ្វើការកែប្រែឡើងវិញទៅលើបញ្ជីឈ្មោះអ្នកទោស ពីព្រោះនៅពេលដែលយើងពិនិត្យឡើងវិញនូវបញ្ជីឈ្មោះរួមរបស់អ្នកទោស ជនជាប់ចោទ បានពិនិត្យមើលឃើញមានឈ្មោះជាន់គ្នាមួយចំនួន ហើយជាលទ្ធផលនៃការពិនិត្យទាំងសងខាងរបស់ខាងសហព្រះរាជអាជ្ញា បញ្ជីឈ្មោះអ្នកទោសដែលត្រូវបានពិនិត្យឡើងវិញនេះ គឺឆ្លុះបញ្ចាំងអំពីឈ្មោះអ្នកទោសឲ្យបានពិតប្រាកដនៅស-២១ ។

ជាដំបូងបញ្ជីឈ្មោះរួមរបស់អ្នកទោសនៅស-២១ ដែលបានធ្វើកាលពីខែមីនាឆ្នាំមុន ដែលមាននៅក្នុងសំណុំរឿងហើយនោះ គឺមានអ្នកទោស ១២៣៨០នាក់ (ដប់ពីរពាន់បីរយប៉ែតសិបនាក់) ហើយនៅក្នុងបញ្ជីឈ្មោះថ្មី គឺមានឈ្មោះមួយរយប្រាំពីរ ដែលជាឈ្មោះជាន់គ្នា ដែលនេះហើយជាការផ្លាស់ប្តូរទាក់ទងទៅនឹងបញ្ហានៃការបកប្រែមួយចំនួនផងដែរ ។ ហើយនៅក្នុងបញ្ជីនេះ គឺមានអ្នកទោសចំនួន ១២២៧៣នាក់ (មួយម៉ឺនពីរពាន់ពីររយចិតសិបបីនាក់) នេះជាចំនួនមនុស្សដែលត្រូវបានសម្លាប់នៅស-២១ ហើយលោកចៅក្រមក៏បានឮសាក្សីផងដែរ ដែលថា អ្នកមួយចំនួនមិនមានឈ្មោះនៅក្នុងបញ្ជីឈ្មោះនេះទេ ។ នេះហើយគឺជាការសន្និដ្ឋានថាជាបញ្ជីឈ្មោះពិតប្រាកដ ហើយទាក់ទងទៅនឹងការវិភាគបញ្ជីនេះ ត្រូវបានរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ដូចដែលលោក លោកស្រីចៅក្រម បាន

ឃើញនៅក្នុងសំណុំរឿងហើយ ពួកគេបានរៀបចំបញ្ជីឈ្មោះចំនួនពីរធំៗ ហើយខាងសហព្រះរាជអាជ្ញាបានបញ្ចូលឈ្មោះទាំងពីរនេះចូលគ្នា គឺមិនមានធ្វើអ្វីលើសពីនោះទៀតទេ ។ ហើយបានរៀបចំឈ្មោះអស់ហ្នឹង ទៅតាមលំដាប់នូវថ្ងៃខែដែលបានចូល ប្រភេទរបស់អ្នកទោស ដើម្បីរៀបចំនូវឧបសម្ព័ន្ធហាសិបៗនោះ ។ ទាក់ទងទៅនឹងសំណូមពររបស់ខាងមេធាវីការពារក្តី គឺខាងសហព្រះរាជអាជ្ញាសូមគាំទ្រ ។

[១៣:៤៥:២៥]

**ប្រធានអង្គជំនុំ៖**

លោក ហ្សង់ម៉ាក សូមអញ្ជើញ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បើសិនជាខ្ញុំយល់ដឹងច្បាស់លាស់ អ្វីដែលភាគីទាំងពីរបាននិយានោះ គឺទាក់ទងទៅនឹងបញ្ហាដែលបានលើកឡើងនៅកាលពីព្រឹកមិញនេះ គឺកម្រិតទៅលើងការកំណត់សម្គាល់ប្រភេទឯកសារ ។ ទាក់ទងទៅនឹងបញ្ហានេះមិនមានការអង្កេតជាក់លាក់ណាមួយទេ អំពីអត្តសញ្ញាណរបស់ឯកសារនោះ ។ តើមានបញ្ហានេះដែរ ឬក៏អត់ទេ?

**លោក ហ្វ្រង់ស្វ័រ រូ៖**

ប្រហែលជាដូច្នេះ ប៉ុន្តែ ខ្ញុំមិនមានពេលពិនិត្យជាមួយនឹងសហព្រះរាជអាជ្ញាទេ ។ ប៉ុន្តែ អាចជាបញ្ហានៃការដាក់ជាឧបសម្ព័ន្ធជាមួយនឹងលេខរៀង៧១ ឯកសារនេះ គឺD86.15 អាចនឹងជាកំហុស ។ ដូច្នេះខាងសហព្រះរាជអាជ្ញាគួរតែផ្ទៀងផ្ទាត់លេខនេះឡើងមើលម្តងទៀត ពីព្រោះខ្ញុំយល់ថា លេខនេះដូចជាមិនត្រឹមត្រូវទេ ។

[១៣:៤៦:៣៦]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ក្រៅពីចំណុចនេះមិនមាននូវបញ្ហាអីទៀតទេឬ?

**ប្រធានអង្គជំនុំ៖**

បានស្តាប់នូវសំណើរបស់តំណាងសហព្រះរាជអាជ្ញា និងមេធាវីការពារក្តីទាំងការកត់សម្គាល់ទាំងការស្នើឃើញថា មិនមានការជំទាស់អីជាក់លាក់ទេ ផ្ទុយទៅវិញគឺមានការគាំទ្រផង ។ ដូច្នេះ គឺអង្គជំនុំជម្រះសម្រេចថាទទួលឯកសារទាំងអស់នេះដាក់នៅចំពោះមុខអង្គជំនុំជម្រះដើម្បីធ្វើការដេញដោល។

ជាបន្តនេះ ជាកិច្ចចាប់ផ្តើមសូមសួរទៅអស់លោក លោកស្រីចៅក្រម ថាតើមានសំណួរអ្វីសួរដល់ជនជាប់ចោទ ពាក់ព័ន្ធជាមួយនឹងអង្គហេតុនៃការសម្លាប់ដែរ ឬទេ?

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** ខ្ញុំចង់ត្រឡប់ទៅក្រោយបន្តិច ទាក់ទងទៅនឹងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តមុននឹងប្រហារជីវិត ។ លោកបាននិយាយថា គឺអាស្រ័យទៅលើគណៈស-២១ ជាអ្នកអនុវត្តនូវសេចក្តីសម្រេចចិត្តដែលថ្នាក់លើបានសម្រេចនោះ ។ ហើយលោកក៏បានពន្យល់ផងដែរ បើសិនជាខ្ញុំយល់ដឹងត្រឹមត្រូវនោះ គឺថាការប្រហារជីវិតនោះ និងស្ថានភាពនៃការប្រហារជីវិត ឬក៏ឈ្មោះអ្នកដែលត្រូវបានសម្លាប់នោះ គឺអាស្រ័យទៅលើការពិភាក្សារបស់គណៈស-២១ ហើយនៅពេលដែលលោកជាប្រធានស-២១ ។ គណៈស-២១ គឺមាន រួមមានលោក លោក ហ៊ី ។ ហើយសមមិត្ត ហ៊ី និងសមមិត្ត ហ៊ុយ គឺ ហ៊ុយស្រែ ។ ដូច្នេះ ខ្ញុំចង់ដឹង តើគណៈស-២១ ហ្នឹង បានពិភាក្សាពីអ្វីទៅ? តើគេពិភាក្សាអំពីទីកន្លែងដែលត្រូវប្រហារជីវិតអ្នកទោស ឬយ៉ាងម៉េច? តើមានអ្វីទៅដែលត្រូវបានសម្រេចនៅក្នុងគណៈស-២១នោះ?

[១៣:៤៩:៥២]

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! មិត្តហ៊ុយ គាត់ធ្វើ-- គាត់នៅដោយឡែកឯស្រែនោះទេ ។ រឿងគាត់ផ្សេង គាត់អត់ចូលលូកឡំជាមួយនឹងរឿងដកមនុស្សចេញពីភ្នំពេញទៅជើងឯកទេ ។

ចំណែក ខ្ញុំហើយនិងមិត្តហ៊ី ពីរនាក់នៅភ្នំពេញគិតគូរកិច្ចការអស់នេះ ។ ខ្ញុំមានអំណាចពិតក្តាប់រួមពិត ត្រួតត្រាលើកិច្ចការទាំងអស់ពិត ។ កិច្ចការទាំងអស់នេះ យើងខ្ញុំមិនប្រកែកទេ វាឧក្រិដ្ឋកម្មមួយច្បាស់លាស់ ។ ក៏ប៉ុន្តែ ក្នុងន័យអនុវត្ត គេគិតគូរធ្វើម៉េចកុំឲ្យចំនួនមនុស្សច្រើនពេកវាស្ទះនៅនឹងគុកនោះ វាច្រើនហួសកំណត់ វាច្រើនពេក នេះគឺគេអ្នកគិតគូរ ។ នេះរយៈកាលទីមួយ ។ រយៈកាលទីពីរ គឺក្រោយពីរឿងស្តាប់ដាច់ចម្លើយម្នាក់មក កិច្ចការនេះ គឺត្រូវតែមិត្តហ៊ី ច្បាស់លាស់ ហើយសូមប្រាប់ខ្ញុំឲ្យច្បាស់លាស់ថា មនុស្សអស់នេះបានសួរចម្លើយចប់ហើយ ។

ដូច្នេះ វារឿងជាមួយខ្ញុំ តែជាមួយមិត្តហ៊ី ទេ ពីរឿងថា ធ្វើម៉េចឲ្យវាច្បាស់យកចេញទៅកុំប៉ះលើមនុស្សដែលកំពុងសួរ ។

**ស៖** ដំបូងនៅពេលដែលលោកនិយាយថាគឺជាការពិភាក្សានៅក្នុងគណៈស-២១ តាមពិត ពិនិត្យមើលទៅគឺគ្រាន់តែជាការពិភាក្សារវាងលោក ហើយនិងមិត្តហ៊ី តែប៉ុណ្ណោះ ។ តើពេលនុ៎ងការពិភាក្សា

ហ្នឹងគឺជាការពិភាក្សាដែលមានឋានៈស្មើគ្នា ឬក៏ជាការពិភាក្សារវាងលោកជាមេ ហើយនិងអ្នកដែលនៅក្រោមបង្គាប់របស់លោក?

**ឆ៖** ក្នុងរឿងកិច្ចការជាទូទៅ មិត្តហ៊ី ជាមនុស្សនៅក្រោមខ្ញុំ ខ្ញុំជាមេ ។ ដោយឡែក ក្នុងកិច្ចការកម្ទេចនេះ ខ្ញុំក៏នៅតែជាមេជាអ្នកដឹងខុសដឹងត្រូវទទួលសម្រេច ធ្វើម៉េចឲ្យធានាទាំងអស់គ្នា ទាំងពីរនាក់ថា មនុស្សនេះពិតជាសួរចម្លើយចប់ហើយ ។ នេះក្នុងក្របខ័ណ្ឌនេះ ។ ដូច្នេះ គេរាយការណ៍មកថា ចប់ហើយបង ។ “ដល់ចប់ហើយយកចុះៗ” នេះខ្ញុំឆ្លើយ ។ នេះវាៗលក្ខណៈបែបនេះ សូមជម្រាបលោកចៅក្រម ។

**ស៖** ដូច្នេះតើយើងអាចនិយាយថា ហ៊ី នឹងសំណូមពរនូវឈ្មោះអ្នកទោសដែលត្រូវតែយកទៅប្រហារជីវិតនោះ ហើយគឺមានតែលោកទេដែលជាអ្នកសម្រេចនៅដំណាក់កាលចុងក្រោយ តើមែនទេ?

[១៣:៥៤:៣៥]

**ឆ៖** ជម្រាបលោកចៅក្រម យើងអាចនិយាយបែបនេះបាន ។

**ស៖** យើងនឹងថយទៅក្រោយបន្តិច ហើយនិងពិនិត្យមើលនៅក្នុងដំណាក់កាលមួយ នៅពេលណាត ជាប្រធានរបស់ស-២១ ។ ខ្ញុំគិតថានៅពេលនុ៎ង ក៏មានគណៈស-២១ ដែរមែនទេ? ហើយថាតើបញ្ហានៃការសម្លាប់មនុស្សនោះក៏ត្រូវបានពិភាក្សានៅក្នុងគណៈស-២១ នោះដែរឬ? ហើយតើពេលនោះលោកជាសមាជិករបស់គណៈស-២១ នោះដែរឬក៏មិនមែនទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ក្នុងរយៈកាលនោះ រឿងទទួលមនុស្ស រឿងកម្ទេចមនុស្សវាស្ថិតនៅលើដៃ ណាត ទាំងអស់ គេអ្នកសម្រេច ។ ឯចំណែក មិត្តហ៊ី ជាអ្នកអនុវត្ត ។ សូមបញ្ជាក់ថាអ្នកអនុវត្តតាមពិតគេមានផែនការមួយ គេលើកសំណើទៅសុំសេចក្តីសម្រេចចិត្ត ។ របៀបដូចដែលមិត្តហ៊ី ស្មើជាមួយនឹងខ្ញុំអ៊ីចឹង របៀបគ្នាអ៊ីចឹង ។ រួចចំណែកខ្ញុំដែលចូលទៅនេះ មុនដំបូងគេប្រគល់ការងារត្រឹមតែជាអ្នកបង្រៀនសួរ ។ ទីពីរក្រោយមកគេឲ្យជួយ គេឲ្យជួយការងារខាងរាយការណ៍ឯកសារទៅខាងលើ រាយការណ៍ទៅខាងលើ ។ ក្នុងរឿងរាយការណ៍ទៅខាងលើនេះ គេឲ្យខ្ញុំរាយការណ៍ស្អី ខ្ញុំរាយការណ៍ហ្នឹង ។ នេះជាសភាពការណ៍ដែលយើងខ្ញុំក្តាប់បាននៅពេលនុ៎ង គេឲ្យធ្វើប៉ុន្មាន ខ្ញុំធ្វើប៉ុននុ៎ង ។ ឥឡូវ តាមឯកសារដែលនៅសល់ មានគាត់បង្កើតលេខាធិការដ្ឋានរបស់គាត់មួយ ម្តងគាត់ហៅថាមន្ទីរ០៣ ដែលសរសេរអក្សរកាត់ថា ម-០៣ ហើយនិងអក្សរកាត់ ម-២១ ។ *អឹម* ២១ នេះនៅឆ្ងាយអំពី-- គេមិនឲ្យអនុប្រធានគ្រប់គ្រងទេ ។

[១៣:៥៨:៤៥]

សូមបង្ហាញឯកសារមួយ គឺឯកសានៅលើលេខ E5/2.2 ទំព័រ ERN 00227572 ខ្ញុំសរសេរទៅសួរម-២១ ឲ្យបញ្ជាក់ចម្លើយមួយមកឲ្យខ្ញុំ ឲ្យគេសួរបញ្ជាក់មកឲ្យខ្ញុំ ។ ខ្ញុំសរសេរចារ ខ្ញុំអត់មានសរសេរសំបុតទេ ខ្ញុំចារលើចម្លើយសារភាពនុ៎ង ដាក់នៅចុះថ្ងៃ១៧ ខែ១២/ ៧៥ ។ ដូច្នេះ វាបញ្ជាក់ឲ្យឃើញថាអា ម-២១ របស់គេនេះ វាមិនឲ្យអនុប្រធានដឹងទេ ។ ដូច្នេះ ក្នុងសម័យដែលខ្ញុំធ្វើជាអនុប្រធានមានភារកិច្ចបន្ទាប់ពីបង្រៀនគេសួរ ហើយនិងរៀបចំឯកសារសម្រាប់រាយការណ៍ទៅលើ ។ ឯកសារណាគេឲ្យរាយការណ៍ទៅលើ ឯកសារនុ៎ង ។ ដូច្នេះ ខ្ញុំសូមសរុបមកវិញ កាលដែលខ្ញុំនៅធ្វើជាអនុប្រធានគេលាក់មិនឲ្យខ្ញុំដឹងរឿងសម្ងាត់ច្រើនដែរ ។ ខ្ញុំសូមចប់ប៉ុណ្ណេះ ។

[១៤:០១:០៤]

**ស៖** តើយើងអាចនិយាយផងដែរបានឬទេ គឺថាមិនមានទំនុកចិត្តរវាងលោក ហើយនិងណាត-ហើយអាចជាវិធានការទាក់ទងទៅនឹងការប្រកួតប្រជែងសម្រាប់ដណ្តើមអំណាច?

**ឆ៖** ខ្ញុំគិតថា លោកចៅក្រមជ្រាបបញ្ហានេះស្រួល ពីព្រោះសមាសភាពកម្លាំងនៅកន្លែងនុ៎ងរាប់រយរាប់ពាន់នាក់ គឺគេកម្លាំងដែល-- កម្លាំងជាងមួយពាន់នាក់-- កម្លាំងជាងពីរពាន់នាក់គឺជាកម្លាំងរបស់គេ ចំណែកខ្ញុំមកមិនដល់ម្ភៃនាក់ផង ។ ដូច្នេះ វាមានពិតជាមានបញ្ហានេះ គេផ្តើលជើងអនុប្រធានៗ ។

**អ្នកបកប្រែ៖**

លោកចៅក្រមប្រធានទាន! ពាក្យផ្តើលជើងហ្នឹង អ្នកបកប្រែកំពុងតែពិភាក្សារកដាក់ពាក្យឲ្យត្រូវ ។

**ជនជាប់ចោទ៖**

**ឆ៖** អត់មានការងារអីសំខាន់ ។ សូមចប់ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** ឥឡូវនេះ ខ្ញុំមានសំណួរមួយចំនួនតូចទៀត ទាក់ទងទៅនឹងបញ្ហានៃបុគ្គលិកដែលជាអ្នកទទួលបន្ទុកក្នុងការកម្ទេច ឬក៏សម្លាប់ ថាតើអ្នកណាជាអ្នកទទួលបន្ទុកក្នុងការជ្រើសរើសបុគ្គលិកនោះ? ថាតើគេហៅក្រុមនោះដូចម្តេច? តើឈ្មោះ ឋាន:ការងាររបស់គេ ហៅថាពិឃាត ឬក៏អ្នកជំនាញខាងសម្លាប់ ឬក៏មានឈ្មោះអីហៅជាក់លាក់ទេ ក្រុមនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ភាសាជំនាន់នុ៎ងយើង-- ភាសាជំនាន់នោះរបស់បក្សកុម្មុយនីស្តកម្ពុជា គេហៅថាកងពិសេស ដែលមានភារកិច្ចប្រាំមួយ ដូចដែលខ្ញុំបានរៀបរាប់ជូនរួមមកពីមុនមកស្រាប់ ។ ក្នុងចំណោមភារកិច្ចទាំងប្រាំមួយនេះ គឺជាភារកិច្ចមួយត្រូវតែហៅថា ពេជ្ឈឃាដដែលគេហៅថា ពេជ្ឈឃាដ ។

[១៤:០៥:០០]

ដូច្នេះ មិនមែនថា*ប៉ូរ៉ូ* -- តែពួកកងពិសេសទេ ខ្ញុំជាបិតា*ប៉ូរ៉ូ* ដែលត្រួតពីលើអា*ប៉ូរ៉ូ* ហ្នឹងឯងទៅទៀត ។ ខ្ញុំអត់បដិសេធទេ ក៏ប៉ុន្តែរឿងពិត គឺវាអ៊ីចឹងកន្លងមក វាមានអង្គភាពមួយ ។ ខ្ញុំសូមបញ្ជាក់ថា កងពិសេសនេះវាមានតួនាទីមួយ គេហៅថា ពេជ្ឈឃាដ ។ ក៏ប៉ុន្តែ មិនមែនមានតែកងពិសេសហ្នឹងវាទទួលឧក្រិដ្ឋកម្មធ្ងន់ទាំងអស់ហ្នឹងតែម្នាក់វាទេ ។ ខ្ញុំផ្ទាល់ខ្លួនជាបិតាអាកងពិសេសហ្នឹង ជាបិតាមេពេជ្ឈឃាដហ្នឹង ។ នេះខ្ញុំសូមបញ្ជាក់ប៉ុននុ៎ង បើសិនជាអ្នកណាមិនធ្វើមួយ អ្នកណាមួយមិនធ្វើ គឺខ្ញុំវាយការណ៍ទៅលើ គឺអ្នកត្រូវកម្ទេចដែរហើយ ។ សូមបញ្ចប់ប៉ុណ្ណេះ ។

**ស៖** ក្នុងន័យការវាយតម្លៃលើបរិមាណ តើលោកអាចស្មានបានទេ អំពីចំនួនបុគ្គលិកនៅក្នុងកងពិសេសនេះ? តើលោកអាចបញ្ជាក់បានទេ បុគ្គលិកនោះ គឺថាអ្នកទាំងអស់ហ្នឹងមកពីម-១៣ មកពីអមលាំង ឬក៏ៗភាគីច្រើនគេមកពីកងពល៧០៣ ឬក៏មកពីណាដែលចូលរួមក្នុងកងពិសេសនេះ? ខ្ញុំមិនសួរឈ្មោះទេ គ្រាន់តែធ្វើការប៉ាន់ប្រមាណពីចំនួនមនុស្សក្នុងកងពិសេសនេះ ។

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ក្នុងសម័យសង្គ្រាមគឺមុន១៧ មេសា ១៩៧៥ កងពិសេសនេះជាអង្គភាពមួយស្រួចបំផុត ។ គេចូលប្រយុទ្ធខ្លួនទល់នឹងខ្លួនជាមួយនឹងខ្មាំង ម្នាក់តទល់នឹងដប់ពីរនាក់ក៏មានដែរ គេហាត់បច្ចេកទេស ។ មិត្តហ៊ អនុលេខាខ្ញុំនេះ អតីតលេខាកងពិសេស អតីតលេខាវរសេតូចកងពិសេស ។ អតីតលេខាវរៈសេនាតូចកងពិសេស អតីតលេខាវរៈសេនា-- *រឺៗ* អតីតលេខាអនុសេតូចកងពិសេស ។ កងពិសេសយកចូលមក៧០៣ អ្ហឺ! សូមទោស កងពិសេសយកពី៧០៣មកចូល២១ មានមួយអនុសេនាតូចៗ ។ យកចូលពី៧០៣ មកអនុកងពិសេសនេះមានចំនួនមួយអនុសេនាតូច ។ ត្រូវហើយ ។ ដូច្នេះ ចំនួនគឺមួយអនុសេនាតូចប្រហែលជា សាមសិបប្លាយនាក់ ។ នេះពួកនេះហើយដែលទទួលភារៈជាពេជ្ឈឃាដនោះ នាំមនុស្សយកទៅកម្ទេចនោះ ។ គ្មានពួកម-១៣ ចូលរួម គ្មានពួកមកពីកំពង់ឆ្នាំងចូលរួមទេក្មេងៗ ។ ហើយក៏កាន់តែគ្មានពួកក្រុងដែរ ។ ខ្ញុំសូមចប់ប៉ុណ្ណេះ ។

[១៤:១១:០៩]

**ស៖** ដូច្នេះខ្ញុំយល់ថា លោកយោងទៅរកអ្វីដែលថាជាក្រុមពិសេសមួយ ដែលថាជាទាហានពិសេស ។ ថាតើគេជាកងទ័ព ជាយោធា តើគេមានបទពិសោធន៍ពីមុនមកទេនៅក្នុងការសម្លាប់ នៅក្នុងការពិឃាដមនុស្សនោះ? ចំណុចនេះលោកបាន ខ្ញុំយោងទៅរកចំណុចមួយដែលបានផ្តល់ចម្លើយទៅសហចៅក្រមស៊ើបអង្កេតនុ៎ង D21 នៃសំណុំរឿងហ្នឹង ទំព័រ០៧ នៅក្នុងអត្ថបទភាសាបារាំង ។ លោកចៅក្រមស៊ើបអង្កេតបានសួរលោកថា សួរអំពីរបៀបដែលកម្ទេចមនុស្ស ។ សំណួរ គឺសួរដូចខាងក្រោម "ចំពោះការកម្ទេចនីមួយៗ គឺមានមនុស្សច្រើនត្រូវបានដាក់ទៅក្នុងរណ្តៅ ថាតើពួកគេត្រូវចងមុខ ឬមិនចងមុខពេលសម្លាប់? នៅពេលសម្លាប់កម្ទេចម្តងៗ មនុស្សជាច្រើននាក់ត្រូវដាក់នៅក្នុងរណ្តៅ ការធ្វើរបៀបនេះ ត្រូវបានកើតឡើងតាំងពីម-១៣ ។ ប៉ុន្តែ រឿងចងមុខមិនចងមុខខ្ញុំមិនដឹងទេ ប៉ុន្តែហើយចងស្លាបសេក និងចងមុខនេះ ពីព្រោះថាអង្គភាពកងពិសេសនេះ មានបទពិសោធន៍ជាសំខាន់ទាក់ទងទៅនឹងការងារ ។ ហើយមានបទពិសោធន៍នេះជាយូរមកហើយ" តើលោកចង់និយាយដូចម្តេចដែលលោកបញ្ជាក់ថា មានបទពិសោធន៍ច្រើន ហើយមានបទពិសោធន៍យូរណាស់មកហើយហ្នឹង លោកមានចង់មានន័យដូចម្តេចពេលដែលលោកឆ្លើយនោះ?

[១៤:១៣:០៩]

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ពាក្យថាមានពិសោធន៍ច្បាស់លាស់ មានន័យថាគេធ្លាប់ចាប់ ។ គេស្ទាត់ជំនាញណាស់ក្នុងសិល្បៈចាប់មនុស្សមិនឲ្យរើរួច ។ គេធ្លាប់សម្លាប់មនុស្ស ដែលមិនអ្នកណាតដៃ ឬក៏នៅរស់តទៅទៀតកើត ។ ដូច្នេះ ពិសោធនេះវាមានតាំងពីសម័យសង្គ្រាមមក មកដល់ក្រោយ១៧ មេសាៗ គេមកសម្លាប់មនុស្សដែលអត់មានអាវុធតដៃនឹងគេ ។ ដូច្នេះ ពិសោធចាស់របស់គេហ្នឹង វាធ្វើឲ្យគេវាមានពិសោធច្បាស់លាស់ហើយក្នុងរឿងសម្លាប់មនុស្ស ។ ដូច្នេះ ពីនគរបាលកងពល៧០៣ ចាប់កំណើតមកពួកហ្នឹងវាអ្នកសម្លាប់ ។ ដូច្នេះ វាយូរយារ គឺគិតចាប់ពីនុ៎ងមក ។ នេះចម្លើយខ្ញុំពីរប៉ុននុ៎ងសូមបញ្ចប់ ។

**ស៖** បទពិសោធន៍ដ៏ច្រើនទាំងអស់នេះរបស់កងពិសេសនោះ តើលោកនិយាយថា តើវាត្រូវទាក់ទង-- គឺថាពួកគេសម្លាប់មនុស្សដែលមិនត្រូវបានសួរអ្វីទាល់តែសោះ គេទទួលបញ្ជា គឺសម្លាប់ភ្លាម? តើលោកបានដឹងថា តើពួកគេមានការលំបាកក្នុងការអនុវត្តភារកិច្ចដែរទេ? ថាតើមានបញ្ហាទាក់ទងជាមួយនឹងការយល់ដឹងអំពីថាតើមានការ បញ្ហាអីទេក្នុងអនុវត្តការសម្លាប់របស់គេនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ខ្ញុំមិនជឿសោះថាគ្មានមនសិការឈឺចាប់ សោកស្ដាយ ខ្មាសអៀនទេ មាន ។ ខ្ញុំក៏ដឹង ខ្ញុំក៏យល់ មេខ្ញុំលោកគ្រូ សុន សេន ក៏យល់ ក៏ដឹង មានរឿងមួយដែលនាំឲ្យខ្ញុំប៉ាននិយាយអ៊ីចឹង ។ ប៉ុន្តែ ខ្ញុំសូមបញ្ជាក់ប៉ុននុ៎ង គឺថាអ្នកណាក៏យល់ដែរ ខ្លួនគេក៏គេខ្មាសអៀនដែររឿងហ្នឹង ។

[១៤:១៨:០០]

**ស៖** តើលោកបានដឹងទេថា តើអ្នកណាម្នាក់ក្នុងចំណោមអ្នកសម្លាប់ទាំងអស់នោះ ឬពេជ្ឈឃាដទាំងនោះ បានពាក់ព័ន្ធនៅក្នុងការសម្លាប់ក្នុងមួយអាណត្តិរបស់ស-២១? តើមានការផ្លាស់ប្ដូរដែរទេ? តើមានខ្វះចំនួនមនុស្ស? ហើយបើសិនជាខ្វះក្នុងកងពិសេសហ្នឹង អ្នកណាជាអ្នកសម្រេចដាក់បន្ថែមជំនួសអ្នកដែលលែងធ្វើនៅកន្លែងហ្នឹងតទៅទៀត?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ការជ្រើសរើសបន្ថែមៗអាចមានៗ ព្រោះខ្ញុំបានដកកងពិសេសនេះមួយចំនួនឲ្យមកធ្វើជាកម្មាភិបាលសួរចម្លើយ ។ ដូច្នេះ ក្នុងការជ្រើសរើសនេះ គោលការណ៍ខ្ញុំកំណត់ឲ្យគេហើយ ឲ្យជ្រើសរើសប្រវត្តិរូបល្អ ។ ធ្លាប់ចូលរួមក្នុងចលនាបដិវត្តន៍យូរគួរសមដែរហើយ ។ យើងមានជំនឿជឿទុកចិត្តលើគេ ។

សរុបមកបើមានរើសមែនមិនដឹងជាប៉ុន្មានដងទេ ក៏ប៉ុន្តែ គោលការណ៍ជ្រើសរើស គឺអ៊ីចឹង ។ ជម្រាបប៉ុណ្ណឹង សូមជម្រាបប៉ុណ្ណឹង ។

**ស៖** ដូច្នេះ មានមនុស្ស បុគ្គលិកខ្លះត្រូវជ្រើសតាំងថ្មី ហើយមានមនុស្សចំនួនដែលនៅតែធ្វើការបែបនុ៎ង ក្នុងតំណែងនុ៎ងជាបន្តរហូតតាំងពីចាប់ផ្ដើមស-២១ ដល់ចប់ ។

**ឆ៖** សូមជម្រាបប្រសាសន៍លោកចៅក្រម! មាន មានអ្នក-- មានចំនួនច្រើនដែលអនុវត្តការងារនេះ ចាប់ពីកកើត ស-២១ រហូតដល់ចប់ ។

**ស៖** ពីមុនលោកបានប្រាប់យើងថា ដើម្បីទទួលបានការចាត់តាំងចូលនៅក្នុងកងពិសេសនេះ យើងត្រូវតែមានប្រវត្តិរូបល្អ ហើយមានការប្ដេជ្ញាចំពោះបដិវត្តន៍ ហើយត្រូវតែមាននៅក្នុងបញ្ជី ។ តើត្រូវតែជាមនុស្សដែលអ្នកប្រកាន់រក្សាការសម្ងាត់នៅក្នុងនោះដែរឬទេ? ថាតើអ្នកនោះ តើលោកបានពិនិត្យផ្ទៀងផ្ទាត់ទេ ថាតើអ្នកទាំងអស់នោះបានរក្សាការសម្ងាត់របស់បក្សដែរនោះទេ ពេលបំពេញការងារនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! អ្នកដែលមានគោលជំហររក្សាសម្ងាត់ពិតប្រាកដនោះ គឺពួកកម្មាភិបាលសួរចម្លើយទៅវិញទេ ឯចំណែកពួកកងពិសេសត្រូវតែរក្សាការសម្ងាត់ក៏ពិតមែនហើយ ក៏ប៉ុន្តែ--

**ស៖** ដូច្នេះ ការសម្លាប់មិនមែនជាកម្មវត្ថុនៃការពិភាក្សា នៅក្នុងចំណោមបុគ្គលិកនៃស-២១ ទេ តើគេបានហាមប្រាមមិនឲ្យមានការនិយាយគ្នាអំពីរឿងការសម្លាប់ទេ ចំពោះបុគ្គលិក និងបុគ្គលិកនៅ ស-២១ នោះ?

**ឆ៖** អ្នកដែលយកមនុស្សទៅសម្លាប់អត់មានតវ៉ាទេ ត្រូវតែយកចេញ ។ កងពិសេសហ្នឹង តែកាលណាមេបញ្ជាត្រូវតែយកចេញ អត់តវ៉ាបានទេ ។

**ស៖** ដូច្នេះ គឺថា ខ្ញុំយល់ហើយ គឺថាមិនអាចតទល់នឹងការបញ្ជាទេ ប៉ុន្តែថា គេអនុញ្ញាតពួកជជែកគ្នាក្នុងចំណោមអ្នកធ្វើការរួមគ្នាទេ ពីរឿងការងារសម្លាប់ក្នុងចំណោមបុគ្គលិក ។ តើមានអនុញ្ញាតឲ្យគេនិយាយក្នុងចំណោមបុគ្គលិកគ្នាឯងពីកិច្ចការរឿងសម្លាប់កម្មេចនេះ?

[១៤:២៣:៥២]

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ក្នុងចំណោមកងពិសេសគ្នាគេ គេពិភាក្សាគ្នាៗ អំពីបច្ចេកទេសធ្វើឃាត ។ គេពិភាក្សាគ្នាអំពីបច្ចេកទេសដឹកជញ្ជូនមនុស្ស ។ គេពិភាក្សាៗគ្នាអំពីបច្ចេក-ទេសចាប់ចងមនុស្ស ទោះបីអារឿងចាប់ចងនេះ វាតិចបំផុតក៏ដោយ ក៏គេពិភាក្សាគ្នាដែរ ។ ជាពិសេស គឺបច្ចេកទេសការពារទីតាំងហ្នឹង កុំឲ្យអ្នកពីក្រៅមកអន្តរាគមន៍វ៉ៃចូលបាន ។ ហើយក៏ពិភាក្សាគ្នាផងដែរ អំពីរឿងបះបោលនៅក្នុង ទប់ទល់ឲ្យជាប់ ។ នេះបន្ថែមពីលើភារកិច្ច-- បន្ថែមពីលើការងារទិតៀនស្វ័យទិតៀន ។

**ស៖** នៅពេលដែលយើងនិយាយអំពីការអ្នកសួរចម្លើយនោះ គឺថាមានសំណួរមួយសួរទៅលោក ប៉ុន្តែខ្ញុំអានចំណុចមួយក្នុងសំណុំរឿង គឺថាទំនាក់ទំនងតាមទូរស័ព្ទដោយអ្នកសួរចម្លើយ ។ តើការជជែកក្នុងទូរស័ព្ទនោះមានការថតសំឡេង ។ តើត្រឹមត្រូវទេអ៊ីចឹងនោះ? បើមានការថតសំឡេងទូរស័ព្ទហ្នឹង តើគេថតចំណុចណាខ្លះ? ថតអំពីការសន្ទនាបែបណា?

**ឆ៖** ខ្ញុំបានបដិសេធរួចហើយថា គ្មានទេ របៀប-- ។ ខ្ញុំនៅតែបដិសេធតទៅទៀត ។

**ស៖** ក្នុងចំណោមកងពិសេសនេះ ដែលជាអ្នកពិឃាដនោះ តើមានអ្នកណាម្នាក់ទទួលរងទោសពិន័យទេ កាលណាគេ-- ការងារមិនបានល្អ ធ្វើការងារមិនបានល្អ ឬក៏ខកខានក្នុងចំណុចណាមួយនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! បើតាមខ្ញុំចាំពួកកងពិសេសមិនមានជាប់ទោសនៅ ស-២១ ដោយសារមិនបានបំពេញការងារនេះ ។ ប៉ុន្តែ បើផ្ទេរមកខាងសួរចម្លើយ អាចមានអ្នកត្រូវចាប់ខ្លួនដោយសារកំហុសផ្សេង កំហុសក្នុងការងារសួរនៅពេលសួរ ។ នេះ ខ្ញុំសូមបញ្ជាក់ប៉ុណ្ណេះ ។

**ស៖** តើលោកបានមានទំនាក់ទំនងជាទៀងទាត់ជាមួយកងពិសេសនោះទេ? តើលោកពិសាបាយជាមួយពួកគេ? តើលោកជួបជាមួយពួកគេរៀងរាល់ថ្ងៃ? តើលោកជជែកជាមួយពួកគេជាទៀងទាត់ប្រចាំថ្ងៃ ឬក៏ប្រចាំពេលណាមួយទេ?

**ឆ៖** ជម្រាបៗប្រសាសន៍លោកចៅក្រម! បាយយើងផ្ទះបាយរួម ដែលយើងទៅហូបទាំងអស់គ្នា ។ នៅតុខ្ញុំមានគ្នាប៉ុន្មាននាក់ទេ ប្រាំពីរ-ប្រាំបី នាក់ប៉ុននុ៎ង ប្រាំមួយ-ប្រាំពីរនាក់ប៉ុននុ៎ង ។ តាមខ្ញុំចាំគឺមានបង ម៉ម ណៃ មួយ, មិត្តហ៊ី ជួនកាលមកជួនកាលអត់ ហើយមានមិត្តប៉ុន ហើយពេលណាប្រពន្ធខ្ញុំ គាត់មកនៅហ្នឹង-- ផ្ទះហ្នឹងដែរជាមួយខ្ញុំ គាត់ទៅហូបបាយជាមួយតុខ្ញុំហ្នឹងដែរ ។ ដូច្នេះ ខ្ញុំមិនដែលបានទៅហូបបាយជាមួយនឹងកងពិសេសទេ ខ្ញុំបញ្ជាអីទៅកងពិសេសមិនដែលបញ្ជាផ្ទាល់ទេ គឺបញ្ជាតាមរយៈមិត្តហ៊ី ទាំងអស់ ។ លេខាអនុសេនាតូចកងពិសេសនេះ មិនដែលមកជិតខ្ញុំទេ ។ នៅក្នុងគណៈកម្មាធិការអនុសេនាតូចកងពិសេសទៅមានម្នាក់ផ្សេងទៅវិញ ដែលឧស្សាហ៍មកជាប់ជិតស្និតជាមួយនឹងខ្ញុំ គឺអនុលេខាអនុសេនាតូចកងពិសេសនេះឯង ទេ--សុំទោស តែជាការទាក់ទងគ្នារវាងមេ និងកូនក្នុងការយកចិត្តមេតែប៉ុននុ៎ងទេ អត់មានការសម្ងាត់ណែនាំអប់រំអីទេ ។ នេះសូមបញ្ជាក់ប៉ុណ្ណេះ ។

[១៤:៣២:៤៩]

**ស៖** តើលោកអាចនិយាយថា លោកខ្លួនឯងផ្ទាល់មិនដែលបានគិតថាបានពិភាក្សាជាមួយពេជ្ឈឃាដអស់ទាំងនោះទេ? មានន័យថា ដើម្បីព្យាយាមយល់អំពី តើពួកគេធ្វើការយ៉ាងម៉េចដែរ និងការងាររបស់គេ ឬក៏គេមានបញ្ហាអ្វីផ្សេងៗ ឬមួយក៏លោកព្យាយាមយល់ពីទំនាក់ទំនងរបស់ពួកគេជាមួយនឹងលោកនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ពិតៗហើយ ។

**ស៖** តើពួកគេហ្នឹងមានគេភ័យខ្លាចលោកឬ?

**ឆ៖** ប្រាកដណាស់ គេខ្លាចខ្ញុំ ។

**ស៖** ឥឡូវនេះ យើងនិយាយអំពីវិធីសម្លាប់មនុស្សវិញ ។ អ្វីដែលខ្ញុំបានអានពីមុន គឺលោកបានយោងទៅលើម-១៣ ប៉ុន្តែ ទៅតាមការយល់ដឹងរបស់ខ្ញុំនៅថ្ងៃនេះ តើវិធីដដែលហ្នឹងត្រូវបានគេប្រើទាំង

នៅម-១៣ និងនៅស-២១ ឬក៏វិធីផ្សេងត្រូវបានប្រើនៅស-២១ នោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! បើនិយាយអំពីថា ធ្វើម៉េចឲ្យស្លាប់? បើត្រឹមតែនិយាយពាក្យថា ធ្វើម៉េចឲ្យស្លាប់ ដំបូងម-១៣ ហើយនិងស-២១ ខុសគ្នា ត្រង់ដែលម-១៣ វ៉ៃអាខាងក្រោមនេះ អាត្រង់សៀវាឡេ នេះ នឹងគល់ឫស្សី ។ ហើយបើនៅខាងស-២១ វិញ ណាត គាត់ពេញចិត្តនឹងអារ ចាក់ចាក់គល់កនេះៗឲ្យចំសរសៃអាទែរនៅត្រង់នេះ ។ ដល់ក្រោយមកខ្ញុំឮ មិត្តហ៊ុយ គាត់និយាយនៅពេលដែលថតកុនជាមួយ ឫទ្ធី ប៉ាន់ ខ្ញុំជឿថា គាត់ត្រឡប់មករកវិធី ដូច M-13 ដែរ ។ នេះរឿងដែលប្លែកគ្នា គឺអ៊ីចឹង ទិដ្ឋភាពថាធ្វើម៉េចឲ្យស្លាប់ គឺប្លែកគ្នាបន្តិចប៉ុននុំងដំបូង ។

ឯចំណែករឿងដែល *អឹមត្រី* (M-13) មិនដែលមាន តែមកឃើញមាននៅស-២១ គឺកម្ទេចហើយឲ្យថត ។ ថតហើយបញ្ជូនទៅលើទុកជាភស្តុតាង ។ ហើយប្លែកមួយទៀត គឺពួកបស្ចិមប្រទេសទាំងបួននាក់នេះ កម្ទេចគេហើយ សម្លាប់គេហើយ ឲ្យដុតសាកសពហ្នឹងឲ្យឆេះខ្ទេច កុំឲ្យនៅសល់ ។ ក៏ប៉ុន្តែ ពួកនេះមិនថតរូបផ្ញើទៅលើទេ គឺត្រូវតែកម្ទេចឲ្យនេះ ហើយចប់ ។ នេះសូមបញ្ជាក់ជូនប៉ុណ្ណេះ។

**ស៖** អ៊ីចឹងសម្រាប់លោកតើលោកអាចនិយាយថា វិធីដែលត្រូវបានប្រើនោះ គឺវាមិនមានភាពខុសគ្នាទេសម្រាប់លោក ពីព្រោះអីលោកមិនខ្វល់ពីវិធីនោះទេ ធ្វើយ៉ាងម៉េចឲ្យតែអ្នកទោសនោះបានស្លាប់ ឬមួយក៏តើជាការសំខាន់ដែរ សម្រាប់លោក ដែលថាអ្នកទោសនោះត្រូវស្លាប់ដោយវិធីណានោះ?

**ឆ៖** លោកចៅក្រមជាទីគោរព! លោកមានប្រសាសន៍ហ្នឹង ត្រូវហើយ ខ្ញុំមិនដែលបានគិតអំពីវិធីដែលគេធ្វើយ៉ាងម៉េចទេ ។ ធ្វើម៉េចឲ្យតែច្បាស់លាស់ថា បានកម្ទេចហើយ នេះសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

**ស៖** លោកបានឃើញរូបថតនៃអ្នកដែលត្រូវបានគេសម្លាប់ ហើយនៅលើរូបថតមួយចំនួន គឺយើងអាចមើលឃើញថា រាងកាយរបស់អ្នកទោសនោះ គឺមានស្នាមគេវ៉ៃ ឬក៏ស្នាមរបួស ឬក៏រហែកសាច់ តើលោកមានបានឃើញរូបខ្លះដែលអាចមានសាកសព ដែលថាពោះរបស់ជនរងគ្រោះនោះត្រូវបានគេវះដែរឬទេ?

**ឆ៖** ខ្ញុំឃើញ ភាគច្រើនលើសលុបៗ មានតែត្រឹមកាត់បំពង់កទេ ។ ក៏ប៉ុន្តែ ដោយឡែករូបថតវន វេត, ឆាយ គឹមហ៊ុ ហើយនិងណាត គេកាត់បំពង់កហើយ គេវះពោះ បើតាមខ្ញុំចាំ មានតែបីនាក់ហ្នឹងទេ ។ ខ្ញុំឃើញរូបថតនេះ ខ្ញុំផ្ញើទៅលើ ។ ខ្ញុំក៏មិនមាត់ ខាងលើដែលទទួលរូបថតហ្នឹង ក៏មិនមាត់ដែរ ។ នេះបើតាមខ្ញុំចាំ គឺមានតែបីនាក់ហ្នឹងទេ ។

[១៤:៤០:៤៥]

**ស៖** ប្រសិនបើលោកមានការរន្ធត់ និងការពិនិត្យមើលបែបនោះ តើលោកមានដែលសួរថា តើហេតុអីបានជាគេប្រព្រឹត្តដូច្នេះនោះដែរឬទេ?

**ឆ៖** ខ្ញុំអត់សួរទេៗ ខ្ញុំគ្រាន់តែសន្និដ្ឋាន ។ សន្និដ្ឋានថា ដើម្បីឲ្យច្បាស់លាស់ ព្រោះ៧០៣នេះជាអង្គភាពដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ណាត ពីមុន ។ ដូច្នេះ ដើម្បីឲ្យខាងលើបំផុត ជឿទុកចិត្តថា ចំពោះសមាសភាព៧០៣ ដែលនៅស-២១ហ្នឹង គេធ្វើឲ្យឃើញពោះវហែកថែមទៀត ។ ហើយពីអង្កាល់មុន១៧ មេសា ១៩៧៥ វន វ៉េត គ្រប់គ្រង ណាត ។ ដូច្នេះ គេវះពោះទាំង ណាត វះពោះទាំង វន វ៉េត ទន្ទឹមគ្នានោះ ក៏គេវះពោះ ឆាយ គឹមហ៊ ដែរ ។ ខ្ញុំសូមចប់ប៉ុណ្ណេះ ។

**ប្រធានអង្គជំនុំ៖**

ដល់ម៉ោងត្រូវសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី រហូតដល់ម៉ោងបីសូមអញ្ជើញចូលវិញ បន្តដំណើរការពិភាក្សាដេញដោលទៀត ។

*[សវនាការសម្រាកពីម៉ោង ១៤:៤៣ នាទី ដល់ម៉ោង ១៥:០៥ នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការពិភាក្សាដេញដោលតទៅទៀត ហើយអម្បាញ់មិញ នេះមុននឹងសម្រាក គឺជាវេទិការបស់ចៅក្រមហ្សង់ម៉ាក ។ ឥឡូវនេះសូមប្រគល់វេទិកានេះជូនទៅលោកចៅក្រម ហ្សង់ម៉ាក បន្តសំណួរចំពោះជនជាប់ចោទ ។ សូមអញ្ជើញលោកចៅក្រម ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** នៅក្នុងនីតិវិធីរបស់យើងនេះលោកបានបញ្ជាក់ថា អំពីការសម្លាប់អ្នកទោសនោះថា តើនៅតាមនីតិវិធីរបស់ស-២១ សាកសពនៅជើងឯកនោះចាត់ចែងដូចម្តេច? អ៊ីចឹងនៅក្នុងដំណាក់កាលស៊ើបអង្កេតមានការស៊ើបអង្កេតនៅក្នុងទីតាំងនោះ នៅក្នុងចំណោមមនុស្សមួយចំនួនដែលរស់នៅជុំវិញនោះដែលថា ជាសារមន្ទីរទួលស្លែង គេបានសម្ភាសន៍ជាមួយមនុស្សម្នាក់ សូមពិនិត្យមើលD49.7 ដែលថាដែលយើងនិយាយអំពីការសម្ភាសហ្នឹង គឺខ្ញុំមិនបញ្ជាក់ឈ្មោះអ្នកផ្តល់សម្ភាសទេ ខ្ញុំនឹងអានអំពីខ្លឹមសារ

មួយដែលជននេះបានបញ្ជាក់ ។ គាត់បានពន្យល់ថា “គាត់បានត្រឡប់មកចុងទសវត្សរ៍ឆ្នាំ៨០ នៅក្នុងតំបន់នេះ ហើយត្រឡប់មករកផ្ទះដែលថាជាផ្ទះរបស់គាត់ដែលបានកើតនៅកន្លែងហ្នឹង ហើយគាត់បានត្រឡប់មកជាមួយក្រុមគ្រួសារ ហើយគាត់បានពិនិត្យឃើញថា កន្លែងនោះមានរបងព័ទ្ធជុំវិញ ហើយផ្ទះដែលបច្ចុប្បន្នហ្នឹង គឺថាមិនប្តូរទេ គឺថាមានផ្ទះ មានដើមចេក មានដើមឈើខ្លះ នៅមានផ្នែក ហើយសង្ហារឹមខ្លះមិនត្រូវបានប្តូរចេញទេ ហើយគាត់ក៏បាននិយាយតទៅទៀតថា ផ្ទះមួយនោះត្រូវបានគេយកទៅប្រើដើម្បីដាក់ស្តុកនូវឆ្អឹង គឺថា ពួកមូលដ្ឋាននិយាយថា ឆ្អឹងនោះ អដ្ឋិធាតុទាំងអស់នោះគឺជា អដ្ឋធាតុដែលគេប្រើសម្រាប់ធ្វើជី” ។ ហើយនៅក្នុងសំណុំរឿង តើលោកអាចបញ្ជាក់ប្រាប់យើងទេថា លោកបានអានបទសម្ភាសន៍មួយនេះ តើលោកមានយោបល់អ្វីទេអំពីចម្លើយនេះដែលថា គេបានដុតសាកសពឲ្យទៅជាផេះ ដែលថាផេះផង់ ឬក៏អដ្ឋធាតុដែលគេដុតមនុស្សហើយគេយកទៅធ្វើជាជីនោះ ។

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ឯកសារនេះខ្ញុំមិនដែលបានអានទេ ។ ខ្ញុំបើឲ្យសន្និដ្ឋាន ខ្ញុំសូមសន្និដ្ឋានថា ជំនាន់នោះគ្មានពេលបានដុតសពអ្នកណាទេ ក្រៅអំពីពួកនេះទាំងបួននាក់ ពួកដែលដុតមិនឲ្យសល់ឆ្អឹង ក្រៅពីនោះអត់មានបានដុតអ្នកណាទាំងអស់ ។ ដូច្នេះ ខ្ញុំមិនមានការអធិប្បាយអីលើសពីនេះតទៅទៀតទេ។ សូមបញ្ជាក់ប៉ុណ្ណេះ ។

[១៥:០៩:០៧]

**ស៖** ប៉ុន្តែមានសាកសពជាច្រើនគឺថា ក្រៅពីសាកសពជនបរទេសទាំងបួន លោកបានបញ្ជាក់ថា សាកសពដែលដុត ដែលមកពីតាខ្មៅ នៅគុកតាខ្មៅនោះ?

**ឆ៖** បើនិយាយពីខ្មោចនៅតាខ្មៅ ខ្ញុំពិតជាមិនបានបញ្ជាថា ឲ្យដុតឲ្យសុសមែន មិនពិតជាមិនបានបញ្ជាឲ្យដុតឲ្យសុសមែន ឲ្យអស់មែន ។ ខ្ញុំមិនដែលបានគិតថា គេយកធាតុដែលដុតហើយទៅប្រើជាជីទេ។ បើថាដុតនៅសល់តិចតួចនៅតាខ្មៅគេកប់ចោលឲ្យបាត់ដាន ។ នេះខ្ញុំគិតអ៊ីចឹងទៅវិញ ។

ដូច្នេះ ការដែលយកទៅ នេះខ្ញុំមិនជឿថា នៅតាខ្មៅក៏គេយកឆ្អឹងដែលដុតនេះយកទៅធ្វើជី មិនជឿ ។

**ស៖** សំណួរមួយទៀតទាក់ទងទៅប្រធានបទផ្សេង ។ ឥឡូវនេះ ការដឹកជញ្ជូនរវាងស-២១ ទៅជើងឯក ឬក៏ពីជើងឯកមកស-២១ នោះ តើលោកបញ្ជាក់បានទេថា ការដឹកជញ្ជូនភាគច្រើនហ្នឹងធ្វើឡើងនៅពេលយប់? តើលោកធ្លាប់បានវត្តមាននៅពេលដែលឡានដឹកចេញទៅទេ? តើលោកធ្លាប់បានពិនិត្យមើលការចេញដំណើរនូវរថយន្តដែលដឹកចេញម្តងៗដែរឬទេ?

**ឆ៖** ខ្ញុំមិនដែលបានទៅត្រួតពិនិត្យទេ ទោះបីពេលចេញដំណើរក៏ដោយ ក៏ខ្ញុំមិនដែលបានទៅមើលដែរ ។ នេះសូមជម្រាប ។

**ស៖** ដូច្នេះលោកមិនបានដឹងថាតើដឹកពេលយប់ ឬពេលថ្ងៃនោះទេ? អ៊ីចឹងឬ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ដែលខ្ញុំទៅពិនិត្យមើលនៅជើងឯកម្ដងនោះ គេឲ្យខ្ញុំទៅយប់។ ដូច្នេះខ្ញុំគិតថាជាទូទៅប្រហែលជាយប់ ពីព្រោះយប់វាធានាការសម្ងាត់ជាង ។

**ស៖** សំណួរមួយទៀត ឥឡូវនេះខ្ញុំនិយាយអំពីរូបថត តាមដែលខ្ញុំយល់ តាមដែលលោកបញ្ជាក់នោះ រូបថតត្រូវបានថតទាំងស្រុងនៅពេលដែលតាមសំណើមកពីថ្នាក់លើ តើអ៊ីចឹងមែនឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! មនុស្សសំខាន់ដូចខាងលើបញ្ជាមកខ្ញុំថត ហើយបញ្ជូនរូបថតនោះទៅខាងលើវិញ ។ ឯចំណែក រូបថតផ្សេងទៀតអាច ឧទាហរណ៍មានម្នាក់នោះកាលដែលសម័យខ្ញុំទៅសារមន្ទីរទួលស្លែង ឃើញគេបង្ហាញរូបម្នាក់ដែលស្លាប់ ហើយគេយកមកដាក់តាមផ្លូវដើរក្នុងអគារនោះ មិនទាន់យកចេញទេ គេថត ។ ហើយលោកចៅក្រមស៊ើបអង្កេតសួរថា ម៉េចក៏បានថតអ៊ីចឹង មិត្តធី អ្នកដែលគេដឹងរឿងនោះៗ គេជម្រាបលោកចៅក្រមថា អាហ្នឹងគឺថតមកពីស្លាប់ ថតទុកជាភស្តុតាង ថា មនុស្សនេះបានស្លាប់បាត់ទៅហើយ ។ ដូច្នេះ មនុស្សដែលស្លាប់នៅទួលស្លែងមានមួយចំនួនផ្សេងទៀត ដែលមិនមែនជាអ្នកធំគេថតទុកសម្រាប់ជាភស្តុតាងបញ្ជាក់ថា មនុស្សនេះបានស្លាប់បាត់ទៅហើយ ។ មិនមែនគេជាអ្នកប្រតិបត្តិការគេលួចដោះលែងទេ គឺពិតជាបានស្លាប់អ៊ីចឹងមែន ។ គេរក្សារូបថតនេះទុក ។

[១៥:១៦:០៥]

**លោក ហ្វ្រង់ស្វ័រ រូ៖**

ខ្ញុំថាមានបញ្ហាក្នុងការបកប្រែ ខ្ញុំបានឮថា ចំពោះអ្នកដែលមិនសំខាន់គេបានថតរូប ប៉ុន្តែបានឮផ្ទុយពីហ្នឹងទៅវិញ ។ ចំណុចនេះក៏ត្រូវតែមានការកែតម្រូវនៅក្នុងប្រតិចារឹកដែរ ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** តើលោកបាននិយាយអ្វីឲ្យប្រាកដសូមបញ្ជាក់ម្ដងឡើងវិញ តើប្រើចំពោះតែមនុស្សសំខាន់ ឬក៏មានទាំងមនុស្សសំខាន់ផងដែរ មិនសូវសំខាន់ផងដែរ? សូមពន្យល់ឲ្យបានច្បាស់ម្ដងទៀត ។

**ឆ៖** ខ្ញុំសូមបញ្ជាក់ជូនអំពីបញ្ហានេះដូចតទៅ ។ ទីមួយបុគ្គលដែលសំខាន់ ខាងលើបញ្ជាឲ្យថត។ ដល់ថតរួចហើយ លាងរួចហើយ ផ្ដិតរួចហើយ ខ្ញុំបញ្ជូនរូបថតទៅលើ ។ ទីពីរ មនុស្សដែលមិនសំខាន់

តែស្លាប់នៅក្នុងក្របខ័ណ្ឌមន្ទីរស-២១ ពួកកងការពារត្រូវតែថតរូបដើម្បីបញ្ជាក់ប្រាប់ប្រធានស-២១ ថា បុគ្គលនោះស្លាប់ទៅហើយ គេមិនមែនជាអ្នកលួចដោះលែងទេ ។ ដើម្បីបង្ហាញភាពស្មោះត្រង់របស់គេ មិនដោះលែងមនុស្សឲ្យអង្គការជ្រាប ។ នេះសូមបញ្ជាក់ប៉ុណ្ណេះ ។

**ស៖** ដូច្នេះ តើលោកនិយាយថា ភាគច្រើននៃអ្នកជាប់ឃុំឬក៏អ្នកទោសនោះត្រូវបានថតរូប ឬក៏ថតរូបតែភាគតិចទេ? អ៊ីចឹង ថាតើភាគច្រើនសុទ្ធតែបានថតរូបក្នុងករណីដូចបានរៀបរាប់ ឬក៏ភាគតិចទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! រូបថតពាក់កណ្ដាលដែលមានលេខហ្នឹង ដែលមានលេខនៅដើមទ្រូងហ្នឹង តាមការណែនាំរបស់ខ្ញុំ គឺឲ្យគេថតគ្រប់គ្នា ។ ប៉ុន្តែ មានមនុស្សសំខាន់ខ្លះអត់បានថតអាភ្ជាប់នឹងដើមទ្រូងលេខអ៊ីចឹងទេ ។ តាមខ្ញុំចាំច្បាស់រូបថត កុយ ធួន មួយ អត់មានទៅអង្គុយថតឲ្យមានជាប់លេខអីៗអ៊ីចឹងទេ ។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណេះ ។

[១៥:២០:៤៨]

**ស៖** ដូច្នេះ ទៅតាមលោកគឺថា រូបថតសាកសពនោះ វាមានប៉ុន្មានទៅ រាប់រយរូបថតសាកសព ឬក៏រាប់ពាន់ ហើយលោកត្រូវពិនិត្យមើលគ្រប់រូបថតអស់ទាំងនោះឬ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! រូបថតដែលត្រូវបញ្ជូនទៅលើ ខ្ញុំបានមើលគ្រប់រូបថត ឯចំណែក រូបថតដែលមនុស្សស្លាប់នៅហ្នឹងស-២១ ខ្ញុំមិនដែលបានមើលទេ ។

**ស៖** ដូច្នេះ រូបថតទាំងអស់ តើមិនត្រូវបញ្ជូនទៅថ្នាក់លើទាំងអស់ទេឬ?

**ឆ៖** រូបថតអ្នកតូចតាច ដែលគេថតនៅស-២១ នេះ មិនមែនសម្រាប់ឲ្យខ្ញុំបញ្ជូនទៅខាងលើទេៗ សម្រាប់ការពារខ្លួនគេ នៅពេលដែលខាងលើដេញដោល ។ ឧបមា រូបថតអ្នកណាមួយទៅ ឧបមាថា រូបថតអ្នកគ្រូ ឌឹម សារឿន ចុះ បើសិនជាគាត់ស្លាប់ដោយសារឈឺ គេថតទុក។ ថ្ងៃក្រោយអង្គការឃើញអ្នកណាមួយថា ឌឹម សារឿន ដែរ មកដេញដោលសួរខ្ញុំ ។ ហើយតែកាលណាអង្គការសួរខ្ញុំៗសួរទៅខាងក្រោមហើយ មានលែងទេ មានលែង ឌឹម សារឿន ទេ? ដល់ទៅ ខ្ញុំទៅសួរខាងក្រោម បើខាងក្រោមថាអត់ទេបង នេះរូបថតគាត់ដែលស្លាប់ ។ ដល់ទៅកាលណាបើខ្ញុំទៅសួរខាងក្រោមៗគេបង្ហាញភស្តុតាង ហើយថា នេះបង រូបថតអ្នកគ្រូ ឌឹម សារឿន ដែលស្លាប់ នេះខ្ញុំអត់បានលែងទេ គាត់ស្លាប់ គឺអត់មានអ្នកណាប៊ានដោះលែងទេ គេបញ្ជាក់មកអ៊ីចឹង ដើម្បីការពារខ្លួនគេ ។

សរុបមក រូបថតមានមួយចំនួនអត់បញ្ជូនទៅលើទេ ហើយខាងខ្ញុំក៏មិនដែលបានឃើញដែរ ។

គេថតគ្រាន់តែសម្រាប់ការពារខ្លួនគេ នៅពេលណាដែលខាងលើដេញដោល ។ ហើយសូមបញ្ជាក់ថា ខ្ញុំលើកយករឿង អ្នកគ្រូ ឌឹម សារឿន នេះ មកនិយាយមិនមែនមានរូបថត អ្នកគ្រូ ឌឹម សារឿន ស្លាប់ទេ អត់មានទេ គ្រាន់តែជាឧទាហរណ៍ ។

**ស៖** ខ្ញុំមានសំណួរមួយទៀតទាក់ទងនៅដំណាក់កាលចុងក្រោយនៃមន្ទីរស-២១ លោកបានពន្យល់ថា នៅដំណាក់កាលចុងបញ្ចប់នៃស-២១ លោកត្រូវបានគេបង្គាប់ឲ្យធ្វើការសម្លាប់ជាឈុត ។ តើការសម្លាប់ជាឈុតហ្នឹង គឺដើម្បីសម្រេចនូវគោលបំណងប្រហាក់ប្រហែលគ្នាទៅនឹងការសម្លាប់ពីមុនៗមកដែរឬ? ពីមុនលោកបាននិយាយថា ការសម្លាប់ជាឈុតនោះ គឺត្រូវបានអនុវត្តដើម្បីចៀសវាងការមានអ្នកទោសច្រើននៅក្នុងគុក ។ ដើម្បីចៀសវាងបញ្ហាអនាម័យ បញ្ហាការផ្តល់ម្ហូបអាហារជាដើម ទាក់ទងទៅនឹងបញ្ហាសន្តិសុខផងដែរ ។ ដើម្បីចៀសវាងថា អ្នកទោសនោះនឹងអាចរត់រួច ក៏ប៉ុន្តែនៅកៀកនឹងចុងបញ្ចប់នៃដំណាក់កាលចុងក្រោយរបស់ស-២១ គឺនៅចុងបញ្ចប់ឆ្នាំ១៩៧៨នោះ នៅឬក៏ដើមប៉ុន្មានថ្ងៃដំបូងនៃដើមឆ្នាំ១៩៧៩ នៅពេលនោះ គឺមានការសម្លាប់អ្នកទោសជាច្រើន ។ តើការបញ្ជាឲ្យសម្លាប់នោះសម្រាប់គោលបំណងដូចគ្នាទៅនឹងការបញ្ជា ឲ្យសម្លាប់ជាឈុតពីមុនមកដែរឬក៏យ៉ាងម៉េច?

[១៥:២៦:៥៨]

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ការដែលដកចេញចុងក្រោយនេះ រវាងថ្ងៃ០២ ថ្ងៃ០៣ មករា ១៩៧៩នេះ មានវត្ថុបំណងផ្សេងទៅវិញ គឺមានវត្ថុបំណងឲ្យអស់អ្នកទោសចេញពីស-២១ ពីព្រោះខាងលើដូចជាចាប់អារម្មណ៍ថា ខ្លួនឯងចាញ់យួន តែមិនប៊ាននិយាយ ខ្លួនឯងចាញ់វៀតណាមចាញ់សង្គ្រាមវៀតណាមហើយ ។

សូមបញ្ជាក់ថា ពេលនោះ ពូនួន ហៅខ្ញុំទៅធ្វើការ ដល់ទៅគាត់ថា មិត្តឌុច ដកចេញឲ្យអស់ពួកនោះ ដកចេញឲ្យអស់ទៅជើងឯកទៅ ។ ខ្ញុំសួរគាត់ភ្លាម ខ្ញុំថា ចុះពួកវៀតណាម ដែលយើងទុកសួរចម្លើយផ្សាយវិទ្យុគិតយ៉ាងម៉េច? គាត់ឆ្លើយថាយកទាំងអស់ ។ ថ្ងៃក្រោយយើងរកបានទៀត វៀតណាមឈ្លើយសឹកវៀតណាម ។ ដូចខ្ញុំបានខ្ញុំនិយាយថា បើដូច្នេះពួក យ-៨, ៨នាក់ ខ្ញុំសុំទុកសួរចម្លើយសិនអង្គភាពហ្នឹង ឈ្មោះអង្គភាព “យ-៨” មិនមែនមនុស្សប្រាំបីនាក់ទេ។ អង្គភាពនោះ ឈ្មោះអង្គភាព Y8 ។ ដូច្នេះ យុទ្ធជន យ-៨ ដែលទើបនឹងចាប់ថ្មីនេះ ខ្ញុំសូមទុកសម្រាប់សួរចម្លើយសិន ។ គាត់ថា យល់ស្រប ប៉ុន្តែ មិត្តម្ចាស់ការណ៍ា មានការអីម្ចាស់ការ ។ ប៉ុណ្ណឹងហើយ ខ្ញុំនៅអត់យល់ថា យួន នែ៎ វៀតណាមជិតមកដល់ទេ ។ ខ្ញុំស្មានតែគេដកសម្រាប់ទទួល ខ្ញុំគិតស្មានថា គេដកសម្រាប់ទទួលអ្នក

ទោសមកថ្មីទៀត ដែលចាប់មកថ្មីទៀត ។ ដូច្នេះហើយបានជាខ្ញុំភ័យថា អុញ! តិចមួយជាន់នេះ ដល់ខ្ញុំចុះ ។ ខ្ញុំរសោះរសេះ ធ្វើការអត់កើតទេ គិតតែពីដេកទាំងយប់ទាំងថ្ងៃ ។

សរុបមក ខ្ញុំនិយាយរឿងរ៉ាវល្អិតនេះ ដើម្បីបញ្ជាក់ឲ្យឃើញថា វត្ថុបំណងនៃការដែលខាងលើឲ្យដកលើកចុងក្រោយនេះ មិនមែនសម្រាប់ទទួលអ្នកទោសដែលចាប់មកថ្មីទៀតទេ ។ ដូចពីមុនៗទេ តែផ្ទាល់ខ្លួនខ្ញុំ ខ្ញុំស្មានតែគេឲ្យដកឲ្យអស់អ៊ីចឹង សម្រាប់ទទួលអ្នកថ្មី ។ ដូច្នេះ រឿងពិតវាផ្សេង ខ្ញុំយល់ខុសផ្សេង ។ ខ្ញុំសូមចប់ ។

[១៥:៣២:៣៥]

**សៈ** ខ្ញុំជឿថាមានភាពផ្ទុយគ្នាពីអ្វីដែលលោកទើបតែនិយាយអម្បាញ់មិញនេះ ពីព្រោះនៅពេលដែលលោកឆ្លើយលើកដំបូង លោកនិយាយថា ថ្នាក់លើគិតថា ឬក៏មើលទៅដូចជាថា ថ្នាក់លើបានគិតថា ពួកគេហ្នឹង នឹងត្រូវចាញ់វៀតណាម ក៏ប៉ុន្តែលោកនិយាយថា លោកមិនបានគិតថា ដូច្នេះទេ នៅពេលនោះ ។ ហើយលោកក៏បានស្នើទៀតថា លោកចង់រក្សាអ្នកសង្គ្រាមឈ្លើយសឹកវៀតណាម បួនប្រាំនាក់នោះ?

**ឆៈ** ខ្ញុំរក្សាយុទ្ធជន អង្គភាពយ-៨ ។ សូមបញ្ជាក់ជូនលោកចៅក្រមបន្ថែមថា អង្គភាពយ-៨ នេះ ជាអ្នកបាញ់ភ្ញៀវបរទេស សម័យបាញ់ ន៉ៃ សម័យ អេលីហ្សាបេត ប៊េកយ័រ ហើយនិង រីឆាត ដាតម៉ាន់ មកទស្សនកិច្ចនៅកម្ពុជា ។ រីឆាត ដាតម៉ាន់ មកទស្សនកិច្ចនៅកម្ពុជា ដូច្នេះ មិនមែនជាទាហានរបស់វៀតណាមទេ មិនមែនប្រាំបីនាក់ទេ គឺទាហាន ដែលការពារមន្ទីរក្រសួងការបរទេស គឺពួកហ្នឹងហើយដែលបានបាញ់ ធ្វើឃាត ពួកអ្នកកាសែតអង់គ្លេស រីឆាត ដាតម៉ាន់ អីហ្នឹង ដែលមកទស្សនកិច្ចនៅកម្ពុជានោះ ។ នេះខ្ញុំសូមបញ្ជាក់ថា រឿងហ្នឹងហើយ ដែលខ្ញុំចង់ទុកស្ងួរ ដែលខ្ញុំសុំគេទុកស្ងួរ ។

[១៥:៣៥:១០]

**សៈ** នៅពេលដែលលោកនិយាយជាមួយ នួន ជា តើគាត់មានបានប្រាប់លោកទេថា លោកត្រូវតែរៀបចំ ដើម្បីភៀសខ្លួនចេញពីទីក្រុងភ្នំពេញនោះ ។ ដូច្នេះមានន័យថា ត្រូវធ្វើអ្វីដើម្បីបំបិទនូវភស្តុតាងដែលមាននៅទីនោះ តើគាត់មានបាននិយាយដូច្នេះទេ នៅពេលដែលគាត់និយាយជាមួយលោក? តើឬមួយក៏លោកយល់ថា នួន ជា មិនបានគិតអំពីការបាត់បង់ ការបរាជ័យនោះទេ?

**ឆៈ** ជម្រាបប្រសាសន៍លោកចៅក្រម! ទាំង នួន ជា ទាំង ប៉ុល ពត ដែលនៅភ្នំពេញគ្រាន់តែយកវិធានការត្រៀមបម្រុងប៉ុណ្ណឹង ។ ទាំង នួន ជា ទាំង ប៉ុល ពត មិនទាន់ជឿថា កងទ័ពវៀតណាម

ចូលមកដល់ភ្នំពេញឆាប់ៗទេ ។ ភស្តុតាង ឯកសារនៅមន្ទីរ៨៧០ ទាំងប៉ុន្មាននៅទាំងអស់ ។ ទាំង នួន ជា ទាំង ប៉ុល ពត ទាំង ខៀវ សំផន រត់ផាសក្រញាំនៅពេលដែលវៀតណាមចូលមកជិតដល់ ។ នេះវា ជាសភាពការណ៍ដែលខ្ញុំដឹងមកក្រោយមទេ ។ វាជារឿងពិត ។

**ស៖** ដូច្នេះលោកបាននិយាយថា គឺថាមិនគួរមានអ្នកទោសនៅសល់នៅមន្ទីរស-២១ទេ ។ ដូច្នេះ បើយោងទៅតាមអ្វីដែលលោកនិយាយ លោកយល់ថា នឹងមានអ្នកទោសថ្មីត្រូវគេនាំចូលមកមែនទេ? ក៏ប៉ុន្តែលោកមានបំណងថានឹង គិតថានឹងចាកចេញពីស-២១ ហើយលោកបានចេញបញ្ជាឲ្យសម្លាប់ យុទ្ធជនទាំងបួននាក់ មកពី យ-៨ នោះ ។ តើលោកបានចេញបញ្ជាឲ្យសម្លាប់ពួកគេទាំងបួននាក់នោះឬ? ឬមួយក៏ បញ្ជានេះត្រូវបានចេញមកពីថ្នាក់លើ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! បញ្ជាឲ្យកម្ទេចពួកយ-៨ ទាំងបួននាក់នេះ ជាបញ្ជា ដែលខាងលើបញ្ជាមក សម្រាប់ឲ្យយើងដោះស្រាយខ្លួន នៅពេលណាដែលមានបញ្ហា ។ ខ្ញុំយកបញ្ជានេះ ទៅប្រគល់ឲ្យ មិត្តហ៊ី គេអ្នកចាត់ចែង ។ ដល់ពេលកងទ័ពវៀតណាម គេចូលមកដល់ភ្នំពេញ បញ្ជានេះ វានៅធរមាន គេអនុវត្ត ។ ខ្ញុំសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

[១៥:៣៩:២២]

**ស៖** ដូច្នេះ យើងដឹងថា មានអ្នកទោសមួយចំនួនបាននៅរស់រានមានជីវិត ។ តើស្ថានភាពជាក់ លាក់ណាមួយរបស់អ្នក ដែលនៅរស់រានមានជីវិតនោះ គឺជាចំណុចមួយ ជាកម្មវត្ថុមួយ ដែលលោក ហើយនិងថ្នាក់លើរបស់លោកត្រូវពិភាក្សាគ្នាឬ? តើមានហេតុការណ៍ មានហេតុផលអ្វីជាក់លាក់ដែល មិនត្រូវសម្លាប់ពួកអ្នកទាំងនេះឬ? ឬមួយក៏មកតែពីភាពប្រញាប់ប្រញាល់ពេក ដូច្នេះគឺថាមិនមានចេញ សេចក្តីសេចក្តីសម្រេច ដើម្បីឲ្យសម្លាប់អ្នកដែលនៅរស់រានមានជីវិតនោះ ។ ហេតុអ្វីបានជាពួកគេនៅ រស់រានមានជីវិត?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! នៅពេលដែល ពូនួន គាត់បញ្ជាឲ្យស-២១ ដកអ្នកទោស ឲ្យអស់ ខ្ញុំអត់មានបានគិតដល់អ្នកដែលយើងខ្ញុំទុកប្រើប្រហែលជាចំនួនប្រាំបួននាក់ហ្នឹងទេ ។ ខ្ញុំមិនៗ បានគិតដល់មនុស្សដែលខ្ញុំទុកប្រើនោះទេ អត់ទេ អត់សោះ អត់បានគិតដល់រឿងនុ៎ងសោះ ម្លោះហើយ អត់បានសួរបញ្ជាក់គាត់ ។ នៅពេលដែល មិត្តហ៊ី គាត់ដកចេញទាំងអស់ នៅសល់អ្នកដែលយើងធ្លាប់ ប្រើទុកចិត្តទុកថ្លើម ជឿជាក់ហើយយើងទុកប្រើ ។ នៅក្នុងចំណោមអ្នកទុកប្រើហ្នឹងមានមនុស្សដែល ខាងលើសម្រេចឲ្យរួចទោស ឲ្យរួចខ្លួនផុតពីស្លាប់ប្រាំនាក់ ។ ក្នុងចំណោមអ្នកដែលនៅ-- ហើយក្រៅ

ពីនោះមានអ្នកដែលយើងខ្ញុំទុក តាមការសម្រេចដោផ្ទាល់ខ្លួន ក្នុងក្របខ័ណ្ឌមន្ទីរស-២១ ។ ដូច្នេះ ដល់ពេលកងទ័ពវៀតណាមគេចូលមក យើងខ្ញុំរត់ទៅ រត់ចោលទៅ ។ ដូច្នេះ ក្នុងការរត់ចោលទៅនេះ វាមាននៅសល់អ្នកដែលនៅរស់ហ្នឹង ទល់រាល់ថ្ងៃហ្នឹង ដូច្នេះគឺរត់ចោលទៅទាំងស្រុងទេ ។

[១៥:៤៣:១១]

**ស៖** ដូច្នេះ បើសិនជាខ្ញុំយល់ច្បាស់ត្រឹមត្រូវនោះ គឺដោយសារតែការគេចខ្លួនដោយសារប្រញាប់ប្រញាល់ហ្នឹង គឺថាពេក គឺថាអ្នកទាំងនេះមិនត្រូវបានសម្លាប់ មិនអាស្រ័យទៅតាមសេចក្តីសម្រេច ឬក៏អ្វីដែលលោកបានគិតនោះ ហើយដែលវាផុសចេញមកពីអ្វីដែលថាការអះអាងរបស់លោកខាងដើមនោះទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! អត់ទេ អត់មានការសង្គ្រោះ ឬការធានាអីអ៊ីចឹងទេ គឺរត់ទៅដោយៗចៃដន្យប៉ផាប់ពភីងទេ ។ នេះសូមបញ្ជាក់ប៉ុណ្ណឹង ។

**ស៖** លោកក៏បាននិយាយផងដែរ បើសិនជាខ្ញុំមិនច្រឡំទេនោះ ថាថ្នាក់លើបានសម្រេចថា មានមនុស្សប្រាំនាក់ដែលមិនត្រូវសម្លាប់ ។ តើអ៊ីចឹងមែនទេ ដែលលោកបញ្ជាក់នោះ? ប្រសិនបើអ៊ីចឹងមែនតើលោកអាចប្រាប់យើងទេ ហេតុអីបានជាអ្នកទាំងនេះ មិនត្រូវបានសម្រេចឲ្យសម្លាប់ពីថ្នាក់លើនោះ?

**ឆ៖** ពួកនេះ គឺពួកជាងគំនូរ និងជាងចម្លាក់ ដែល ប៉ុល ពត គាត់ចង់ទុកសម្រាប់ឲ្យកសាងវិមានមួយជាវិមានរំឭក មួយនៅលើៗវត្តភ្នំ នៅលើកំពូលវត្តភ្នំ ។ ដូច្នេះ គាត់សម្រេចប៉ុណ្ណឹង ថាមិនត្រូវសម្លាប់ទុកឲ្យរស់ទៅ ។

**ស៖** ដូច្នេះនៅក្នុងថ្ងៃចុងក្រោយនៃសវនាការនេះ ហើយយើងបានយល់ថា លោកបានបញ្ជាក់ថាលោកមិនមានចេតនានឹងទៅមើលកន្លែងឃុំខ្លួនទេ ហើយលោកក៏មិនចង់ឮ ឬក៏មិនចង់ឃើញអ្នកទោសទាំងនោះនៅពេលដែលគេសួរចម្លើយ ហើយនិងគេរងទារុណកម្មនោះ ។ ហើយខ្ញុំក៏ជឿថា យើងយល់ថាលោកមិនមានចេតនាពិនិត្យមើលអ្នកទោសក្នុងពេលដែលគេសម្លាប់ ហើយនិងមើលទីកន្លែងដែលត្រូវសម្លាប់អ្នកនោះ ដើម្បីយល់ថាតើ-- ដើម្បីឲ្យដឹងពីវិធីនៃការសម្លាប់នោះទេ ។ ហើយក៏មិនចង់ដឹងថាគេកប់កន្លែងណាទេ លើកលែងតែលោកមានភារកិច្ចត្រូវទៅ ។ ប្រសិនបើលោកមិនបានទទួលបញ្ជាពីថ្នាក់លើទេ ដែលបង្គាប់ឲ្យលោកទៅទេ ហើយនិងដើម្បីទៅពិនិត្យនូវស្ថានភាពនោះទេ តើនេះជាចំណុចត្រឹមត្រូវ ដែលយើងយល់ទៅតាមគំនិតដែលលោកបញ្ជាក់ដែរឬទេ?

[១៥:៤៧:១៧]

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! លោកចៅក្រមយល់ត្រឹមត្រូវហើយ រឿងពិតគឺអ៊ីចឹង ។

**ស៖** ដូច្នេះការគ្មានចេតនានេះ គឺដោយសារលោកការពារខ្លួនឯង ឬក៏លោកព្យាយាមលាក់កំបាំងពីការពិតដែលលោកអាចនឹងឃើញរូបភាពរំខាន ឬក៏លោកចៀសវាងនូវការជួបប្រទះនូវអារម្មណ៍ដែលមិនពេញចិត្ត ដែលមិនសប្បាយក្នុងចិត្តនោះ?

**ឆ៖** រឿងនេះ ក៏ពិតដែរ លោកចៅក្រម ។ ដូចខ្ញុំបានជម្រាបលោកចៅក្រមពីលើកមុនអ៊ីចឹងថាខ្ញុំក្បត់មិត្ត ក្បត់ភក្តិ ដើម្បីឲ្យតែខ្លួនឯងរស់ បានឃើញពន្លឺព្រះអាទិត្យប៉ុណ្ណឹង ។

**ស៖** ចំពោះរូបលោក ចំពោះអ្នកទោសនៅស-២១ តើគេនៅមានជា-- លោកចាត់ទុកគេជាមនុស្សជាតិដែរឬទេ? ឬក៏ការងារគ្រាន់តែៗអនុវត្ត ដូចជា គោលការណ៍គណិតសាស្ត្រ គ្រាន់តែបូកហើយនិងដក ឬក៏ដើម្បីៗធានានូវគុណភាពនៃសារភាពតែប៉ុណ្ណឹងទេ? ឬក៏មានអ្វីថែមទៀតនោះ?

**ឆ៖** បើមើលឲ្យខ្លីឃើញខ្ញុំរក់រីរវល់នឹងចម្លើយសារភាពនេះមែន ។ ខ្ញុំខំធ្វើការនេះទាំងយប់ទាំងថ្ងៃ អត់ខ្លាចនឿយ អត់ខ្លាចហត់ ។ ក៏ប៉ុន្តែ ជំនាន់នោះ ខ្ញុំខំចៀសៗទៅឃើញកន្លែងណាដែលវាប៉ះទង្គិចនឹងអារម្មណ៍ខ្លាំងពេក ។ ដឹងដែរថា វាជារឿងឧក្រិដ្ឋ តែនៅមានកូនអារម្មណ៍មួយលួងលោមខ្លួនឯងថារដ្ឋាភិបាលគេទទួលខុសត្រូវចំពោះមុខប្រវត្តិសាស្ត្រ ។ ខ្ញុំជាប៉ូលិសខ្ញុំអត់មានអ្នកណានេះទេ អានេះគិតជំនាន់នុ៎ង ភ័យព្រួយតក់ស្លុត វាពិតមានមែនហើយ តែមានកូនអារម្មណ៍នេះ លួងលោម ។ ក៏ប៉ុន្តែមើលសភាពការណ៍ឥឡូវ ដោយខ្ញុំយល់ដឹងឥឡូវនេះ ការងារលើសេចក្ដីសារភាពដែលខ្ញុំចារទៅលើនេះ វាមានធាតុពិតឧក្រិដ្ឋជាងកងពិសេសដែលគ្នាយកមនុស្សទៅកម្ទេចនៅជើងឯងទៅទៀត ។ កងការពារយកមនុស្សទៅកម្ទេចនៅជើងឯក គឺគ្នាកម្ទេចមនុស្សដែលស្លាប់រួចហើយ ដែលខាងលើគេសម្រេចឲ្យសម្លាប់ហើយ ។ ឯចំណែក ខ្ញុំៗមានស្លាបប៉ាកកា ខ្ញុំសរសេររាយការណ៍ទៅលើ ។ ថ្វីត្បិតតែការចារហ្នឹង ខ្ញុំខំរក្សាភាពសត្យានុម័តយ៉ាងម៉េចក៏ដោយ ក៏ខាងលើគេយកអារបស់ហ្នឹងទៅប្រើសម្រាប់ចាប់មនុស្សដែលនៅមានសេរីភាព ។ នេះហើយដែលខ្ញុំបាទទទួលស្គាល់ថា ឧក្រិដ្ឋកម្មដែលខ្ញុំកាន់ស្លាបប៉ាកកាចារលើសេចក្ដីសារភាពហ្នឹង វាឧក្រិដ្ឋជាងគ្នាកងពិសេសទៅទៀត ។ ទន្ទឹមនេះដែរៗ ឯកសារមាគ៌ានយោបាយគោលនយោបាយបក្សដែលខ្ញុំជាអ្នកបង្រៀន វាមានលក្ខណៈឧក្រិដ្ឋកម្មជាងឧក្រិដ្ឋកម្មដែលខ្ញុំសរសេរចារនៅលើសេចក្ដីសារភាពនោះទៅទៀត ។ ពីព្រោះអី? ពីព្រោះអាមាគ៌ានយោបាយ ដែលយើងផ្សព្វផ្សាយទៅហ្នឹង វាទៅសង្កត់ការយល់ដឹងរបស់គេ បន្ថែមការយល់ដឹងរបស់គេឲ្យកាន់តែ ឧក្រិដ្ឋឡើងៗ ដោយស្មានដឹង ។

[១៥:៥៥:១៣]

សូមសរុបមកវិញ រូបថតដែលខ្ញុំអង្គុយបង្រៀនឯកសារហ្នឹង បើមើលអាតឡូវនេះទៅ វាហាក់ដូចជាជំនាន់នោះ ខ្ញុំវាសម្បើមណាស់ ភ្ញាក់រំឭកវណ្ណៈ ។ ក៏ប៉ុន្តែ តាមពិត ដល់មើលអាតឡូវ វិភាគឲ្យមែនទែន គឺជារូបថតមួយគួរឲ្យខ្មាស់អៀន គួរឲ្យតក់ស្លុតនឹងឧក្រិដ្ឋកម្មដែលខ្ញុំបានប្រព្រឹត្តិទៅលើមនុស្សជីវិតមនុស្សមួយម៉ឺនពីរពាន់បីរយផ្លាយនាក់ ។

ដូច្នេះ ខ្ញុំសូមទទួលទាំងអស់ ឧក្រិដ្ឋកម្មនៅស-២១ ទាំងប៉ុន្មាន ។ ទន្ទឹមនេះ ខ្ញុំជំពាក់បក្ខជនម្នាក់ ខ្ញុំតក់ស្លុតនឹងការបាត់បង់អាយុជីវិតប្រជាជនកម្ពុជាជាងមួយលាននាក់ ។ ខ្ញុំទទួលខុសត្រូវខាងផ្លូវចិត្តចំពោះការបាត់បង់អាយុជីវិតប្រជាជនទាំងមួយលានជាងនាក់ ជារៀងរហូត ។ ហ្នឹង ខ្ញុំសូមបញ្ចប់ប៉ុណ្ណេះ ។

[១៤:៥៧:២៤]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំមិនមានសំណួរអ្វីបន្ថែមទៀតទេ សូមអរគុណ ។

**សួរដោយប្រធានអង្គជំនុំ៖**

លោក លោកស្រីចៅក្រមមានសំណួរអ្វីទៀតទេ?

ខ្ញុំនៅមិនទាន់ច្បាស់ពីរបីសំណួរទេ ។ សូមលោកបញ្ជាក់ម្តងទៀត ។

**ស៖** កម្លាំងប្រចាំការនៅជើងឯកពិតប្រាកដហ្នឹង មានចំនួនប៉ុន្មាន? ហើយមុខងារជាសារវន្តជាចម្បងរបស់គេ ពួកហ្នឹងគេមានមុខងារធ្វើអ្វី?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! បើតាមខ្ញុំចាំមានប្អូននាក់ ខ្ញុំមិនស្គាល់ឈ្មោះអស់ទេ ក៏ប៉ុន្តែ ខ្ញុំចាំម្នាក់មែនទែន គឺ ត្រើយ តេង ។ គ្នានៅជីករណ្តៅ គេចេញផុតមកគ្នាលុបរណ្តៅ គ្នាយាមការពារ មិនឲ្យអ្នកណាពីក្រៅចូលទៅដល់កន្លែងនុំង ឃើញកន្លែងនុំង ។ នេះមុខងាររបស់គ្នាប៉ុណ្ណឹងឯងជាសំខាន់ ។

**ស៖** ទីពីរ អំពីទំហំ ឬក៏ជម្រៅនៃរណ្តៅវិញ តើមានការណែនាំពីលោកទេ ថារណ្តៅកប់សពរួមហ្នឹង តម្រូវឲ្យមានការជីកជម្រៅកម្រិតណា? ហើយមានទំហំទទឹងប៉ុន្មាន? បណ្តោយប៉ុន្មានដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! ខ្ញុំអត់មានបានណែនាំលម្អិត ដល់ប៉ុន្មនុំងពេកទេ ។

**ស៖** ចុះឈ្លើយសឹកវៀតណាម តើយកទៅសម្លាប់នៅកន្លែងណា? នៅជុំវិញមន្ទីរមជ្ឈមណ្ឌលសន្តិសុខស-២១ ក្រុងភ្នំពេញ? ឬក៏យកទៅសម្លាប់នៅជើងឯក?

**ឆ៖** ខ្ញុំមិនច្បាស់ទេ ក៏ប៉ុន្តែ សូមសន្និដ្ឋានថាប្រហែលជាយកទៅជើងឯកច្រើនជាង ពីព្រោះមនុស្សនៅមានកម្លាំងដាក់ទៅឆ្ងាយបាន ស្រួលដឹកជញ្ជូន ។

**ស៖** ពាក្យថាមនុស្សសំខាន់ៗហ្នឹង លោកសំដៅទៅបុគ្គលប្រភេទណាទៅ ដែលលោកតែងតែនិយាយថា មនុស្សសំខាន់ ឬក៏បុគ្គលសំខាន់ៗនោះ? សំខាន់ក្នុងជួរបក្ស និងរដ្ឋនៃរបបនោះ? ឬក៏មានមនុស្សផ្សេងទៀត ដែលអាចចាត់ទុកថាជាមនុស្សសំខាន់ដែរ?

**ឆ៖** ខ្ញុំសូមឆ្លើយពីរម៉ាត់ ។ ទីមួយគឺដែលហៅថាមនុស្សសំខាន់នេះ គឺសំដៅមនុស្សនៅក្នុងបក្សហើយនិងរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យជំនាន់នុ៎ង ។ ទីពីរ មិនទាន់មានអ្នកណាធំមកជាង សួរ សុផាន សួរ សុផាន មានឋានៈត្រឹមតែអនុលេខកងពល ក៏ទុកជាសំខាន់ដែរ ដែលត្រូវយកចិត្តទុកដាក់សួរឱ្យផិត ។ ដល់ដល់ក្រោយមក ចុងក្រោយគេ វន វ៉េត ជាមនុស្សសំខាន់ ព្រោះគាត់ វាមានឋានៈដល់ទៅសមាជិកអចិន្ត្រៃយ៍មជ្ឈិម បុគ្គលទីប្រាំមួយ ។ នេះវាវិវត្តទៅតាមសភាពការណ៍អ៊ីចឹង ។

**ស៖** ចុះមនុស្សផ្សេងទៀត ដូចជា ហួត សម្បត្តិ, ហ៊ូ នឹម, ចៅ សេង, ភឹង តុន, ម៉ាក ទូច ហៅ កែម អគ្គរដ្ឋទូតកម្ពុជាប្រជាធិបតេយ្យប្រចាំប្រទេសឡាវ--

(អ្នកបកប្រែ៖ លោកចៅក្រមប្រធាន, សូមលោកអានឈ្មោះឱ្យយឺតបន្តិចទាន ព្រោះខាងអ្នកបកប្រែ បកមិនទាន់ ។ សូមអធ្យាស្រ័យ)

**ប្រធានអង្គជំនុំ៖**

មានករណីមួយចំនួនឃើញថាមានឈ្មោះ ហួត សម្បត្តិ, ហ៊ូ នឹម, ចៅ សេង, ភឹង តុន ដែលលោកតែងតែនិយាយដល់ថា ជាលោកគ្រូរបស់លោក ហើយក៏គាត់ជាសាកលវិទ្យាធិការភូមិន្ទភ្នំពេញ ។ ហើយនៅក្នុងនោះមានឯកអគ្គរដ្ឋទូតកម្ពុជាប្រជាធិបតេយ្យប្រចាំប្រទេសឡាវ ម៉ាក (មាឃ) ទូច ហៅ កែម ហើយនិងមានទាំងឯកអគ្គរដ្ឋទូតកម្ពុជាប្រជាប្រធិបតេយ្យប្រចាំប្រទេសវៀតណាមផងដែរ ដែលត្រូវសម្លាប់នៅទីនោះ ។

**ស៖** ទីមួយយើងសួរថា តើចាត់ទុកថា ជាមនុស្សសំខាន់ដែលទេ? ហើយទីពីរ គឺទីតាំង ឬកន្លែងសម្លាប់គាត់នៅឯក្រុងភ្នំពេញ ឬក៏យកទៅជើងឯករួមជាមួយគេដែរ?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន! សូមបែងចែកជាពីរដាច់ដោយឡែកពីគ្នា ។ បុគ្គលដែលជាសមាជិករួបរួមជាតិកម្ពុជា ហើយនិងជាសមាជិករាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា គេហៅថាបញ្ញាជនយើងខ្ញុំមិនឲ្យតម្លៃថា ជាបុគ្គលសំខាន់ទេ ។ ដូច្នេះ សួរចម្លើយក៏មិនជាយកចិត្តទុកប៉ុន្មាន ដូច ហួត សម្បត្តិ ដូច ជា សាន ដូច អ៊ី ស៊ុបគន្ធី អីៗហ្នឹង អត់មានយកចិត្តទុកដាក់ទេ សួរចម្លើយ ។ នេះជារឿងពិត។ ឯចំណែកពួកនេះ យកទៅកម្ទេចនៅឯណា ខ្ញុំភ្លាប់មិនបានទេ ប៉ុន្មានគ្រាន់តែអាចសន្និដ្ឋានបានថាអាចយកទៅដល់ជើងឯក ។ ម្យ៉ាងទៀតផ្ទៃក្នុង ជាបក្ខជន ឧទាហរណ៍បង សៀង អាន គាត់ជាឯកអគ្គរាជទូតមែន ក៏ប៉ុន្តែគាត់ជាអតីតតស៊ូជើងចាស់ ។ បង មាឃ ទូច ហៅ កែម ប្រពន្ធគាត់ ឌី ខាន ហៅ យួស ថុល ។ នេះជាផ្ទៃក្នុងបក្ស ការយកចិត្តទុកដាក់សួរចម្លើយសង្កត់ធ្ងន់បន្តិចដែរ ចង់ដឹង ចង់ឮ ។

នេះសូមបញ្ជាក់ប៉ុណ្ណេះ ពួកនេះអាចយកទៅកម្ទេចនៅជើងឯកដែរ ។ ដោយឡែក ចំពោះលោកសាស្ត្រាចារ្យ ភីង តុន ខ្ញុំអត់បានដឹងថា គាត់ធ្លាក់ខ្លួនទៅដល់ហ្នឹងទេ ប៉ុន្តែឯកសារវាមាន ។ ការសួរចម្លើយបានសួរចម្លើយបឋមទេ ដែលបង ម៉ម ណៃ ធ្វើហើយ ដែលម្សិលមិញខ្ញុំបានជម្រាបបញ្ជាក់ជូន ។ បុត្រីច្បងរបស់គាត់ ហើយនិងអ្នកបង ដែលជាភរិយារបស់គាត់ថា អត់មានទារុណកម្មទេ បង ម៉ម ណៃ ជាអ្នកសួរ ។ ហើយក្រោយមកប្រហែលជាយើងខ្ញុំមិនដឹង គេទុកត្រាំត្រែងរហូតគាត់ស្លាប់ដោយជំងឺផង ដោយខ្សោយខ្វះម្ហូបអាហារផង រហូតគាត់ស្លាប់ ។ នេះបើសិនជាគាត់ស្លាប់នៅហ្នឹងមជ្ឈមណ្ឌលសន្តិសុខនៅភ្នំពេញ សពហ្នឹងកប់នៅភ្នំពេញ ។ ដូច្នេះ ឲ្យយើងខ្ញុំប៉ាានកំណត់យ៉ាងម៉េចពីសពលោកគ្រូខ្ញុំ ខ្ញុំអត់ប៉ាានកំណត់ទេ នេះជារឿងពិត ។ ក៏ប៉ុន្តែ បុគ្គលម្នាក់នេះ ដែលរឿងខ្ញុំស្តាយៗតែប៉ុណ្ណេះទេ ខ្ញុំគោរពគាត់ដូចគោរព ថៅ សេង, ខ្ញុំគោរពគាត់ដូចគោរពបង វ័ន្ន គត់ ដែរ ។ ប្រសិនជាខ្ញុំបានដឹង បើអាចបានឧបត្ថម្ភគាត់ឲ្យបានអស់ចិត្ត ដូចបានឧបត្ថម្ភបង វ័ន្ន គត់ បានឧបត្ថម្ភ ថៅ សេង ។ ទោះបីជាគេឲ្យខ្ញុំយកគាត់ទៅកម្ទេចថ្ងៃក្រោយក៏ធ្វើម៉េច វាអ៊ីចឹងទៅហើយ ប៉ុន្តែ បានអស់ចិត្តខ្លួនឯងថាបានឧបត្ថម្ភគាត់ ។ តែនេះវាមិនអស់ចិត្តសោះ ។ នេះខ្ញុំសូមជម្រាបឲ្យត្រង់កណ្តាលទេវតាអត់ក្បត់នឹងវិញ្ញាណក្ខន្ធគ្រូខ្លួនឯងទេ ។ សូមវិញ្ញាណក្ខន្ធគ្រូអត់ទោសឲ្យខ្ញុំផង នេះខ្ញុំនិយាយឲ្យត្រឹមពិតខ្ញុំអត់ដឹងមែន បើដឹងក៏ខ្ញុំមិនជួយជីវិតគាត់ឲ្យរួច គឺបានគ្រាន់តែឧបត្ថម្ភគាត់ឲ្យដូច ថៅ សេង យ៉ាងហោចក៏បានដូចប្រហែលបង វ័ន្ន គត់ ដែរ ។ នេះតែប៉ុណ្ណឹងឯង នេះគឺរឿងពិត ខ្ញុំសូមជម្រាបបញ្ជាក់យ៉ាងនេះ ។ ដោយឡែក មនុស្សមួយហ្នឹង គឺប្រហែលជាសពគាត់នៅមជ្ឈមណ្ឌលភ្នំពេញនៃមន្ទីរ ស-២១ ។ នេះខ្ញុំសូមជម្រាបបញ្ជាក់ជូនលោកប្រធានប៉ុណ្ណេះ ។

**ប្រធានអង្គជំនុំ៖**

លោកស្រីចៅក្រមមានសំណួរអីពាក់ព័ន្ធ ជាមួយនឹងខាងតំណាងសហព្រះរាជាអាជ្ញាទេ? បាទ ឥឡូវនេះគឺ-- សូមអញ្ជើញ ។

**លោក វីលៀម ស្មីត៖**

អរគុណលោកប្រធានបើខ្ញុំមិនក្រោកឈរដើម្បីសួរសំណួរជនជាប់ចោទទេ ក៏ប៉ុន្តែខ្ញុំយល់ថាមានការភ័ន្តច្រឡំមួយចំនួន ថាតើបញ្ជីឈ្មោះអ្នកទោសដែលត្រូវបានកែសម្រួលឡើងវិញ ហើយនិងឧបសម្ព័ន្ធហ្នឹងត្រូវបានដាក់តាំងបង្ហាញនូវចំពោះមុខអង្គជំនុំជម្រះហើយឬនៅ? ហើយនិងឯកសារ D61.1 រហូតដល់ 61.5 នោះ ថាតើនឹងត្រូវបានសន្មតថាដាក់បង្ហាញដែរឬទេ គឺឯកសារ D68 រហូត D53.1 ដែលជាការបង្ហាញអំពីទីតាំងរបស់ស-២១ ដែលត្រូវបានបង្ហាញនោះ? ហើយខ្ញុំគិតថា ត្រូវបានដាក់បង្ហាញជាត្រឹមត្រូវនៅចំពោះមុខអង្គសវនាការនោះ? តើត្រឹមត្រូវដែរឬទេលោកចៅក្រម?

[១៦:០៨:១៩]

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន ។ លោក ស្មីត អង្គជំនុំជម្រះបានបញ្ជាក់ថាឯកសារទាំងប៉ុន្មានដែលលោកបានបញ្ជាក់កាលពីព្រឹកមិញ ហើយឯកសារពីរដែលលោកបាននិយាយឡើងវិញនោះ គឺត្រូវបានដាក់តាំងបង្ហាញនៅចំពោះមុខអង្គសវនាការហើយ ទាក់ទងទៅនឹងសេចក្តីណែនាំដែលបានចេញ ហើយនិងទាក់ទងទៅនឹងវិធាន៨៧ ។ ហើយដូចគ្នានេះដែរ គឺមានការបញ្ជាក់ដូចចំពោះឯកសារដែលបានស្នើឡើងដោយមេធាវីការពារក្តី ។ ខ្ញុំសូមឆ្លៀតឱកាសនេះ ដើម្បីធ្វើការធានាថា លោកមិនមានបំណងដាក់បង្ហាញនៅចំពោះមុខអង្គសវនាការនៅពេលនេះ នូវរូបថតនានា ឬក៏ឯកសារនានា ។ ក៏ប៉ុន្តែ លោកនឹងរក្សាសិទ្ធិក្នុងការប្រើឯកសារ ឬក៏រូបថតអស់ទាំងហ្នឹងនៅពេលដែលលោកសួរសំណួរជនជាប់ចោទ ឬក៏សាក្សីដទៃៗទៀត ។ តើនេះជាចំណុចត្រឹមត្រូវដែរឬទេ?

**លោក វីលៀម ស្មីត៖**

ជាការត្រឹមត្រូវហើយលោកស្រីចៅក្រម ឬមួយក៏នៅពេលណាមួយ ដែលយើងធ្វើសេចក្តីសន្និដ្ឋានបញ្ចប់នោះ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

នេះហើយគឺជាការយល់ដឹងពីជំហររបស់ខាងសហព្រះរាជអាជ្ញា ។

ប៉ុន្តែ គ្រាន់តែយើងចង់ធ្វើការបញ្ជាក់ឲ្យច្បាស់នៅពេលនេះ ។ ដូច្នេះខ្ញុំជឿថា យើងបានដោះស្រាយរួចរាល់ហើយ ជាមួយនឹងសំណើរបស់លោក ដែលបានធ្វើកាលពីព្រឹកមិញនេះ ។ ហើយមិនមានបញ្ហាផ្សេងទៀតទេ ទាក់ទងទៅនឹងឯកសារដែលយើងត្រូវធ្វើការដោះស្រាយនោះ?

**លោក វីល្មៀម ស្មីត៖**

សូមអរគុណលោកស្រីចៅក្រម មិនមានសំណើអ្វីផ្សេងទៀតទាក់ទងនឹងឯកសារ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះ ដោយការសួរដេញដោលនៃអង្គហេតុដែលបានគ្រោងទុកហ្នឹង ឃើញថា ដល់ទីបញ្ចប់ហើយ ។ អ៊ីចឹងអង្គជំនុំជម្រះប្រកាសផ្អាកសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការនឹងលើកទៅបន្តនៅថ្ងៃច័ន្ទ ទី២២ ខែមិថុនា ឆ្នាំ២០០៩ ចាប់ពីវេលាម៉ោងប្រាំបួនព្រឹកទៅ ។ ហើយអំឡុងពេលនៃដំណើរការសវនាការចាប់ពីថ្ងៃច័ន្ទ ទី២២ ខែមិថុនា ឆ្នាំ២០០៩នោះ គឺជាវេទិការរបស់ភាគីដែលមានខាងសហព្រះរាជអាជ្ញា មេធាវីការពារក្តី និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលនឹងធ្វើ ដែលឡើងធ្វើការដេញដោលលើអង្គហេតុដែលពាក់ព័ន្ធជាមួយនឹងប្រតិបត្តិការស-២១ ជើងឯកនេះ ។ ហើយសូមអញ្ជើញភាគីចូលរួមនៅក្នុងដំណើរការនីតិវិធី បានជម្រាបអម្បាញ់មិញនេះ ។

អនុរក្សមន្ទីរឃុំឃាំង នាំជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំងវិញ ហើយឲ្យនាំគាត់មកកាន់សាលសវនាការនេះ នៅថ្ងៃច័ន្ទ ទី២២ ខែមិថុនា ឆ្នាំ ២០០៩ ឲ្យបានមុនម៉ោងប្រាំបួនព្រឹកជាកំណត់ ៕

*[សវនាការផ្អាកនៅម៉ោង ១៦:១១:៣៤ នាទី]*